លេខ៖...............................

**សេចក្តីព្រាង**

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រយៈពេល១០ខែ ឆ្នាំ២០១៨ និងទិស១០ខែ ឆ្នាំ២០១៩

(គិតចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៨)

## I. ស្ថានភាពទូទៅ

រយៈពេល១០ខែ ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្រ្កាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថានប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក និងទោះបីរាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៤ឆ្នាំកន្លងទៅនេះ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល។

ពលរដ្ឋខ្មែរនៅតែបាននិងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ វង្វេងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស់ និងពេលវេលាជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ថ្មីៗនេះ រូបភាពនៃអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏កើតឡើងនូវសកម្មភាពផលិត និងចែកចាយរូបភាពអាសអាភាសយ៉ាងអាណាធិបតេយ្យ ក្នុងគោលដៅពាណិជ្ជកម្មផ្លូវភេទ នៅតាមតំបន់ទេសចរណ៍ និងតំបន់អភិវឌ្ឍន៍ថ្មីៗ ដូចជានៅខេត្តព្រះសីហនុ រាជធានីភ្នំពេញ និងសាយភាយទៅតាមទីជនបទមួយចំនួន។

ក្នុងឆ្នាំ២០១៨ នេះដែរ អំពើជួល"**ពពោះជំនួស**" ដើម្បីនាំទារកចេញឆ្លងដែនដោយខុសច្បាប់ ត្រូវបាន រកឃើញ និងបង្រ្កាបក្នុងទ្រង់ទ្រាយធំមួយករណីទៀត បន្ទាប់ពីបានបង្រ្កាបករណីទី១ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦។

ចំណែកឯបទល្មើសពាក់ព័ន្ធនឹងការជួញដូរសេវាផ្លូវភេទ ក៏ត្រូវបានស៊ើបអង្កេត និងបង្ក្រាបទាន់ពេលវេលាផងដែរ។ លើសពីនេះទៅទៀត ភាពរងគ្រោះ ដោយការស្វែងរកគូស្រករក្រៅប្រទេស និងពលការិនីបម្រើការតាមផ្ទះ ក៏មានជាបន្តបន្ទាប់ ហើយត្រូវបានស្ថានទូតកម្ពុជា សហការជាមួយសមត្ថកិច្ចនៃប្រទេសគោលដៅ និងអង្គការដៃគូ សង្គ្រោះ និងបញ្ជូនត្រឡប់មកវិញ។ ក្នុងបញ្ហាអាពាហ៍ពិពាហ៍ទៅក្រៅប្រទេស ក៏មានស្ត្រីមួយចំនួនរងគ្រោះដោយអំពើហិង្សាធ្ងន់ធ្ងរ និងរហូតដល់អំពើឃាតកម្ម ជាដើម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស រយៈពេល១០ខែ ឆ្នាំ២០១៨

### ការអនុវត្តយុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១.បានរៀបចំគោលនយោបាយ

- **ក្រសួងអប់រំ យុវជន និងកីឡា៖** បានប្រកាសឲ្យអនុវត្តគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារនៅតាមសាលារៀន**"។

ក.២. អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខារួច

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាធារណរដ្ឋឥណ្ឌា និងជាមួយអង្គការដៃគូចំនួនពីរ មាន៖សមាគមមូនិធិ **ឈានឆាយ** ដើម្បីមនុស្សធម៌ និងអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល (GVC)។

ក.៣. សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានបន្តដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.៤. សន្ធិសញ្ញាកំពុងរៀបចំ

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - **ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" ចំនួន បី គឺ**
    - រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយ (១)សាធារណរដ្ឋប្រជាមានិតឡាវ (១)សាធារណរដ្ឋបារាំង និង(៣)សាធារណរដ្ឋកូរ៉េខាងត្បូង។

- **ស្ដីពីការ"បញ្ជូនទណ្ឌិត"** ជាមួយចក្រភពអង់គ្លេស ប្រទេសប៉េរូ និងសាធារណរដ្ឋប្រជាមានិតឡាវ។

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International ។

ក.៥. <u>បទដ្ឋានគតិយុត្តិ កំពុងរៀបចំ</u>

- **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖** ធ្វើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**" **និង** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្ដីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្ដីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

ក.៦. <u>**កិច្ចសហប្រតិបត្តិការអន្តរជាតិដែលបានអនុវត្ត**</u>

- កិច្ចប្រជុំអគ្គស្នងការដ្ឋាននគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ជាមួយខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ។

## ខ. <u>ការងារបង្ការ ទប់ស្កាត់</u>

១-<u>ថ្នាក់ជាតិ</u>

- **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** (គិតត្រឹមថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៨) ៖
  - បានអនុញ្ញាតឲ្យភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ចំនួន**៩៥** ធ្វើការជ្រើសរើស បណ្ដុះបណ្ដាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការងារនៅក្រៅប្រទេស។
  - បានអប់រំណែនាំ និងតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅក្រៅប្រទេសចំនួន**៥២**លើក មានពលករសរុបចំនួន ៣៦.១៤៩នាក់ ស្រី ៣១.៤៦៦នាក់។
  - បានចុះធ្វើអធិការកិច្ចទីភ្នាក់ងារឯកជនជាប្រចាំ ដើម្បីពង្រឹងសមត្ថភាព និងតម្រង់ទិសឲ្យទីភ្នាក់ងារជ្រើសរើសឯកជនអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ដើម្បីការការពារ និងលើកកម្ពស់សិទ្ធិពលករខ្មែរនៅក្រៅប្រទេស។
  - បានលើកកម្ពស់លក្ខខណ្ឌការងារ និងបៀវត្សរ៍កម្មករ កម្មការិនីក្នុងស្រុក ឲ្យបានកាន់តែប្រសើរ បានខិតខំ និងជំរុញការអនុវត្តនូវរបបសន្តិសុខសង្គម រួមមានរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងរបបសោធននិវត្តន៍សម្រាប់កម្មករ និយោជិក នៃវិស័យឯកជន អប់រំ និងលើកកម្ពស់ការយល់ដឹងជាប្រចាំដល់កម្មករ និយោជិក អំពីរបបសន្តិសុខសង្គម ផ្សព្វផ្សាយទូលំទូលាយ អំពីទីផ្សារការងារ និងធ្វើអភិបាលកិច្ច ដើម្បីជាជម្រើសសម្រាប់ប្រជាពលរដ្ឋក្នុងការធ្វើការងារ ក្នុងស្រុក កាត់បន្ថយភាពប្រថុយប្រថានស្វែងរកការងារ នៅក្រៅប្រទេស។
  - បានត្រួតពិនិត្យ ផ្សព្វផ្សាយ និងណែនាំ អំពីនីតិវិធីនៃការជ្រើសរើសកម្មករវ័យក្មេង នៅតាមបណ្ដារោងចក្រសហគ្រាស ដែលមានអ្នកចូលរួមសរុបចំនួន ៤០០នាក់ ស្រី ២២៩នាក់។

- ពង្រឹងការការពារ ការលើកកម្ពស់សិទ្ធិ ការបង្ការ ទប់ស្កាត់ ដល់ពលករទេសន្តរប្រវេសន៍ការងារ ជៀសវាងពីការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ត្រូវបានធ្វើឡើងតាមរយៈការពង្រឹងប្រសិទ្ធភាព នៃការផ្តល់សេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជន ការអនុវត្តច្បាប់ បទបញ្ញានានាជាធរមាន និងបន្តកិច្ចសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។
- បានពង្រឹងផ្នែកមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ការងារ ដែលមាននៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥រាជធានី-ខេត្ត សម្រាប់ទទួលពិនិត្យ និងដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍ និងការផ្តល់ប្រឹក្សាយោបល់។
- ក្រសួងបានខិតខំយកចិត្តទុកដាក់ ក្នុងការអនុវត្តលើការងារកុមារ ដោយផ្អែកលើគោលការណ៍៣គឺ៖ **(១)ដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឲ្យកុមារទទួលបានការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មកុមារទៅក្នុងសង្គមជាតិ (២)កិច្ចសហការជាមួយ អង្គការសង្គមស៊ីវិលនានា និងការប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និកុមារ (៣)ការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពកុមារ។**

- **ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា៖**
  - បានចុះសិក្សាផលប៉ះពាល់នៃអំពើជួញដូរមនុស្សលើការសិក្សាចំនួន០៩ខេត្ត ដោយមានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ស្រុក និងគ្រឹះស្ថានសិក្សា ដូចជាខេត្ត៖ កោះកុង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ សៀមរាប កំពង់ឆ្នាំង ស្វាយរៀង ត្បូងឃ្មុំ និងខេត្តរតនគិរី ចំនួន**២៧០**នាក់ ស្រី**៣៤**នាក់។
  - បានសហការជាមួយ UNICEF ដាក់បញ្ចូលខ្លឹមសារការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអ៊ីនធឺណេត ទៅក្នុងកម្មវិធីសិក្សាសាលាបឋមសិក្សា និងមធ្យមសិក្សា និងផ្សព្វផ្សាយដល់កុមារក្រៅសាលានៅតាមសហគមន៍ មានការគាំទ្រដោយអង្គការNGORC។
  - បានសហការជាមួយអង្គការ Winrock អន្តរជាតិ រៀបចំ

## ២-<u>ថ្នាក់ក្រោមជាតិ</u>

- **ខេត្តតាកែវ**
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បើកវគ្គបណ្តុះបណ្តាលបានចំនួន **១៥**វគ្គ ដល់សិក្ខាកាមបានចំនួន **៣៧៥**នាក់ ស្រី **២៣៦**នាក់ រួមមានចំនាញៈ ជួសជុលកុំព្យូទ័រ, សំណង់ជាងកំបោរតបណ្តាញអគ្គិសនី ,ផ្សារដែក, រចនាបោះពុម្ភ, កែសម្ផស្សក្រាត់ដេរសម្លៀកបំពាក់, ជីកំប៉ុស្តដំណាំ បន្លែចម្រុះ, ចិញ្ចឹមត្រី, ចិញ្ចឹមជ្រូកចាក់វ៉ាក់សាំង, ចិញ្ចឹមមាន់ចាក់វ៉ាក់សាំង, និងបណ្តុះផ្សិតចំបើង ក្នុងគោលបំណងកាត់បន្ថយការធ្វើចំណាកស្រុកពីសំណាក់បងប្អូនប្រជាពលរដ្ឋដែលគ្មានចំណេះ ជំនាញ ដើម្បីស្វែងរកការងារធ្វើទាំងក្នុង និងក្រៅប្រទេស។

### ខ.១. <u>ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសពលករឯកជន</u>

❖ តាមរយៈក្រុមហ៊ុនឯកជនចំនួន៩៥ ដែលមានអាជ្ញាប័ណ្ណ និងតាមប្រព័ន្ធអនុគ្រោះមុខរបរ (EPS) របស់រដ្ឋាភិបាលកម្ពុជា បានជ្រើសរើសបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស ចំនួន៩១.២១១នាក់ (ស្រី៣១.៦៣៥នាក់) ក្នុងនោះ៖

- ប្រទេសថៃឡង់ដ៏ ចំនួន៨៤.២៤៦នាក់ (ស្រី២៩.៣០៣នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន ០៣នាក់ (ប្រុស ០៣នាក់)
- ប្រទេសជប៉ុន ចំនួន ២.២១៧នាក់ (ស្រី ១.០៣១នាក់)
- ប្រទេសសឹង្ហបូរី ចំនួន ២៥១នាក់ (ស្រី ២៥១នាក់)
- តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន ៥០នាក់ (ស្រី ៥០នាក់)
- ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន ០៣នាក់ (ស្រី ០៣នាក់)
- ប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ(EPS) ចំនួន៤.៤៤១នាក់ (ស្រី៩៩៧នាក់)

### ខ.២. ការកាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ

រដ្ឋបាលខេត្តចំនួន៣ បន្ទាយមានជ័យ បាត់ដំបង និងប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass)សរុបចំនួន **៧៤.០១៧** ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន ក្នុងនោះ ៖

- ខេត្តបន្ទាយមានជ័យចំនួន ២៦.៩៧៦ ប័ណ្ណ
- បាត់ដំបង ចំនួន ៣៨.៤៦៦ ប័ណ្ណ
- ខេត្តប៉ៃលិន ចំនួន ៨.៥៧៥ ប័ណ្ណ

### ខ.៣. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៨នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើ ចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" ដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន ៤៦.០០០លើក មានអ្នកចូលរួមសរុបចំនួន ៣.៤១៨.៩៩១នាក់ (ធៀបនឹង១០ខែ ឆ្នាំ២០១៧ មានចំនួន **៣.៤៧៥.៣៣២**នាក់) ថយចុះចំនួន**៥៦.៣៤១**នាក់ ស្មើនឹង**១,៦២%** ។ (មូលហេតុ អាជ្ញាធរមមាញឹកក្នុងការរៀបចំការបោះឆ្នោត)

### ខ.៤. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

❖ **នៅថ្នាក់ជាតិ៖**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមផ្តល់បទសម្ភាសន៍៖
  - នៅស្ថានីយ៍ទូរស្សន៍បាយ័ន (BTV) និងនៅស្ថានីយ៍ទូរទស្សន៍ NICE (NICE TV) របស់ក្រសួងមហាផ្ទៃ ស្តីពី «**ការស៊ីឈ្នួលពពោះជំនួស ឬការជួញដូរទារកឆ្លងដែន**» និង អំពី «**ស្ថានភាពពលករវិលត្រលប់តាមច្រកទ្វារព្រំដែនអន្តរជាតិ**» ។
  - ជាមួយ Mr. Rodrigo (UN-WOMEN) និងលោក លឹម ទិត្យ (UN-ACT) អំពីករណីពពោះជំនួស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - បានអនុញ្ញាតជំនួបស្វែងយល់ ករណីស្ត្រីពពោះជំនួស ជាមួយតំណាងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ប្រចាំកម្ពុជា OHCHR-Cambodia អង្គការសហប្រជាជាតិ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- ○ បានផ្សព្វផ្សាយការយល់ដឹងតាមរយៈកម្មវិធីទូរទស្សន៍ អំពើការជួញដូរមនុស្សផងដែរ វិធានការរបស់រាជរដ្ឋាភិបាល ចំពោះអំពើពពោះជំនួសដើម្បីនាំទារកឆ្លងដែនខុសច្បាប់ និងភាពរីកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការ ក្នុងការបង្ការ ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាព។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**
  - ○ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍(MRC) ខេត្តបាត់ដំបង បានផ្សព្វផ្សាយការយល់ដឹងតាមរយៈកម្មវិធីវិទ្យុស្តីពីការធ្វើទេសន្តរប្រវេសន៍ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ជនបទ នៃខេត្តបាត់ដំបង និងប្រជាពលរដ្ឋមួយចំណែក នៃខេត្តប៉ៃលិន ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ ដែលទទួលបានពត៌មានសរុបប្រមាណ ១.០០០.០០០នាក់។
  - ○ បានផលិត និងបោះពុម្ពឯកសារ ស្តីពីការណែនាំការធ្វើទេសន្តរប្រវេសន៍ និងការធ្វើការងារដោយភាពវៃឆ្លាត ចំនួន ៧០.០០០ច្បាប់ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយដល់អាជ្ញាធរមានសម្ថកិច្ច អ្នកធ្វើការងារពាក់ព័ន្ធ សហគមន៍ និងប្រជាពលរដ្ឋ។

- **ក្រសួងធម្មការ និងសាសនា** បានសហការជាមួយអង្គការដៃគូ ដែលធ្វើការផ្តោតលើក្រុមកុមារវ័យជំទង់ និងយុវជន បានផលិតគំនូរជីវចល ផ្សព្វផ្សាយតាមរយៈវីដេអូ ស្តីពីការទប់ស្កាត់អំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការជួញដូរមនុស្សនៅតាម វត្តអារាម និងសហគមន៍ បានចំនួន៥ រាជធានី-ខេត្ត មាន៖(រាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ សៀមរាប និង ខេត្តបាត់ដំបង) មានការចូលរួមចំនួន៦០អង្គ/នាក់

❖ **នៅថ្នាក់រាជធានី ខេត្ត៖**

- បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព តាមប៉ុស្តិ៍វិទ្យុចំនួន២២៣លើក ក្នុងនោះ(ខេត្តកោះកុង ២១១លើក សៀមរាប ០៥លើក កំពង់ចាម ០១លើក បាត់ដំបង០៥លើក និងកំពត០១លើក)។

- **ខេត្តសៀមរាប៖**
  - **មន្ទីរព័ត៌មានខេត្ត** បានសហការជាមួយស្នងការដ្ឋាននគរបាល អង្គភាពជុំវិញខេត្ត និងអង្គការពាក់ព័ន្ធនានា ផលិតកម្មវិធីសន្ទនាដើម្បីផ្សព្វផ្សាយតាមវិទ្យុជាតិនគរភ្នំយ៉ាងទូលំទូលាយដល់សហគមន៍ អាជ្ញាធរមូលដ្ឋានក្រុង-ស្រុក ឃុំ/សង្កាត់ ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកខុសច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ។
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះចែកសម្ភារសិក្សា ដល់សិស្សានុសិស្សចំនួន ៨០នាក់ ស្រី៤២នាក់ ក្នុងគម្រោងលុបបំបាត់ពលកម្មកុមារក្នុងវិស័យឡូតដូ បាន ចមនួន ០៣លើក នៅក្រុងសៀមរាប ស្រុកសូទ្រនិគម និងស្រុកបន្ទាយស្រី។
  - **អង្គការ** Friend International គម្រោងកល្យាណមិត្ត បានធ្វើការចែកខិត្តប័ណ្ណ និងសម្ភារ ផ្សព្វផ្សាយដែលមានខ្លឹមសារទាក់ទងនឹងកិច្ចការការពារកុមារ មានដូចជា៖
    - ○ គន្លឹះទាំង៧សម្រាប់ជួយដល់កុមារ ចំនួន ៤៦៦សន្លឹក

- គន្លឹះទាំង៧សម្រាប់ជនបរទេស ចំនួន ៩១៤សន្លឹក
- កាតទូរស័ព្ទបន្ទាន់ ចំនួន ៨៨៤សន្លឹក
- និងបានលើកស្លាកទូរស័ព្ទបន្ទាន់ ចំនួន ១២រឺម៉កម៉ូតូកង់បី។
- លេខទូរស័ព្ទបន្ទាន់នៅលើផូស្ទ័រ ចំនួន ៤០ផូស្ទ័រ
- រក្សាកុមារនៅក្នុងគ្រួសារ/សហគមន៍ (មណ្ឌលកុមារកំព្រាធ្វើឲ្យកុមារបែកចេញពីគ្រួសារ) ចំនួន ៨៥ផូស្ទ័រ
- ភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន ៦៣អាវ
- ភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន ១០៦ស្ទីកគ័រ
- កុមារមិនមែនជាឧបករណ៍សម្រាប់ទាក់ទាញកុមារទេ ចំនួន ៨៦សន្លឹក

- **ខេត្តបន្ទាយមានជ័យ** សមត្ថកិច្ចនគរបាល និងអង្គកាដៃគូ បានបំផុសសកម្មភាពតាមសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារ និងកិច្ចការការពារកុមារ តាមរយៈបណ្ណាល័យចល័ត ស្តារនីតិសម្បទាចល័ត ភ្នាក់ងារសុវត្ថិភាពកុមារស្ម័គ្រចិត្ត បង្កើតលេខទូរស័ព្ទសុវត្ថិភាពកុមារបន្ទាន់(០៩៥ ៩៦០ ៣០៣) ការជួបជុំគ្នាជាមួយក្រុមគោលដៅនៅតាមសហគមន៍ និងធ្វើសកម្មភាពអប់រំតាមចិញ្ចើមថ្នល់ ។ល។
- **ខេត្តបាត់ដំបង អង្គការ Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំណាកស្រុក **៧៧៣**នាក់ ស្រី **២៨៦**នាក់ ដែលបញ្ជូនត្រឡប់ពីច្រកព្រំដែនដូង ខេត្តបាត់ដំបង។
- **ខេត្តកំពង់ធំ** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅឃុំបន្ទាយស្ទោង និងឃុំសំព្រោច ស្រុកស្ទោង រួមទាំងសមាជិកក្រុមប្រឹក្សាឃុំ សមាជិកភូមិ អនុភូមិ និងមេភូមិសរុបចំនួន **១៥១**នាក់ ស្រី **១១១**នាក់។
- **ខេត្តឧត្តរមានជ័យ** ការិយាល័យជំនាញសហការជាអធិការកិច្ចក្រុង ស្រុកចុះបិទផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមបណ្តាគោលដៅសំខាន់ៗមួយចំនួន។
- **ខេត្តកំពង់ស្ពឺ** បានផលិតបដា ពាក្យស្លោក មួយចំនួនពាក់ព័ន្ធ ខ្លឹមសារនៃវិធានការច្បាប់ប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្ស និងធ្វើការចងបដា ពាក្យស្លោក ទាំងនោះ នៅខាងមុខមន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងនៅតាមវិទ្យាល័យនានាទូទាំងខេត្ត។

## ខ.៥. វិធានការបង្ការ ទប់ស្កាត់ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

### ខ.៥.១. វិធានការទប់ស្កាត់ការធ្វើចំណាកស្រុកតាមជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ

- **ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង៖** ស្នងការដ្ឋាននគរបាល និងវរៈនគរបាលការពារព្រំដែនគោកលេខ(៨១៧, ៨១៩, ៨២៣, ៣១០) បានធ្វើការទប់ស្កាត់ពលករខ្មែរ ដែលបម្រុង ធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ សរុបចំនួន០៩លើក មនុស្សចំនួន **១២០**នាក់ ស្រី **៥០**នាក់ កុមារ **០៦**នាក់។ ក្នុងនោះមានខេត្ត៖
  - **បន្ទាយមានជ័យ** ចំនួន០៧លើក មនុស្សចំនួន១១៤នាក់ ស្រី៤៨នាក់ កុមារ ០៣នាក់។
  - **បាត់ដំបង** ចំនួន០២លើក មនុស្សចំនួន០៦នាក់ ស្រី០២នាក់ កុមារ ០៣នាក់។

## ខ.៥.២-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ

នគរបាលជំនាញនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- **កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្ត៖**
  - (១)ខេត្តកំពត (២)ខេត្តតាកែវ (៣)ខេត្តកែប (៤)ខេត្តមណ្ឌលគិរី (៥)ខេត្តព្រះសីហនុ (៦)ខេត្តកោះកុង (៧)ខេត្តក្រចេះ (៨)ខេត្តឧត្តរមានជ័យ (៩)ខេត្តស្វាយរៀង (១០)ខេត្តកណ្តាល (១១)ខេត្តរតនគិរី (១២)ខេត្តសៀមរាប (១៣)ខេត្តស្ទឹងត្រែង (១៤)ខេត្តពោធិ៍សាត់ (១៥)ខេត្តកំពង់ធំ (១៦)ខេត្តកំពង់ចាម (១៧)ខេត្តកំពង់ឆ្នាំង និង(១៨)ខេត្តស្វាយរៀង ការធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិក ធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ការធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ៖**

| ស្នងការដ្ឋាន រាជធានី ខេត្ត | ១០ខែ ឆ្នាំ២០១៨ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែឧសភា | ខែមេសា | ខែមិថុនា | ខែកក្កដា | ខែសីហា | ខែកញ្ញា | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
| | ៨០២ គោលដៅ | ៥២៣ គោលដៅ | ៦១១ គោលដៅ | ៤២១ គោលដៅ | ២៧៤ គោលដៅ | ៤៩៨ គោលដៅ | ៥២៥ គោលដៅ | ៥៩៣ គោលដៅ | ៦៥៩ គោលដៅ | ៣៧៥ គោលដៅ | | |
| សរុបមនុស្ស | ២.២៣៥ នាក់ | ១.៧៥៣ នាក់ | ២.០៣៧ នាក់ | ១.៨៤៥ នាក់ | ៩៣៩ នាក់ | ២.១៩៤ នាក់ | ២.៦១៦ នាក់ | ២.២៥៦ នាក់ | ២៦.១៧៨ នាក់ | ១.៦៦២ នាក់ | នាក់ | នាក់ |

- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅទូទាំងរាជធានី-ខេត្ត។
- ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន៤០លើក ក្នុងនោះមាន៖ខេត្ត (១)កែប (២)ខេត្តព្រះវិហារ (៣)ខេត្តកំពង់ធំ(៤)ខេត្តកំពង់ស្ពឺ (៥)ខេត្តឧត្តរមានជ័យ (៦)ខេត្តស្ទឹងត្រែង និង(៧)ខេត្តព្រៃវែង និង(៨)ខេត្តស្វាយរៀង ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ**

| ស្នងការដ្ឋាន រាជធានី ខេត្ត | ១០ខែ ឆ្នាំ២០១៨ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែមេសា | ខែឧសភា | ខែមិថុនា | ខែកក្កដា | ខែសីហា | ខែកញ្ញា | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
| | ២៤លើក | ២២លើក | ២២លើក | ២២លើក | ២១លើ | ២២លើក | ៣៥លើក | ៣៣លើក | ៩២លើក | ៤០លើក | | |
| សរុប | | | | | | | | | | | | |

- **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងអង្គការម្លប់តាប៉ាង** បានដាក់បណ្តាញភ្នាក់ងារ ដើម្បីការពារសុវត្ថិភាពកុមារ មានក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី ចំនួន១៤៣នាក់ ផ្ទះសំណាក់ សណ្ឋាគារ ២៤កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ ៧១នាក់ បណ្តាញតាមសហគមន៍ ៦០នាក់ ផ្នែកភ្នាក់ងារទេសចរណ៍០២នាក់ សមាជិកបណ្តាញបុគ្គលិកផ្ទះសំណាក់/សណ្ឋាគារ **៣៧៤**នាក់។
- **ខេត្តសៀមរាប៖**
  - **រដ្ឋបាលក្រុងសៀមរាប** បានធ្វើការដឹកនាំ និងជំរុញឲ្យមន្ត្រីក្រោមឱវាទ ចុះពិនិត្យតាមបណ្តាភូមិ និងប៉ុស្តិ៍រដ្ឋបាលទាំង១២សង្កាត់ ដែលមានប្រជាការពារសរុប **៧១**ក្រុម ស្មើនឹង**១១១**គោលដៅ មានមនុស្សសរុបចំនួន **២.៥៣២**នាក់ លើ**៩៩**ភូមិ។
  - **ស្នងការដ្ឋាននគរបាលខេត្ត៖**
    - បានហាមឃាត់ និងបង្ក្រាបសកម្មភាពភ្ញៀវទេសចរណ៍ ដែលបានបង្កើតក្រុមសប្បាយរាំតាមក្បាច់រួមភេទ នៅចំណុចហាង Scoot Mit ក្នុងតំបន់ Put Street មានចំនួន៣៦នាក់ ស្រី ១១នាក់ ក្នុងនោះបានឃាត់ខ្លួនជនបរទេសចំនួន ០៥នាក់ ស្រី ០៣នាក់ ដែលជាអ្នកប្រមូលផ្តុំភ្ញៀវ នៅស្នងការដ្ឋាននគរបាលខេត្ត ដើម្បីធ្វើកិច្ចសន្យា ផ្តិតមេដៃ និងធ្វើការអប់រំណែនាំឲ្យយល់អំពីវប្បធម៌ខ្មែរ មុននឹងឲ្យពួកគេត្រឡប់ទៅទីលំនៅដ្ឋានវិញ។
    - **និងបានសហការជាមួយអង្គការ Friend InTernation** គម្រោងកល្យាណមិត្ត បានដាក់បណ្តាញភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ ដល់ក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បីចំនួន៤៥នាក់។
  - **មន្ទីរទេសចរណ៍ខេត្ត** បានចុះត្រួតពិនិត្យនៅតាមបណ្តាសេវាកម្មសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ដើម្បីជំរុញឲ្យម្ចាស់អាជីវកម្មបន្តអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់ទេសចរផ្លូវភេទ និងការជួញដូរមនុស្ស និងបន្តបិទផ្សាយហាមមិនឲ្យក្មេងអាយុក្រោម១៨ឆ្នាំ ចូលទៅមណ្ឌលកម្សាន្តដោយគ្មានអាណាព្យាបាលទៅជាមួយ។
  - **មន្ទីរធម្មការ និងសាសនាខេត្ត** បានធ្វើសេចក្តីណែនាំ ប្រគេន និងជំរាបជូនដល់មន្ត្រីសង្ឃនៃការិយាល័យធម្មការ និងសាសនាខេត្ត/ក្រុង/ស្រុក ដើម្បីជំរុញព្រះសង្ឃដែលជាធម្មធឹកបន្តអប់រំ ផ្សព្វផ្សាយដល់ពុទ្ធបរិស័ទចំណុះជើងវត្ត ឲ្យបានយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពទៅក្រៅប្រទេស នៅក្នុងកម្មវិធីបុណ្យកាន់បិណ្ឌ បុណ្យកឋិនទាន និងបុណ្យចេញព្រះវស្សាជាដើម។
  - **មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត** បានធ្វើការណែនាំ និងបញ្ជ្រាបការផ្សព្វផ្សាយអំពីបញ្ហានៃអំពើជួញដូរមនុស្ស ដល់កម្មករនៅតាមបណ្តារោងចក្រ សហគ្រាស សិប្បកម្ម និងម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម ឲ្យមានការលើកទឹកចិត្តដល់កម្មករ ទាំងបញ្ហាសុខភាព ទាំងការលើកទឹកចិត្តបន្ថែមដល់អ្នកធ្វើការងារបានល្អ និងមានការសហការគ្នាឲ្យបានល្អរវាង ម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម និងកម្មករ ដើម្បីឈានទៅរកការរីកចម្រើន និងការកាត់ បន្ថយការធ្វើចំណាកស្រុកទៅក្រៅប្រទេស។

- **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះធ្វើការសម្ភាសដល់មាតា បីតា របស់កុមារ ក្នុងគម្រោងបង្ការ ទប់ស្កាត់ និងដកហូតពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដោយបានធ្វើកិច្ចសន្យាបញ្ឈប់ប្រើប្រាស់កុមារក្នុងវិស័យឡឥដ្ឋ នៅក្រុងសៀមរាប ស្រុកសូទ្រនិគម និងស្រុកបន្ទាយស្រី។

## ខ.៦. វិធានការប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់

### ខ.៦.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

ការធ្វើបច្ចុប្បន្នភាពលើទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងឆមាសទី១ ឆ្នាំ២០១៨នេះ មានតួលេខ ដូចខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំឆមាសទី១***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣០០.០៧៧ | ១២៧.៧៤៩ | ៨.៤៧៨ | ៣.១៦៥ | ១៦៨.០៤២ | ៧៤.៦៣៥ | ៩៥៦ | ៤២៧ | ១៣២.០៣៥ | ៥៣.១១៤ | ៧.៥២២ | ២.៧៣៨ | ថយចុះ ២១.៥២០ |
| កុម្ភៈ | ២៨៨.២៦៣ | ១២៦.៨២៩ | ៨.៥១៣ | ៣.១៦៦ | ១៥៧.១៤៧ | ៧៣.៦៥៨ | ៩៩៧ | ៤២៧ | ១៣១.១១៦ | ៥៣.១៧១ | ៧.៥១៦ | ២.៧៣៩ | ថយចុះ ១១.៨១៤ |
| មីនា | ២៦០.២២៨ | ១១៤.១២៩ | ៦.៨៨០ | ២.៤៧៩ | ១៥៥.៣៧៧ | ៧០.៩៩៥ | ៤២៨ | ១៥៣ | ១០៤.៨៥១ | ៤៣.១៣៤ | ៦.៤៥២ | ២.៣២៦ | ថយចុះ ២៨.០៣៥ |
| មេសា | ៣២២.៨៦៧ | ១៤៧.៩៥៨ | ៩.០៩០ | ៣.៥០៨ | ១៨៣.០៦៤ | ៩១.៦៤៨ | ១.៨០៦ | ៧៧៦ | ១៣៩.៨០៣ | ៥៦.៣១០ | ៧.២៨៤ | ២.៧៣២ | កើនឡើង ៦២.៦៣៩ |
| ឧសភា | ៣២២.៨៨៩ | ១៤៧.៩១៦ | ៧.៨៧៨ | ២.៩៧៨ | ១៨៣.៧៤៥ | ៩១.៤៩០ | ៦១៩ | ២៥៣ | ១៣៩.១៤៤ | ៥៦.៤២៦ | ៧.២៥៩ | ២.៧២៥ | កើនឡើង ២២ |
| មិថុនា | ៣៤២.៣៤២ | ១៥៣.១៩៤ | ៩.០៥៦ | ៣.៣៦៧ | ១៩២.៤២២ | ៨៨.៦៩៥ | ៦៥២ | ២៧៦ | ១៤៩.៩២០ | ៦៤.៤៩៩ | ៨.៤០៤ | ៣.០៩១ | កើនឡើង ១៩៤៥៣ |
| កក្កដា | ៤០៥.៨៥៣ | ១៥៦.៨១២ | ៨.៤៤៥ | ២.៧៥១ | ១៩៧.២១០ | ៩០.៧០៩ | ៦៥២ | ២៧៦ | ២០៨.៦៤៣ | ៦៦.១០៣ | ៧.៧៩៣ | ២.៤៧៥ | កើនឡើង ៦៣.៥១១ |
| សីហា | ៣១១.៧៨៦ | ១៥៩.១២៤ | ១១.០២០ | ៤.២៥២ | ១៩៥.៣៧៦ | ៩០.៤៦៥ | ២.១០០ | ៩៥០ | ១១៦.៤១០ | ៦៨.៦៥៩ | ៨.៩២០ | ៣.៣០២ | ថយចុះ ៩៤.០៦៧ |
| កញ្ញា | ៣៦២.៤៩៥ | ១៥៩.៧៤៦ | ៩.៤៨៨ | ៣.៥៨០ | ១៩៨.២៦៥ | ៩១.៦៧១ | ៦៥៣ | ២៧៧ | ១៦៤.២៣០ | ៦៨.០៧៥ | ៨.៨៣៥ | ៣.៣០៣ | កើនឡើង ៥០.៧០៩ |
| តុលា | ៣៦១.១៥១ | ១៦១.៤៤០ | ៩.៤២៧ | ៣.៥៤២ | ១៩៩.៩០៥ | ៩៥.០៥៩ | ៦៥៣ | ២៧៧ | ១៦១.២៤៦ | ៦៦.៣៨១ | ៨.៧៧៤ | ៣.២៦៥ | ថយចុះ ២.២៦០ |

## ខ.៧. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន **១.១៥៦គូ** ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាម រយៈទូរស័ព្ទផ្ទាល់ចំនួន **១១៤**នាក់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន១៧ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (រាជធានីភ្នំពេញ

បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កណ្ដាល កំពង់ធំ ព្រះវិហារ ក្រចេះ ស្វាយរៀង សៀមរាប ព្រះសីហនុ តាកែវ ឧត្ដរមានជ័យ និងខេត្តត្បូងឃ្មុំ)។

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

**អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់)** កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន **១០៩/១៣៩**ករណី (បើប្រៀបធៀបនឹង១០ខែ ឆ្នាំ២០១៧ មានការថយចុះចំនួន **៣០**ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងសរុបចំនួន **១៨៥/១៨១**នាក់ (ស្រី **៧៩**នាក់) ក្នុងនោះមានជនសង្ស័យជាអនីតិជន **១៣**នាក់ និងជនបរទេសចំនួន **៣០/១៧**នាក់ មាន **០៩**សញ្ជាតិ (អង់គ្លេស **០៥**នាក់ ចិន **១៥**នាក់ វៀតណាម **០៣**នាក់ កាណាដា **០២**នាក់ អូស្ត្រាលី **០១**នាក់ ន័រវេ **០១**នាក់ ហូឡង់ **០១**នាក់ ញូស៊ីលែន **០១**នាក់ និងហ្វីលីពីន **០១**នាក់)។ យើងបានសង្គ្រោះជនរងគ្រោះចំនួន **១៨៩/២៥៣**នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ **៦៩**នាក់ អាយុពី១៥-១៧ឆ្នាំ **២១**នាក់ និងអាយុ១៨ឆ្នាំឡើង **៩៩**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **៧៤**នាក់ អង្គការ **០២**នាក់ និងគ្រួសារចំនួន **១១៣**នាក់)។

**១.ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **៣៤/៤៣ករណី** (បើប្រៀបធៀបនឹង១០ខែ ឆ្នាំ២០១៧ ថយចុះចំនួន ០៩ ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **៨៦**នាក់ (ស្រី **៦២**នាក់) និងជនបរទេស **០៥**នាក់ សញ្ជាតិចិន សង្គ្រោះជនរងគ្រោះចំនួន **៥៥**នាក់ ក្នុងនោះ៖ អាយុក្រោម១៥ឆ្នាំ **០៧**នាក់ អាយុពី១៥-១៧ឆ្នាំ **០៨**នាក់ និងអាយុ១៨ឆ្នាំឡើង ៤០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**១៣**នាក់ អង្គការ **០២**នាក់ និងទៅគ្រួសារចំនួន ៤០នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០៧ | ១០(អនីតិ.១) | |
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៨ | ១៣ | ចិន៣ |
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១០ | ១២ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ | ០២ | ០៣ | ចិន១ |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | |
| -អំពើលក់-ដូរមនុស្សដោយមានគោលដៅ | ០២ | ០៣ | |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ០១ | ០៤ | |
| -ការទទួលយកមនុស្សដោយជួយដល់ជនល្មើស | ០១ | ០១ | |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ០១ | ៣៧ | ចិន១ |
| -អំពើអូសទាញពេស្យាចារកុមារ | ០១ | ០២ | |
| *សរុប* | *៣៤ ករណី* | *៨៦ នាក់(អនីតិ.១)* | *០៥ នាក់* |

**២.ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន៧៥/៩៦ករណី (បើប្រៀបធៀបនឹង១០ខែ ឆ្នាំ២០១៧ ថយចុះចំនួន ២១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៩៩នាក់ (ស្រី ១៧នាក់) ជនសង្ស័យជាអនីតិជន ០៨នាក់ និងជនបរទេស ២៥នាក់ មានសញ្ជាតិអង់គ្លេស ០៥នាក់ វៀតណាម ០៣នាក់ កាណាដា ០២នាក់ អូស្ត្រាលី ០១នាក់ ន័រវេ ០១នាក់ ហូឡង់ ០១នាក់ ញូស៊ីលែន ០១នាក់ ចិន ១០នាក់ និងហ្វីលីពីន ០១នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ១៣៤នាក់ ក្នុងនោះ៖ មានអាយុក្រោម១៥ឆ្នាំ ៦២នាក់ អាយុ១៥-១៧ឆ្នាំ ១៣នាក់ និងអាយុ១៨ឆ្នាំឡើង ៥៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន ៦១នាក់ និងទៅគ្រួសារចំនួន ៧៣នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ស្គាលទម្ងន់ទោស ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | អូស្ត្រាលី១ |
| -សញ្ជារកម្ម | ០៦ | ១៥(អនីតិ.១) | ចិន១០ |
| -សញ្ជារកម្ម (មានអនីតិជន) | ០៥ | ០៦ | |
| -ស្គាលទម្ងន់ទោសនៃសញ្ជារកម្ម | ០២ | ០៤ | |
| -សញ្ជារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០៣ | ០៦(អនីតិ.១) | វៀតណាម៣ |
| -រូបភាព និងសម្ភារអាសអាភាស | ០២ | ១១(អនីតិ.១) | អង់គ្លេស៥ កាណាដា២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤១ | ៤១(អនីតិ.៩) | ន័រវេ១ ហូឡង់១ ញូស៊ីលែន១ |
| -អំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៥ | ១៥ | ហ្វីលីពីន១ |
| *សរុប* | *៧៥ ករណី* | *៩៩នាក់(អនីត.១២)* | *២៥នាក់* |

### ៣.ការដោះស្រាយករណីវិវាទរវាងពលករទេសន្តរប្រវេសន៍ និងបណ្តាក្រុមហ៊ុននានា

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - បានទទួលនិងដោះស្រាយវិវាទផ្នែក ទេសន្តរប្រវេសន៍ ចំនួន ៣៧ក្រុមហ៊ុន មានសំណុំរឿងចំនួន ៣៩ករណី ក្នុងមានពលករចំនួន ៥៨៧នាក់ ស្រី ២១៨នាក់។ បណ្តឹងសះជាចំនួន ៣១ករណី បណ្តឹងមោឃៈ ០១ករណី និងបណ្តឹងកំពុងតាម ដានដោះស្រាយបន្តមានចំនួន ០៧ករណី។
  - បានត្រួតពិនិត្យក្នុងការអនុវត្តគម្រោងការបង្ការទប់ស្កាត់ និងការដកហូតពលកម្មកុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច បានចំនួន ០៦លើក ក្នុងនោះបានដកហូតកុមារ ចំនួន ២០០នាក់ ស្រី ១០៥នាក់។

### ៤.ការបង្ក្រាបករណីជួលពពោះជំនួស ដើម្បីនាំចេញឆ្លងដែនខុសច្បាប់

**នគរបាលរាជធានីភ្នំពេញ** បានបង្ក្រាបអំពើពពោះជំនួសដើម្បីនាំទារកឆ្លងដែន បានមួយករណីដែលមានជនពាក់ព័ន្ធ ៥នាក់ និងស្ត្រីពពោះជំនួស ៣២នាក់ ។ ករណីនេះ តុលាការ បាននិងកំពុងតែបន្តនីតិវិធីស៊ើបអង្កេតរកជនល្មើសពាក់ព័ន្ធ និងភស្តុតាងបន្ថែមទៀត ដើម្បីកំណត់បទល្មើស និងរកជនល្មើសមកផ្តន្ទាទោសឲ្យបានត្រឹមត្រូវ។

### គ.២. <u>កិច្ចការយុត្តិធម៌</u> (រយៈពេល ៩ខែ)

### គ.២.១. <u>លទ្ធផលចំណាត់ការផ្តន្ទាទោស</u>

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

#### គ.២.១.១. <u>ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត</u>

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន **១២៣**ករណី ជនរងគ្រោះ ចំនួន **១៤៤**នាក់(អនីតិជន **៩០**នាក់ ស្រី**៧០**នាក់) ជនត្រូវចោទមានចំនួន **១៤៧**នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន **៧៨**ករណី តម្កល់ទុកឥតចាត់ការ **០៣**ករណី និងកំពុងចាត់ការចំនួន **៤២**ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប ១២៣ | ១៣ | ៤១ | ២០ | ៧០ | ១០៥ | ២២ | ១៩ | ០១ | ៧៨ | ៣ | ៤២ |
| | ៥៤នាក់ | | ៩០នាក់ | | ១២៧នាក់ | | ២០នាក់ | | ១២៣ករណី | | |

#### គ.២.១.២. <u>ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត</u>

ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត សរុបមានចំនួន ៣៦៤ករណី ជនរងគ្រោះ ៤៥៤នាក់(ស្រី១៧២នាក់) អនីតិជន២៥៥នាក់(ស្រី២៤៤នាក់) ជនត្រូវចោទមានចំនួន ៤៨៧នាក់(ស្រី៥៤នាក់ អនីតិជន ៧០នាក់(ស្រី០៣នាក់) នៅក្នុងឃុំចំនួន៣៨០នាក់ (ស្រី៤៦នាក់) អនីតិជន ៦៥នាក់(ស្រី៣២នាក់) នៅក្រៅឃុំ ១៥៦នាក់ (ស្រី៣៩នាក់) អនីតិជន ៤៤នាក់(ស្រី១៣នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន ៥៩ករណី លើកលែងចោទ ១ករណី និងកំពុងចាត់ការចំនួន ៣០៤ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប ៣៦៤ | ២៧ | ១៧២ | ១១ | ២៤៤ | ៣៦៣ | ៥៤ | ៦៧ | ៣ | ២១៨ | ៤៧ | ៣២ | ៣២ | ៧៣ | ៤០ | ៣១ | ១៤ | ៥៩ | ១ | ៣០៤ |
| | ១៩៩នាក់ | | ២៥៥នាក់ | | ៤១៧នាក់ | | ៧០នាក់ | | ៣២៩នាក់ | | | | ១៥៨នាក់ | | | | ៣៦៤ករណី | | |

#### គ.២.១.៣.<u>ចំណាត់ការរបស់ចៅក្រមជំនុំជម្រះនៃសាលាដំបូង រាជធានី-ខេត្ត</u>

ចំណាត់ការរបស់ថៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន ១៦៧ករណី ជនរងគ្រោះចំនួន ២២២នាក់(ស្រី ១២៨នាក់) អនីតិជន ៨៥នាក់(ស្រី ៨០នាក់) ជនជាប់ចោទសរុប ២១០នាក់ (ស្រី ៣៨នាក់) និងប្រភេទចំណាត់ការ (ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៥០ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ៩៤នាក់ នៅក្រៅឃុំ ៤១នាក់ និងកំពុងចាត់ការ ១១៧ករណី) ដូចមានតារាងរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ថៅក្រមជំនុំជម្រះរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| សរុប ១៦៧ | ៩ | ១២៨ | ៥ | ៨០ | ១៧២ | ៣៨ | ០ | ០ | ០ | ០ | ៥០ | ៩៤ | ៤១ | ១១៧ |
| | ១៣៧នាក់ | | ៨៥នាក់ | | ២១០នាក់ | | | | | | | | | |

គ.៣. <u>ការងារដោះស្រាយវិវាទ រវាងពលករទេសន្តរប្រវេសន៍ និងក្រុមហ៊ុនឯកជននានា</u>

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានទទួល និងដោះស្រាយវិវាទផ្នែកទេសន្តរប្រវេសន៍ចំនួន **៣៧**ក្រុមហ៊ុន មានសំណុំរឿង **៣៩**ករណី ក្នុងនោះមានពលករសរុបចំនួន **៥៨៧**នាក់ ស្រី **២១៨**នាក់។ បានដោះស្រាយបណ្តឹងសះជាចំនួន **៣១**ករណី និងបណ្តឹងកំពុងតាមដានដោះស្រាយបន្តចំនួន **០៧**ករណី ។

## ឃ. <u>កិច្ចការការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ</u>

### ឃ.១. <u>ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ</u>

#### ឃ.១.១. <u>ការទទួលជនសង្ស័យរងគ្រោះ</u>

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

  យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន **៤៣៤**នាក់ ស្រី **២៥៩**នាក់ មកពី ៖

  - ប្រទេសម៉ាឡេស៊ី ចំនួន **២០៧**នាក់ (ស្រី **១១៩**នាក់)
  - ប្រទេសចិន ចំនួន **១០២**នាក់ (ស្រី **៨៩**នាក់)
  - ប្រទេសវៀតណាម ចំនួន **៦៣**នាក់ (ស្រី **២០**នាក់)
  - ប្រទេសឡាវ ចំនួន **០៩**នាក់ (ស្រី **០១**នាក់)
  - ប្រទេសថៃ ចំនួន **៣៦**នាក់ (ស្រី **១៨**នាក់)
  - ប្រទេសសិង្ហបុរី ចំនួន **១០**នាក់ (ស្រី **១០**នាក់)
  - ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន **០៥**នាក់ (ស្រី **០៣**នាក់)
  - ប្រទេសឥណ្ឌូនេស៊ី ចំនួន **០២**នាក់

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន **២៧៤**នាក់ (ស្រី **២៣១**នាក់) កុមារ**៦៨**នាក់(កុមារី**២៩**នាក់)។ មានដូចខាងក្រោម៖

| ឆ្នាំ២០១៨ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិយាយ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆកា | ធ្នូ |
| ទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា | ៩០នាក់ ស្រី៥៣នាក់ | ២៦នាក់ ស្រី១៤នាក់ | ១០នាក់ ស្រី៥នាក់ | ១០នាក់ ស្រី | ១៧នាក់ ស្រី១៤នាក់ | ២១នាក់ ស្រី២០ | ៤០នាក់ ស្រី៣២នាក់ | ៥៥នាក់ ស្រី៤២នាក់ | គ្មាន | ៣១នាក់ ស្រី | | |
| សរុប | | | | | | | | | | | | |

- បានទទួលជនសង្ស័យរងគ្រោះដែលអជ្ញាធរបរទេសបញ្ជូនត្រឡប់ពីប្រទេសនានា ចំនួន **១៧៣**នាក់ (ស្រី **១៣៩**នាក់) ក្នុងនោះមកពីប្រទេស៖ ចិន **៨២**នាក់ វៀតណាម **២៩**នាក់ ម៉ាឡេស៊ី **៦០**នាក់ និងអារ៉ាប់ប៊ីសាអូឌីត **០២**នាក់ ក្នុងនោះមានករណី៖ រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ **៩៩**នាក់ ជួញដូរផ្លូវភេទ **១២**នាក់ និងជួញដូរកម្លាំងពលកម្ម **៦២**នាក់ (ដោយមានការសហការពី អង្គការសម្ព័ន្ធចាប់ដៃ អង្គការ IOM អង្គការរតនៈអ៊ិនធើណេសិនណល អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ អង្គការក្ដីសង្ឃឹម និងយុត្តិធម៌ អង្គការមេត្រីអន្តរជាតិ ។
- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលជនរងគ្រោះសរុបចំនួន៩៨នាក់(ស្រី២៣នាក់) កុមារ៦៧នាក់(កុមារី២៨នាក់) ក្នុងនោះ៖
  - ជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃប្រទេសថៃ (DSDW) ចំនួន **២០**នាក់ (ស្រី **០២**នាក់) កុមារ **១៦**នាក់ (កុមារី **០៨**នាក់) ជាករណីជួញដូរកម្លាំងពលកម្ម។
  - ជនរងគ្រោះនិរទេសចំនួន **៧៩**នាក់ (ស្រី **២១**នាក់) កុមារ **៥២**នាក់ (កុមារី **២១**នាក់)។
- បានធ្វើមាតុភូមិនិវត្តន៍ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ជនជាតិវៀតណាមចំនួន **០២**នាក់ត្រឡប់ទៅប្រទេសវៀតណាមវិញ ដោយមានការសហការពីមន្ត្រីមន្ទីរ ស.អ.យ ខេត្ត ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការមេត្រីអន្តជាតិ។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

**អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់)** បានទទួលពលករខ្មែរដែលត្រឡប់ពីបណ្ដាប្រទេសផ្សេងៗចំនួន **១៥៧**នាក់ (ស្រី **១២២**នាក់) ក្នុងនោះបានសម្ភាស ចំនួន **១៤៦**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

| ល.រ | មកពីប្រទេស | ចំនួនសរុប | សម្ភាសន៍ | ទៅតាមរយៈ | | | |
|---|---|---|---|---|---|---|---|
| | | | | ក្រុមហ៊ុន | មេខ្យល់ | ខ្លួនឯង | អ្នកស្គាល់គ្នា |
| ១ | ចិន | ៦៩ | ៦៧ | | ៦២ | | ៥ |
| ២ | ម៉ាឡេស៊ី | ៥៦ | ៤៨ | ៨ | ៣០ | ៧ | ៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | វៀតណាម | ២១ | ២០ | ១ | ១៨ | | ១ |
| ៤ | ថៃ | ១ | ១ | | ១ | | |
| ៤ | ឥណ្ឌូនេស៊ី | ៥ | ៥ | | | | ៥ |
| ៥ | អារ៉ាប៊ីសាអូឌីត | ៥ | ៥ | ៣ | ២ | | |
| **សរុប** | | **១៥៧** | **១៤៦** | **១២** | **១១៣** | **៧** | **១៤** |

- **ខេត្តបន្ទាយមានជ័យ**
    - **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ** បានទទួល និងធ្វើការសម្ភាសដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញារងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ពីប្រទេសថៃ ចំនួន ៦២នាក់ (ស្រី ១៩នាក់) កុមារ ៣៩នាក់ (កុមារី ១៨នាក់) ក្នុងនោះមាន៖ (ជនងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស ៦០នាក់ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០១នាក់ និងជួញដូរកម្លាំងពលកម្ម ០១នាក់។

ឃ.៣. <u>ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស</u>

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទាចំនួន ៦៩៤នាក់ (ស្រី ៤០៦នាក់ កុមារ ១៣៣នាក់ កុមារី ៩៦នាក់)ដូចមានក្នុងតារាងខាងក្រោម៖

- បានធ្វើការសម្ភាស និងបញ្ជូនជនរងគ្រោះទាំង ៨១នាក់ (ស្រី ៦៨នាក់) រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ២៣នាក់ ជួញដូរផ្លូវភេទ ១៨នាក់ និងជួញដូរកម្លាំងពលកម្ម ៤០នាក់ ទៅទទួលស្តារនីតិសម្បទា ពីអង្គការដៃគូមានដូចជា: អង្គការសម្ព័ន្ធចាប់ដៃ អង្គការលីកាដូ អង្គការរតនៈអ៊ិនធើណេសិនណល អង្គការបេសកម្មយុត្តិធម៌អន្តរជាតិ អង្គការសូននៃក្តីសង្ឃឹមកម្ពុជា និងអង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានបញ្ជូនជនរងគ្រោះដែលនិរទេស និងធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ៩៥នាក់ (ស្រី ២១នាក់) កុមារ ៦៦នាក់ (កុមារី ២៩នាក់) ទៅអង្គការដៃគូ៖ អង្គការ IOM ០២នាក់ អង្គការដំណក់ទឹក ៥២នាក់ អង្គការគ្រួសារថ្មី០៤នាក់ អង្គការកល្យាណមិត្ត(ភ្នំពេញ) ០១នាក់ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ២៨នាក់ អង្គការសូននៃក្តីសង្ឃឹម និងយុត្តិធម៌ ០៥នាក់ អង្គការ A21 ០១នាក់ និងអង្គការភឿន ០២នាក់ ដើម្បីទទួលសេវាស្នាក់នៅសុវត្ថិភាព អប់រំក្នុង និងក្រៅប្រព័ន្ធ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងផ្តល់សេវាផ្សេងៗទៀត មុនពេលធ្វើសមាហរណកម្មទៅសហគមន៍វិញ។
- **មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានធ្វើការពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះ**ដោយអំពើជួញដូរមនុស្សចំនួន ១៧៤នាក់ (ស្រី ១៧១នាក់) កុមារ ០២នាក់ ក(កុមារី ០២នាក់) ទៅទទួលសេវាស្តារនីតិសម្បទានៅមណ្ឌលរដ្ឋ និងអង្គការដៃគូ) ក្នុងនោះមាន៖ មន្ទីរ ស.អ.យ រាជធានីភ្នំពេញ ១៥០នាក់ មន្ទីរ ស.អ.យខេត្តក្រចេះ ១៣នាក់ តាកែវ ០៦នាក់ សៀមរៀប ០៤នាក់

និងមន្ទីរ ស.អ.យខេត្តពោធិ៍សាត់ ០១នាក់ ។ (ករណីជួញដូរមនុស្ស ៥៤នាក់ និងករណីធ្វើអាជីវកម្មផ្លូវភេទ ១២៣នាក់)។

- អង្គការក្រៅរដ្ឋាភិបាល ដែលជាដៃគូ បានទទួល និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញសរុបចំនួន ៣៨៤នាក់ (ស្រី ១៤៦នាក់ កុមារ ៦៥នាក់ (កុមារី ៦៥នាក់) ក្នុងនោះរួមមានៈ អង្គការរតនៈអ៊ិនធើណេសិនណល ៥៦នាក់ អង្គការមេត្រីអន្តរជាតិ ០១នាក់ អង្គការស្ទួននៃក្តីសង្ឃឹម និងយុត្តិធម៌ ៣៩នាក់ អង្គការបេសកកម្មទូទាំងពិភពលោក ០៩នាក់ អង្គការARM ០១នាក់ អង្គការពន្លកថ្មី ១២នាក់ អង្គការមូលនិធិហាការអន្តរជាតិ ៦៤នាក់ អង្គការសម្ព័ន្ធចាប់ដៃ ២៦នាក់ អង្គការជោគវាសនានៅកម្ពុជា ៣៨នាក់ សមាគមន៍កុមាររីករាយ ២៤នាក់ អង្គការរ៉េណាសេដើរជាមួយស្ត្រីកម្ពុជា ០៣នាក់ និងអង្គការសកម្មភាពដើម្បីកុមារ ៧១នាក់ (ករណី ជួញដូរកម្មពលកម្ម ៦៩នាក់ រំលោភផ្លូវភេទ ១៥២នាក់ ជួញដូរផ្លូវភេទ ១៩នាក់ បៀតបៀនកេរ្តិ៍ភេទ ៤២នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៩នាក់ និងរៀបអាពិហ៍ពិពាហ៍ក្លែងក្លាយ ៥២នាក់)។

### ឃ.៤. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះឲ្យទៅតាមសហគមន៍វិញ សរុបចំនួន ៣៤៨នាក់ (ស្រី ២០៥នាក់) កុមារ ១៣៥នាក់ (កុមារី ៨៦នាក់) ក្នុងនោះមានៈ

- បានធ្វើសមាហរណកម្មជនរងគ្រោះ ជនរងគ្រោះដោយអំពើជួញដូរពលកម្មចំនួន ៨៥នាក់ (ស្រី ៧៥នាក់) កុមារ ០២នាក់ (កុមារី ០២នាក់) ដោយបានសហការជាមួយអង្គការរតនៈអ៊ិនធើណេសិនណលចំនួន ៣៣នាក់ និងអង្គាករដៃគូផ្សេងទៀត។
- មន្ទីរស.អ.យ រាជធានី-ខេត្ត បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅគ្រួសារ និងសហគមន៍វិញសរុបចំនួន ១១៤នាក់(ស្រី ៥១នាក់) កុមារ៦៣នាក់(កុមារី ៣២នាក់) ក្នុងនោះមានៈ មន្ទីរខេត្តស្វាយរៀង ៩៣នាក់ ខេត្តតាកែវ ១២នាក់ និងខេត្តកំពង់ធំ ០៩នាក់ (ករណីជួញដូរកម្លាំងពលកម្ម ៩៣នាក់ ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ១៣នាក់ និងករណីជួញដូរផ្លូវភេទ ០៩នាក់)។
- អង្គការក្រៅរដ្ឋាភិបាល ដែលជាដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍សរុបចំនួន ១៤៩នាក់(ស្រី ៧៩នាក់) កុមារ ៧០នាក់(កុមារី ៥២នាក់) ក្នុងនោះមានៈ អង្គការរតនៈអ៊ិនធើណេសិនណល ២១នាក់ (សហការជាមួយមន្ទីរខេត្តកណ្តាល ០១នាក់) អង្គការក្តីសង្ឃឹម និងយុត្តិធម៌ ០៤នាក់ អង្គការមេត្រីអន្តរជាតិ ១៧នាក់ អង្គការស្ទួននៃក្តីសង្ឃឹម ៤៩នាក់ អង្គការសង្គ្រោះ និងថែទាំស៊ីជីកញ ០៤នាក់ អង្គការសង្គ្រោះជោគវាសនាកម្ពុជា ៣៧នាក់ អង្គការមូនិធិហាការ ០៤នាក់ និងអង្គការតំណក់ទឹក ១៣នាក់ (ករណីរំលោភបំពានផ្លូវភេទ ២៥នាក់ ជួញដូរផ្លូវភេទ ២៤នាក់ ជួញដូរកម្លាំងពលកម្ម

២៧នាក់ ជួញដូរមនុស្ស ២៨នាក់ រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ២៩នាក់ និងករណីរំលោភបំពានផ្លូវភេទ ១៦នាក់)។

**ការបញ្ជូនពលករត្រឡប់ពីប្រទេសថៃ៖**

នៅមានចំណុចសេសសល់ មួយចំនួនទៀត គឺការតាមដាន ស្ថិតិនៃការបញ្ជូនត្រឡប់ ក្នុងនោះ ៖

<u>ស្ថិតិពលករ ដែលអាជ្ញាធរបរទេសបានចាប់បញ្ជូនមកវិញតាមច្រកព្រំដែន</u>

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសចំនួន១៩ប្រទេស បញ្ជូនត្រឡប់មកកម្ពុជាវិញ មានចំនួន **២៤.៥៩៣**នាក់ (ស្រី ៨.៥១៥នាក់ កុមារ **២.១៦៩**នាក់)មាន៖
  - តាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ **៧១៥**នាក់
  - តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ មានចំនួនសរុបមនុស្ស **២៣.៨៧៨**នាក់ (ស្រី **៨.២១០** នាក់ កុមារ **២.១៦៦**នាក់)។
  - ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម មនុស្ស **៤៩**នាក់ (ស្រី **៣៦**នាក់) និងមកពីប្រទេសផ្សេងទៀតមាន(កូរ៉េខាងត្បូង **៨៣**នាក់ ម៉ាឡេស៊ី **៥៨**នាក់ ជប៉ុន **២៨**នាក់ ចិន **៥៦**នាក់ និងសឹង្ហបូរី **៦០**នាក់...)។
- **សាកសពដែលបញ្ជូនត្រឡប់តាមច្រកអន្តរជាតិ** ក្នុងខេត្ត បាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ និងតាមទីចាត់ការព្រំដែន សរុប **១២០**នាក់។
- **ទីចាត់ការទំនាក់ទំនងការងារព្រំដែន អគ្គបញ្ជាការដ្ឋាន** សហការជាមួយស្ថាប័នច្រកទ្វារទទួលសាកសពប្រជាពលរដ្ឋកម្ពុជាពីប្រទេសថៃៈមានចំនួន**១០៩លើក** សរុប**១១៦នាក់(ស្រី១៨នាក់)**

**របាយការណ៍ពីស្ថានភាព ៖**

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

ស្នងការដ្ឋាននគរបាលខេត្ត ចំនួន៤ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាត់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៩៤០លើក មនុស្សសរុបចំនួន ២៨.៤៤០នាក់ (ស្រី ១០.០៩៩នាក់) អនីតិជន ២.៥១៤នាក់ (ស្រី ១.០២៧នាក់) ៖

+តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ៩៣៥លើក មនុស្សចំនួន ២៨.៣៥៨នាក់ (ស្រី ១០.០៤៣នាក់) អនីតិជន ២.៤៦៤នាក់ (ស្រី ៩៩៩នាក់)៖

  - ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ ចំនួន **៦៩៩**លើក មនុស្សចំនួន **២៥.៥៤៩**នាក់ (ស្រី **៨.៩៧៩**នាក់) អនីតិជន **២.៤០៥**នាក់ (ស្រី **៩៩៩**នាក់) ក្នុងនោះមានពលរដ្ឋខ្មែរចំនួន **៧៧៥**នាក់ (ស្រី **៣១**នាក់) ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែ មុននឹងបញ្ជូនមកកម្ពុជាវិញ។
  - ស្នងការដ្ឋាននគរបាលខេត្ត បាត់ដំបង **១២២**លើក មនុស្សចំនួន **១.៣៧៨**នាក់ (ស្រី **៦៧០**នាក់) អនីតិជន **៥៥**នាក់។
  - ស្នងការដ្ឋាននគរបាលខេត្ត កោះកុង **០៥**លើក មនុស្សចំនួន **៥៦**នាក់(ស្រី **២៥**នាក់) អនីតិជន **០៤**នាក់។
  - ស្នងការដ្ឋាននគរបាលខេត្ត ប៉ៃលិន **១០៩**លើក មនុស្សចំនួន **១.៣៧២**នាក់ (ស្រី **៥៥១**នាក់)។

+តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន០៥លើក មនុស្សចំនួន៨២នាក់ (ស្រី ៥៦នាក់) អនីតិជន ៥០នាក់ (ស្រី ២៨នាក់) ក្នុងនោះមាន៖

- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង **០៥លើក មនុស្សចំនួន ៨២**នាក់ (ស្រី **៥៦**នាក់)អនីតិជន **៥០**នាក់ ស្រី**២៨**នាក់។

- អគ្គបញ្ជាការដ្ឋានទីចាត់ការការងារព្រំដែន នៃក្រសួងការពារជាតិ បានសហការជាមួយស្ថាប័ន អាជ្ញាធរពាក់ព័ន្ធជាមួយមជ្ឈមណ្ឌលជំនួយផ្នែកចំណាកស្រុក អង្គការសោម៉ារីតាន់ភឹស និងអង្គការគេនៈអន្តរជាតិទទួល ពលករខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ សរុបចំនួន ២៧.៤៨១នាក់ (ស្រី ១១.៥៥១នាក់) កុមារ ២.៦៩៧នាក់។

## ការគ្រប់គ្រងជនបរទេស៖

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មានវិធានការគ្រប់គ្រងជនបរទេស ដែលស្នាក់នៅ និងធ្វើការខុសច្បាប់នៅកម្ពុជា** និងបានអនុវត្ត ដូចខាងក្រោម ៖

១. **ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:** ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជាចំនួន **៥៣៥**នាក់ ស្រី**៤៥**នាក់ មាន **៤២**សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖
   - អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបណ្តេញចេញចំនួន **៣១៤**នាក់ ស្រី **១៧**នាក់មាន **៤២**សញ្ជាតិ។
   - បានបណ្តេញចេញដោយការិយាល័យអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន មានជនជាតិវៀតណាម **១០**នាក់ ក្រៅពីនោះជនសង្ស័យដែលនៅសល់ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីធ្វើការបណ្តេញបន្ត។
   - បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន **៦៨**លើក មនុស្សចំនួន **២០៧**នាក់ ស្រី **២៨**នាក់។

២. **កំណត់បទល្មើសស្នាក់នៅខុសច្បាប់** សរុបមានមនុស្សចំនួន **១១០**នាក់ ស្រី **២៦**នាក់ និងមាន **១៩**សញ្ជាតិដែលចែកជា៖
   - **ករណីលួចឆ្លងដែនខុសច្បាប់** មានមនុស្សចំនួន **២១**នាក់ ស្រី **០៦**នាក់ **០២**សញ្ជាតិ (វៀតណាម **១៨**នាក់ និងថៃ **០៣**នាក់)។
   - **ស្នាក់នៅខុសច្បាប់** មានមនុស្ស **១៣**នាក់ ស្រី **០៤**នាក់ និងមាន **១០**សញ្ជាតិ (មានជនជាតិវៀតណាម **០៣**នាក់ បារាំង **០២**នាក់ ឥណ្ឌា **០១**នាក់ អង់គ្លេស **០១**នាក់ សឹង្ហបុរី **០១**នាក់ រ៉ូម៉ានី **០១**នាក់ ឈីលី **០១**នាក់ មីយ៉ាន់ម៉ា **០១**នាក់ រុស្ស៊ី **០១**នាក់ និងអូស្ត្រាលី **០១**នាក់)។
   - **ស្នាក់នៅគ្មានលិខិតឆ្លងដែន** មានមនុស្ស **០៣**ក់ មាន **០៣**សញ្ជាតិ(មានជនជាតិឥណ្ឌា អូស្ត្រាលី និងអ៊ីតាលី)។

- **ស្នាក់នៅហួសទិដ្ឋាការ** មនុស្ស ១៣នាក់(ស្រី ០១នាក់) **០៧**សញ្ជាតិ (អ៊ីរ៉ង់ ០២នាក់ កូរ៉េ ០១នាក់ អៀកឡង់ ០១នាក់ កូរ៉េ ០១នាក់ នីហ្សេរីយ៉ា ០៤នាក់ សឹង្ហបុរី ០២នាក់ និង អង់គ្លេស ០២នាក់)។
- **ស្នាក់នៅលើសទិដ្ឋាការ** មានមនុស្ស ១០នាក់ មាន ០៤សញ្ជាតិ (មានជនជាតិ នីហ្សេរីយ៉ា ០៧នាក់ អ៊ុយក្រែន ០១នាក់ អ៊ីតាលី ០១នាក់ និងចិនដីគោក ០១នាក់)។
- **ករណីលិខិតឆ្លងដែនគ្មានសុពលភាព** មនុស្ស ០១នាក់ សញ្ជាតិអាមេរិក។
- **ការប្រើប្រាស់ឯកសារក្លែងក្លាយ** មានមនុស្ស ០២នាក់ មាន ០២សញ្ជាតិ (ជនជាតិណាមីប៊ី និងឥណ្ឌា)។
- គ្មានឯកសារគ្រប់គ្រាន់ មនុស្សចំនួន **៣៦**នាក់ ស្រី **១៣**នាក់ សញ្ជាតិវៀតណាម។
- គ្មានឯកសារស្នាក់នៅ មនុស្សចំនួន **០៥**នាក់ មាន **០៣**សញ្ជាតិ (ឥណ្ឌា **០១**នាក់ ចិន **០២**នាក់ និងនីហ្សេរីយ៉ា **០២**នាក់)។
- គ្មានប័ណ្ណការងារ មនុស្សចំនួន **០៦**នាក់ ស្រី **០២**នាក់ សញ្ជាតិចិន។

៣. <u>ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី</u>

សរុបមកដល់ពេលបច្ចុប្បន្ន លទ្ធផលការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជា ពីជនបរទេសកំពុងប្រើប្រាស់មិនប្រក្រតីសរុបចំនួន **២៨.៨៤៥**ឯកសារ លើ **១៧.៥០០**គ្រួសារ មានចំនួនមនុស្ស **៦២.០២០**នាក់ (ស្រី **៤.៩៨៣**នាក់) មាន ០៤សញ្ជាតិ។

## III. ការលើកកម្ពស់សមត្ថភាពដឹកនាំ និងអនុវត្ត

### ក. <u>ក្នុងប្រទេស</u>

#### ក.១. <u>ការបណ្តុះបណ្តាលក្នុងប្រទេស</u>

ក្នុងរយៈពេល ១០ខែនេះ មានក្រសួង ស្ថាប័នអនុវត្តន៍ និងលេខាធិការដ្ឋានរាជធានី-ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ ដូចមានតារាងលម្អិតខាងក្រោម និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន **១២៤**វគ្គ មានសិក្ខាកាមចូលរួមចំនួន **៣.៣២៣**នាក់ ក្នុងនោះមានស្ត្រី **១.៥៧៥**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក ៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ក្រសួង ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ក្នុងការអនុវត្តគោលនយោបាយអប់រំ បណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ(TVET Policy) ឆ្នាំ២០១៧-២០២៥ និងការទទួលស្គាល់សមត្ថភាពជំនាញពលករ ដែលត្រឡប់មកមាតុភូមិវិញ ក្រសួងបានសហការជាមួយអង្គការ MOI បានជ្រើសរើសសិក្ខាកាម ធ្វើការបណ្តុះបណ្តាលទាំងទ្រឹស្តី ទាំងការអនុវត្តជាក់ស្តែងផ្នែកបដិសណ្ឋារកិច្ច នៅសាលាបណ្តុះ បណ្តាលបច្ចេកទេស Paul Dudrule ខេត្តសៀមរាប រយៈពេល៣ខែ និងត្រូវបន្តហ្វឹកហាត់ការងារជាក់ស្តែងនៅប្រទេសថៃរយៈពេល៣ខែទៀត។ | ០២ | ២០ | ០០ |
| ២ | **ក្រសួងកិច្ចការនារី** បានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាគគ្រូបង្គោលថ្នាក់ភូមិ ថ្នាក់តំបន់ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានានៅក្នុងខេត្តរតនគិរី បាត់ដំបង និងខេត្តកំពត ដែលមានសមាសភាពចូលរួមមកពីស្រុក/ខេត្ត និងក្រុម | ០៤ | ១៦៨ | ១៣៩ |

| | | | | |
|---|---|---|---|---|
| | ប្រឹក្សាសង្កាត់/ឃុំ ទាំង១៨ខេត្តមាន ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ព្រះវិហារ កំពង់ធំ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ពោធិ៍សាត់ កោះកុង ព្រះសីហនុ កំពត កែប តាកែវ និងកំពង់ស្ពឺ និងមន្ទីរកិច្ចការនារីទាំង២៥រាជធានី-ខេត្ត។ | | | |
| ៣ | **ក្រសួងអប់រំ យុវជន និងកីឡា ៖**<br>- បានសហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ បានរៀបចំបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយវគ្គខ្លីស្តីពីជំនាញទន់គន្លឹះនៃការស្វែងរកការងារ ក្នុងការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**លោកជំទាវ សឿ សុជាតា** មានខេត្តកោះកុង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តព្រៃវែង មានសិក្ខាកាមចូលរួមចំនួន៤៥នាក់។<br>- សហការជាមួយក្រសួងសុខាភិបាល និងអង្គការ UNICEF ដើម្បី បង្កើតសៀវភៅ ស្តីពីការថែទាំសុខភាពសម្រាប់កុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ និងបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលនៅតាមគ្រឹះស្ថានសុខាភិបាលចំនួន៤៥ ដើម្បីប្រើប្រាស់សៀវភៅនេះ ដូចជាបណ្តុះបណ្តាល៖<br>• គ្រូឧទ្ទេស ថ្នាក់ជាតិអំពីសៀវភៅស្តីពីការថែទាំសុខភាពកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភ បំពានផ្លូវភេទមកពីក្រសួងពាក់ព័ន្ធរួមមាន៖ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច ក្រសួងសុខា ភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានចំនួន២០នាក់។<br>• សាកល្បង ជាមួយបុគ្គលិកមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពចំនួន៥ ក្នុងខេត្តក្រចេះ សរុប២០នាក់។<br>• គ្រូឧទ្ទេសថ្នាក់ខេត្តចំនួន១២នាក់ក្នុងខេត្តគោលដៅមាន ខេត្តក្រចេះ និងរតនគីរី បានប្រព្រឹត្ត។<br>• ដល់គ្រូពេទ្យ និងបុគ្គលិកមន្ទីរពេទ្យពីមណ្ឌលសុខភាពចំនួន៤៥ និងមន្ទីរពេទ្យបង្អែកចំនួន២ក្នុងខេត្តក្រចេះ និងរតនគីរីកំពុងដំណើរការ។ គ្រូពេទ្យ និងមន្ត្រីសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលបានចាប់ផ្តើមអនុវត្តខ្លឹមសារនៅក្នុងសៀវភៅ ស្តីពីការថែទាំសុខភាពកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពានផ្លូវភេទជាបណ្តើរៗជាមួយនឹងការពិនិត្យតាមដានពីសំណាក់មន្ត្រីរបស់ក្រសួងសុខាភិបាលនៅថ្នាក់ជាតិក្រោមការគាំទ្រពីអង្គការយូនីសេហ្វ។ | ០៨ | ៩៧ | ០០ |
| ៤ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំបើកវគ្គបណ្តុះបណ្តាលលើគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលមានសិក្ខាមចូលរួមមកពី៖ មន្ត្រីស.អ.យ មន្ត្រី គ.ក.ន.ក មន្ត្រីថ្នាក់ស្រុក(មេឃុំ-មេភូមិ) គ្រូបង្រៀន និងនគរបាលប៉ុស្តិ៍ នៃខេត្តព្រៃវែង និងខេត្តកំពង់ធំ។ | ០២ | ៩៣ | ២៥ |
| ៥ | **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចាត់បញ្ជូនអគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីចូលរួមជាគ្រូបង្គោល ក្នុងវគ្គបណ្តុះ បណ្តាលបំប៉នជំនាញប្រឆាំងអំពើជួញដូរមនុស្ស ជូនដល់៖<br>- នាយនគរបាលប៉ុស្តិ៍រដ្ឋបាល នៃអធិការដ្ឋាននគរបាល ក្រុងតាខ្មៅ នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល អ្នកចូលរួមចំនួន៣២នាក់ ស្រី០៨នាក់។<br>នាយនគរបាលប៉ុស្តិ៍រដ្ឋបាល នៃអធិការដ្ឋាននគរបាល ខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ អ្នកចូលរួមចំនួន៣០នាក់ ស្រី០៦នាក់។ | ០២ | ៦២ | ១៤ |
| ៦ | **អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតជន**<br>- បានសហការជាមួយអង្គការ(AIM SWAT) បានបើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ចំនួន០២វគ្គ។ | ០៤ | ៨០ | ១៣ |

| | | | | |
|---|---|---|---|---|
| | - ខេត្តឧត្តរមានជ័យ បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជាដល់ជនបង្គោលទាំង៥ក្រុង/ស្រុក។ | ០១ | ១៤៣ | ៤៦ |
| ៧ | **ខេត្តបន្ទាយមានជ័យ លេខាធិការ គ.ខ.ប.ជ** បានបើកវគ្គបណ្តុះបណ្តាលៈ<br>- ពង្រឹងសមត្ថភាពដល់ជនបង្គោល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាស ភាពចូលរួមមកពី៩ក្រុង/ស្រុក មានក្រុង(ប៉ោយប៉ែត. សេរីសោភ័ណ) និងស្រុក (ថ្មពួក ស្វាយចេក .អូរជ្រៅ .ម៉ាឡៃ .ព្រះនេតព្រះ .ភ្នំស្រុក និងស្រុកមង្គលបូរី) ។<br>- ស្តីពីសិទ្ធិស្ត្រី ការធ្វើចំណាកស្រុកដោយស្របច្បាប់ និងសុវត្ថិភាព និងអំពើជួញដូរមនុស្ស ចំនួន៦វគ្គ នៅក្នុងសង្កាត់ទាំងបីនៃក្រុងប៉ោយប៉ែត ស្រុកព្រះនេត្រព្រះ ស្រុកស្វាយចេក និងស្រុកមង្គលបូរី។ | ៣២ | ៤៨៣ | ២៤៩ |
| ៨ | **ខេត្តបាត់ដំបង លេខាធិការ គ.ខ.ប.ជ ៖**<br>- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីទេសន្តរប្រវេសន៍ និងសមភាពយេនឌ័រដល់អាជ្ញាធរក្រុង/ស្រុក ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការដៃគូនានា ក្នុងខេត្ត នៅសាលប្រជុំវិទ្យាស្ថានជាតិ បណ្តុះបណ្តាលបច្ចេកទេសខេត្ត។<br>- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន០២វគ្គ នៅឃុំសំរោងស្រុកឯកភ្នំ និងឃុំត្រែងស្រុករតនមណ្ឌល។<br>- បានសហការជាមួយអង្គការការីតាស កម្ពុជាបើកវគ្គបណ្តុះបណ្តាលជនបង្គោល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន០៦វគ្គ នៅស្រុកសំពៅលូន ភ្នំព្រឹក កំរៀង សំឡូត គាស់ក្រឡ និងស្រុករុក្ខគិរី ។<br>- បើកវគ្គបណ្តុះបណ្តាល ស្តីលក្ខខណ្ឌការងារ និងសន្តិសុខការងារ នៃសហគ្រាសគ្រឹះស្ថាន និងក្រុមហ៊ុនផ្នែកសេវាកម្មប្បន្ត។ | ១១ | ៣៧០ | ១៥៩ |
| ៩ | **ខេត្តសៀមរាប គណៈកម្មាធិការ គ.ខ.ប.ជ**<br>- បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្ត និងអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល(GVC) បើកវគ្គបណ្តុះបណ្តាល ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកំណត់អត្តសញ្ញាណជនរងគ្រោះ កិច្ចការពារកុមាររងាយរងគ្រោះ ការរំលោភបំពានផ្លូវភេទលើ អនីតិជន ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជំនាញស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ការសង្គ្រោះចិត្តសាស្ត្របឋម និងសមាហរណកម្មសង្គម។<br>- គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពដល់ លេខាធិការដ្ឋានលើការរៀបចំផែនការសកម្មភាព រយៈពេល៥(២០១៩-២០២៣) អ្នកចូលរួមចំនួន៨៥នាក់ ស្រី៤៤នាក់។<br>- សហការជាមួយអង្គការ IOM បើកវគ្គបណ្តុះបណ្តាល អំពីការសង្គ្រោះចិត្តសាស្ត្របឋម និងការត្រៀមខ្លួនរបស់សហគមន៍សម្រាប់ជួយដល់ជនរងគ្រោះ ដោយការជួញដូរមនុស្ស និងជនដែលងាយរងគ្រោះ ដល់ក្រោមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន២៥នាក់។<br>- អង្គការFriend International វគ្គបណ្តុះបណ្តាលចំនួន០៤វគ្គៈ<br>○ ស្តីពីការពង្រឹងសមត្ថភាពភ្នាក់ងារសុវត្ថិភាពកុមារ ដល់បុគ្គលិក អ្នកចូលរួម ចំនួន៣២នាក់។<br>- ស្តីពីការលើកកម្ពស់កិច្ចការពារកុមារ (អាហារដ្ឋាន, អ្នករត់ម៉ូតូរម៉កកង់បីអ្នកលក់បន្លែផ្លែឈើ) អ្នកចូលរួមចំនួន២៦នាក់។ | ២២ | ៣០០ | ៧៩ |
| ១០ | **ខេត្តកំពង់ធំ គណៈកម្មាធិការ គ.ខ.ប.ជ** បានសហការជាមួយអង្គការវិនរ៉ុក និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បើកវគ្គបណ្តុះបណ្តាលស្តីពីៈ | ១៣ | ៣៨៤ | ១៣៩ |

| | | | | |
|---|---|---|---|---|
| | - ពង្រឹងសមត្ថភាពជនបង្គោល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០៨វគ្គ<br>- វិធីសាស្ត្រនៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ចំនួន ០៥វគ្គ។ | | | |
| ១១ | **ខេត្តព្រះសីហនុ ៖**<br>- មន្ទីរទេសចរណ៍ខេត្ត បានបើកវគ្គបណ្តុះបណ្តាលៈ<br>• ស្តីពីបដិសណ្ឋារកិច្ច សេវាកម្មអាហារ និងភេសជ្ជៈ ចំនួន០២ថ្ងៃ នៅភូមិកោះតូច សង្កាត់កោះរ៉ុងសន្លឹម ក្រុង-ខេត្តព្រះសីហនុ។<br>• ស្តីពីច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់ប្រតិបត្តិករទេសចរណ៍ និង វិនិយោគិន ទេសចរណ៍ចិន បញ្ហាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ទេសចរណ៍ផ្លូវភេទ។<br>- ប្រធានលេខាធិការដ្ឋាន បានសហការជាមួយ មន្ទីរកិច្ចការនារី ស្នងការដ្ឋាននគរបាលខេត្ត និង អង្គការដៃគូ បើកវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពយល់ដឹងអំពីច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ ។<br>- ក្រុមការងារលេខាធិការដ្ឋាន បានសហការជាមួយ មន្ទីរទេសចរណ៍ខេត្ត បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដោយបានបញ្ជ្រាបការងារយេនឌ័រ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ដល់បុគ្គលិកបម្រើការងារនៅតាម កាស៊ីណូ ភោជនីយដ្ឋាន និងអាហារចិនមួយចំនួន ក្នុងខេត្តព្រះសីហនុ។ | ២៥ | ៩៩៧ | ៥៦៨ |
| ១២ | **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តមណ្ឌលគិរី** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ០១ | ៥០ | ២៦ |
| ១៣ | **ខេត្តក្រចេះ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានបើកវគ្គបណ្តុះបណ្តាលៈ<br>- ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ។<br>- ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ។ | ០៧ | ៣៦០ | ២៦៥ |
| ១៤ | **ខេត្តរតនគិរី មន្ទីរកិច្ចការនារី** បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ។ | ០១ | ៤៨ | ៤៧ |
| ១៥ | **ខេត្តព្រៃវែង** ប្រធានលេខាធិការ គ.ខ.ប.ជ ខេត្ត/ស្រុក មន្ទីរសង្គមកិច្ច និងមន្ទីរកិច្ចការនារី បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃបើកវគ្គបណ្តុះបណ្តាលដល់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការធ្វើចំណាកស្រុកខុសច្បាប់នៅសាលាស្រុក(ស្វាយអន្ទរ ព្រះស្តេច និងស្រុកព្រះស្តេច) ។ | ០២ | ៥៣ | ០០ |
| ១៦ | **ខេត្តស្វាយរៀង** ប្រធានលេខាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយៈ<br>- អង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាលលើប្រធានបទ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើរំលោភបំពានផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។<br>- ក្រុមហ៊ុនចំនួន ១៦ នៅតាមតំបន់សេដ្ឋកិច្ចពិសេសនានា ក្នុងខេត្តបើកវគ្គបណ្តុះបណ្តាលដល់កម្មករ និយោជិក ស្តីពីសុវត្ថិភាពការងារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការសង្គ្រោះបឋម ការធ្វើ អនាម័យដើម្បីសុខភាព ការគ្រប់គ្រងសារធាតុគីមី ការការពារជំងឺអេដស៍ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ផ្លូវគោកចំនួន៦២វគ្គ។ | ៦៣ | ១.២៧៦ | ៧៤៤ |
| ១៧ | **ខេត្តកំពង់ស្ពឺ** បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សលើការផ្តល់សេវាសមស្រប នៅថ្នាក់ខេត្ត។ | ០១ | ៣៨ | ១៨ |
| ១៨ | **ខេត្តកំពត** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុក និងការស្វែងរកការងារធ្វើប្រកបដោយសុវត្ថិភាព និងស្របច្បាប់។ | ០២ | ៧០ | ២០ |

| សរុប | ១២៤ | ៣.៣២៣ | ១.៥៧៥ |
|---|---|---|---|

ក.២. សិក្ខាសាលា

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអង្គការ ILO-Triagle បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់៖
  - ដើម្បីធ្វើបច្ចុប្បន្នភាពគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់កម្ពុជា ឆ្នាំ២០១៩-២០២៣ កាន់តែមានសុក្រឹតភាព ដែលមានសមាសភាពចូលរួមមកពីគ្រប់ភាគីពាក់ព័ន្ធ ចំនួន ១២០នាក់។ គោលនយោបាយនេះ នឹងត្រូវប្រកាសផ្សព្វផ្សាយ ដាក់ឲ្យអនុវត្តជាផ្លូវការណ៍នៅថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៨ ខាងមុខនេះ។
  - ដើម្បីប្រមូលធាតុចូលជាចុងក្រោយពី បណ្តាក្រសួង ស្ថាប័ន សហជីព និយោជក អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធសម្រាប់រៀបចំចងក្រងឯកសារគោលការណ៍ណែនាំ ស្តីពីយន្តការទទួលពាក្យបណ្តឹង និងដោះស្រាយវិវាទ ទាក់ទងនឹងទេស្តរប្រវេសន៍ការងារ។
  - ថ្នាក់ជាតិ ត្រៀមសម្រាប់វេទិកាអាស៊ានលើកទី១១ ស្តីពីពលករទេស្តរប្រវេសន៍ ក្រោមប្រធានបទការ ប្រើប្រាស់ប្រព័ន្ធឌីជីថល ក្នុងការលើកកម្ពស់សមម្យ សម្រាប់ពលករទេស្តរប្រវេសន៍ នៅក្នុងក្រប ខណ្ឌអាស៊ាន ដោយផ្តោតសំខាន់លើ៖(១) ការ ប្រើប្រាស់ប្រព័ន្ធឌីជីថល សម្រាប់គ្រប់គ្រងពលករទេស្តរប្រវេសន៍ (២)សេវាឌីជីថល សម្រាប់ពលករទេស្តរប្រវេសន៍។
- ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយ**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** និងអង្គការវីនរ៉ក់ អន្តរជាតិ បានរៀបចំសិក្ខាសាលា ស្តីពី ការពង្រឹងការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា ចំនួន ចំនួន ១០វគ្គ នៅក្រុង-ស្រុក ទាំង១០ ក្នុងក្រុងកំពង់ចាម មានសិក្ខាកាមចូលរួមចំនួន ៦០០នាក់ (ស្រី ១១៣នាក់)។
- **ក្រសួងទេសចរណ៍** បានរៀបចំសិក្ខាសាលា ស្តីពី "ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ មន្ទីរ អង្គភាព សមត្ថកិច្ច អាជ្ញាធរដែនដីពាក់ព័ន្ធ និងយុវជន នៅតាមបណ្តាខេត្តចំនួន ០៣ រួមមាន៖ ខេត្តពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង ក្នុងគោលបំណងដើម្បីចូលរួមលើកកម្ពស់ និងការទប់ស្កាត់ ការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ មានសិក្ខាកាមចូលរួមចំនួន ២២៨នាក់ (ស្រី ១០០នាក់)។
- **ខេត្តត្បូងឃ្មុំ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការស៊ីកាស្វា និងអង្គការក្លែនអន្តរជាតិប្រចាំខេត្ត បានរៀបចំសិក្ខាសាលា ស្តីពីការអនុវត្តល្អ និងការពង្រឹងនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី និងសេវាសង្គម សមាសភាពចូលរួមមាន៖ អភិបាលរង ស្នងការរង អធិការនគរបាលក្រុងស្រុកទាំង៧ ប៉ុស្តិ៍នគរបាលប្រចាំច្រកព្រំដែនវៀតណាម ប៉ុស្តិ៍នគរបាលឃុំទាំង ១២ ក្នុងស្រុកពញាក្រែក ស្រុកតំបែរ និងមន្ទីរពាក់ព័ន្ធនានា សរុបចំនួន ៧៩នាក់ (ស្រី ៣៣នាក់)។
- **ខេត្តកំពត** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសិក្ខាសាលា ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ដៃគូអនុវត្តន៍កម្មវិធីត្រីកោណ ក្នុងតំបន់អាស៊ាន មានសិក្ខាកាមចូលរួមចំនួន ១៩នាក់ (ស្រី ០៤នាក់)។

- **ខេត្តបាត់ដំបង** បានរៀបចំសិក្ខាសាលាៈ
    - ស្តីពីកិច្ចសហការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានសមាសភាពចូលរួមៈ អភិបាលរងក្រុង/ស្រុក ស្នងការដ្ឋាននគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត មន្ទីរទេសចរណ៍ខេត្ត មន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តអយ្យការអមសាលាដំបូងខេត្ត មជ្ឈមណ្ឌលការងារ អង្គការ IJM អង្គការ World Vision លោកមេឃុំ និង គ.ក.ន.ក និងអង្គការ ស្ថាប័នពាក់ព័ន្ធ សរុបចំនួន **៨៧**នាក់ ស្រី**៤៩**នាក់។
    - ផ្សព្វផ្សាយ ស្តីពីការប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន នានចំនួន ៣លើក មានអ្នកចូលរួមសរុប **១៤៥** នាក់ ស្រី **២២** នាក់។
- **ខេត្តស្វាយរៀង** បានសហការជាមួយអង្គការឆាលហ្វាន់កម្ពុជា រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ និងការជួញដូរគ្រឿងញៀន តាមបណ្តាគោលដៅទាំង១៣ នៅក្នុងស្រុកស្វាយជ្រំ និងស្រុករមាសហែក មានអ្នកចូលរួមសរុប **៨៣**នាក់ ស្រី **២៩**នាក់។

### ក.៣. ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៥០៨**លើក មានអ្នកចូលរួមសរុប **១៩.១៤៧**នាក់ (មានស្រី **៨.០១៣**នាក់) ក្នុងនោះ**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ** ចំនួន **១៩២**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ចំនួន **៦**លើក ក្រសួងអប់រំ យុវជន និងកីឡា **០៦**លើក ក្រសួងកិច្ចការនារី **១៥**លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន **៣៧**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **២៥២**លើក ។

## ខ. នៅក្រៅប្រទេស និងថ្នាក់អន្តរជាតិ

### ខ.១. វគ្គបណ្តុះបណ្តាល

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចាត់បញ្ជូននាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ចំនួន **០២**រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណៈរដ្ឋប្រជាមានិតចិន។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានចាត់បញ្ជូននាយនគរបាលចំនួន **០៧**រូប ដើម្បីទៅចូលរួម ៖
    - វគ្គបណ្តុះបណ្តាល ស្តីពី "**ឯកទេសប្រឆាំងនឹងការរត់ពន្ធមនុស្សខុសច្បាប់ និងការរត់ពន្ធជនអន្តោប្រវេសន៍**" (នៅប្រទេសសឹង្ហបុរី)។
    - វគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅប្រទេសចិន។
    - វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់សម្រាំង ដើម្បីបង្ក្រាបបទល្មើសលើកុមារ តាមប្រព័ន្ធ អ៊ិនធើណេត ប្រទេសថៃ។

- វគ្គបំប៉នការងារដឹកនាំសម្រាប់ថ្នាក់នាយកដ្ឋាន ស្នងការ និងការិយាល័យ ប្រទេសវៀតណាម។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ចំនួន ០២រូប ដើម្បីទៅចូលរួម៖
  - វគ្គបណ្តុះបណ្តាល ប្រតិបត្តិការគ្រប់គ្រងការធ្វើសមារណកម្ម ព្រំដែន ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។
  - វគ្គបណ្តុះបណ្តាលកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យព្រំដែនលើកទី១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- **ខេត្តកំពង់ធំ លេខធិការដ្ឋាន គ.ខ.ប.ជ** បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើកុមារវគ្គទី៧ នៅបណ្ឌិតសភា ILea ទីក្រុងបាងកង ប្រទេសថៃ។

ខ.២. <u>កិច្ចប្រជុំ និងសិក្ខាសាលា ជាអន្តរជាតិ</u>

- **គ.ជ.ប.ជ** បានរៀបចំកិច្ចប្រជុំទ្វេភាគី លើកទី២ កម្ពុជា-ចិន ដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ស្តីពីសហប្រតិបត្តិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរាជធានីភ្នំពេញ
- **គ.ជ.ប.ជ** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងប្រទេសបញ្ជូន ចំនួនបី ស្តីពីតួនាទីប្រទេសបញ្ជូន ក្នុងការលើកកម្ពស់សុវត្ថិភាពពលករក្នុងប្រទេសថៃ នៅរាជធានីភ្នំពេញ
- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បាន៖
  - ចូលរួមសិក្ខាសាលាការលើកកម្ពស់ការការពារសិទ្ធិពលករទេសន្តរប្រវេសន៍៖ ស្តីពីដំណើរការចុះបញ្ជី និងអ្នកគ្មានឯកសារ ប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ីលតុន ក្រុងបាងកក ប្រទេសថៃ។
  - ចូលរួមកិច្ចប្រជុំអង្គការសហប្រជាជាតិ ពិភាក្សាលើខ្លឹមសារកាតិកាសញ្ញា ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅប្រទេសម៉ិចស៊ិកកូ។
  - ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងបញ្ជូនមន្ត្រីជាន់ខ្ពស់ចូលរួមកិច្ចប្រជុំ របស់ Bali Process ស្តីពី ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។
  - តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៧ បាលីប្រូសេស(Bali Process) ស្តីពីការរត់ពន្ធ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន ពាក់ព័ន្ធ ប្រព្រឹត្តិទៅនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ដោយមានការចូលរួមពីថ្នាក់រដ្ឋមន្ត្រី តំណាងប្រទេសចំនួន ៤៦ នៅជុំវិញពិភពលោក។
  - បានដឹកនាំគណៈប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តកោះកុង ដើម្បីអញ្ជើញជួបពិភាក្សាការងារ ជាមួយអាជ្ញាធរខេត្តត្រាត ប្រទេសថៃ។
- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចាត់បញ្ជូននាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ចំនួន ០៣រូប ដើម្បីទៅចូលរួម៖

- កិច្ចប្រជុំ ស្តី Working conference of the six conutries joint action against human trafficking (Cambodia China, Laos, Myanmar, Thailand. Vietnam) នៅទីក្រុងគន់មិញ ខេត្តយន់ណាន សាធារណរដ្ឋប្រជាមានិតចិន។
- សិក្ខាសាលាគោលនយោបាយអនុតំបន់មេគង្គលើកទី២ ស្តីពី ភាពទៀងទាត់ និងការគ្រប់គ្រងទេសន្តប្រវេសន៍អាពាហ៍ពិពាហ៍ ដែលរៀបចំដោយអង្គការIOM នៅទីខេត្តគ័ងចូវ សាធារណរដ្ឋប្រជាមានិតចិន។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងថ្នាក់មន្ត្រីជាន់ខ្ពស់ជាមួយ៖
  - ភាគីថៃចំនួន ៦លើក ដើម្បីពិនិត្យ និងដោះស្រាយបញ្ហានានា ដែលកើតឡើង និងទប់ស្កាត់រាល់បញ្ហាទាំងនោះដែលកើតមានជាយថាហេតុ។
  - ភាគីម៉ាឡេស៊ីចំនួន ៣លើក ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី **ការគ្រប់គ្រងពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។**
  - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារ និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃរដ្ឋគូវ៉ែត ស្តីពី "**ការផ្លាស់ប្តូរវិស័យកម្លាំងពលកម្មរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត**" និងការ ស្វែងយល់អំពីឱកាសវិនិយោគ នៃរដ្ឋគូវ៉ែត នៅកម្ពុជា។

- **ក្រសួងកិច្ចការនារី លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានខមមីតកម្ពុជា** បានដឹកនាំប្រតិភូចំនួន ០៦រូប ស្រី ០៤រូប ដែលមានតំណាងទៅចូលរួមមាន ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា អង្គការ UN-ACT និងអង្គការរតនៈអន្តរជាតិ ស្តីពីការអនុវត្តច្បាប់ និងកិច្ចសម្របសម្រួលជនរងគ្រោះ និងកិច្ចប្រជុំខមមីតថ្នាក់តំបន់ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ ដើម្បីចូលរួម ៖
  - កិច្ចប្រជុំពិភាក្សាតុមូល ចែករំលែកបទពិសោធន៍ជំនាញទេសន្តរប្រវេសន៍អឺរ៉ុប (Magration EU Expertise) នៅប្រទេសថៃ។
  - កិច្ចប្រជុំវគ្គបណ្តុះបណ្តាលកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យព្រំដែនលើកទី១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
  - ចូលរួមសិក្ខាសាលា ស្តីពីគម្រោងនៅតំបន់អាស៊ីអាគ្នេយ៍ នៅកោះ PENANG ប្រទេសម៉ាឡេស៊ី។
- **ខេត្តមណ្ឌលគិរី៖** លោកឧត្តមសេនីយ៍ទោ ស្នងការនគរបាលខេត្ត បានដឹកនាំគណៈប្រតិភូ ចំនួន ០២លើក ដើម្បីចូលរួមប្រកិច្ចប្រជុំ បូកសរុបលទ្ធផលការងារសហប្រតិបត្តិការ ស្តីពីការរក្សាសន្តិសុខព្រំដែន និងការបង្ការ ទប់បទល្មើសផ្សេងៗ នៅបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនខេត្តដាក់ណុង ប្រទេសវៀតណាម។
- **ខេត្តស្វាយរៀង** បានចូលរួមកិច្ចប្រជុំ **ស្តីពីកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើស និងការការពារសន្តិសុខសណ្តាប់ធ្នាប់តាមតំបន់ព្រំដែន រវាងនគរបាលខេត្តតៃនិញនៃប្រទេសវៀតណាម និងស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ នៃព្រះរាជាណាចក្រកម្ពុជា នៅមន្ទីរនគរបាលខេត្តតៃនិញ ប្រទេសវៀតណាម។**

- **ខេត្តព្រះវិហារ** ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំថ្នាក់ខេត្តជាមួយខេត្តចំប៉ាសាក់ រដ្ឋធានីវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាមានិតឡាវ ស្តីពី**កិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើស និងការការពារសន្តិសុខសណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន ជាពិសេសពាក់ព័ន្ធការឆ្លងដែនខុសច្បាប់ និងអំពើជួញដូរមនុស្ស។**
- **ខេត្តកោះកុង** ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីនគរបាលថ្នាក់នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីទៅចូលរួមកិច្ចប្រជុំក្រុមលេខាធិការនៃគណៈកម្មាធិការភូមិភាគកម្ពុជា-ថៃ លើកទី២១ រវាងភាគីកម្ពុជា យោធភូមិភាគ៣ និងភាគីថៃ កងបញ្ជាការការពារព្រំដែនច័ន្ទបុរីត្រាត លើកទី២១ នៅខេត្តច័ន្ទបូរី ដែលមានការអញ្ជើញចូលរួមពីអង្គភាព និងមន្ទីរពាក់ព័ន្ធក្នុងខេត្ត។ អង្គប្រជុំបានលើកឡើងនៅចំណុចរួមមួយ គឺរួមគ្នាបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសការជួញដូរមនុស្សរវាងប្រទេសទាំងពីរ ដើម្បីដាក់ជូនគណៈកម្មាធិការ ថ្នាក់ភូមិភាគ នៃប្រទេសទាំងពីរសម្រេច។

ខ.៣. <u>សន្និសីទ</u>

- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញចូលរួមសន្និសីទអន្តរជាតិរវាងកម្ពុជា-ថៃ៖ ការធ្វើទេសន្តរប្រវេសន៍ការងារ និងអំពើជួញដូរមនុស្ស និងបានផ្តល់បទបង្ហាញអំពីក្របខណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជា នៅក្នុងប្រទេសថៃ ប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ីលតុន ទីក្រុងបាងកក ប្រទេសថៃ។
- **ក្រសួងកិច្ចការនារី** បានចូលរួមសន្និសីទអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាងថៃ-កម្ពុជា ស្តីពី **ពលករទេសន្តរប្រវេសន៍នៅទីក្រុងបាងកក ប្រទេសថៃ** ដែលមានតំណាងចូលរួមមាន៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងអង្គការគាំទ្រផ្នែកច្បាប់ដល់កុមារ និងស្ត្រី(LSCW) រៀបចំដោយគ្រោង MIG-GIGHTS របស់អង្គការក្រុមអ្នកស្ម័គ្រចិត្តអ៊ីតាលី(GVC)។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានចាត់បញ្ជូននាយនគរបាលជាន់ខ្ពស់ ចំនួន **០២**រូប ដើម្បីទៅចូលរួមសន្និសីទ ស្តីពីការប្រយុទ្ធប្រឆាំងអំពើភេរវកម្មអាស៊ាន នៃប្រទេសសឹង្ហបុរី។
- **ខេត្តសៀមរាប** លោកស្រីប្រធានលេខាធិការ គ.ខ.ប.ជ បានចូលរួមសន្និសីទអន្តរជាតិ ស្តីពី **ការធ្វើទេសន្តរប្រវេសន៍ការងាររបស់ពលករកម្ពុជានៅក្នុងប្រទេសថៃ និងអំពើជួញដូរមនុស្សនៅទីក្រុងបាងកក ប្រទេសថៃ។**

ខ.៤. <u>ទស្សនកិច្ច</u>

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋឥណ្ឌា ដែលក្នុងដំណើរទស្សនកិច្ចនោះ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាតំណាងដ៏ខ្ពស់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយភាគីឥណ្ឌានូវ "**អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស**"។

- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានអញ្ជើញបំពេញទស្សនកិច្ចនៅរដ្ឋធានីវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អមដំណើក្នុងពេលនោះមាន **ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍** និងប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ផងដែរ។
- **ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងដំណើរទស្សនកិច្ចការងារ ខេត្ត KHANH HOA នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញចូលរួមទស្សនកិច្ចតាមក្រុមហ៊ុនសំណង់ក្នុងខេត្តច័ន្ទបូរី (រៀបចំដោយសមាគមពលករខ្មែរ-ថៃ) និងនៅសហគមន៍គ្រួសារទេសន្តរប្រវេសន៍ខ្មែរ នៅខេត្តសមុទ្រប្រាកាន ប្រទេសថៃ (រៀបចំដោយអង្គការ LPN) ដើម្បីស្វែងយល់ពីសុខទុក្ខពលករ ពលការិនីកម្ពុជា ក្នុងប្រទេសថៃ។
- **ក្រសួងកិច្ចការនារី** បានទៅចូលរួមទស្សនកិច្ច ផ្លាស់ប្តូរបទពិសោធន៍ និងសន្និសីទអន្តរជាតិ រវាងថៃ-កម្ពុជា នៅទីក្រុងបាងកក ប្រទេសថៃ មានតំណាងរបស់ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី ទៅចូលរួម។
- **ខេត្តបាត់ដំបង** បានចូលរួមទស្សនកិច្ចអន្តរជាតិសម្រាប់ការពិភាក្សារវាងប្រទេសកម្ពុជា និងប្រទេសថៃ ស្តីពី**បញ្ហាការជួញដូរមនុស្ស និងការចំណាកស្រុក នៅទីក្រុងបាងកក ប្រទេសថៃ។**

២.៥. <u>ជាវាគ្មិន</u>

- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាជាសាធារណៈ អំពីបទបញ្ញត្តិនានា និងគោលនយោបាយរវាងកម្ពុជា-ថៃ លើបញ្ហាការជួញដូរមនុស្ស និងពលករអន្តោប្រវេសន៍ នៅមូលនិធិ SEA Junction នៅទីក្រុងបាងកក ប្រទេសថៃ។

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

- ការគាំទ្ររបស់រាជរដ្ឋាភិបាល ចំពោះសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ដែលត្រូវបានចាត់ទុកថាជាការងារអាទិភាពមួយដ៏សំខាន់ដែលត្រូវយកចិត្តទុកដាក់ បានបើកផ្លូវឲ្យមានដំណោះស្រាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយថ្នាក់តំបន់ និងសកលលោក។
- ក្រសួងស្ថាប័នពាក់ព័ន្ធនានា ក្នុងរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ គោលការណ៍ ផែនការសកម្មភាព និងបទដ្ឋានការងារជាច្រើន ដើម្បីរួមគ្នាធ្វើសកម្មភាពបង្ការ ទប់ស្កាត់ ការពារ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឲ្យកាន់តែមានប្រសិទ្ធភាព។
- កិច្ចសហការ និងការឯកភាពគ្នាក្នុងការធ្វើប្រតិបត្តិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានផ្តល់នូវភាពខ្លាំងក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស ឲ្យបានជោគជ័យ ។

- អនុសាសន៍ដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតែជាត្រីវិស័យសម្រាប់តម្រង់ទិសការងារគណៈកម្មាធិការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។
- ការចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិនានា ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។ បានផ្តល់នូវការយោគយល់គ្នា និងកិច្ចសហការល្អ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាបានដោយរលូន ។
- យន្តការជាតិ ដែលមានរចនាសម្ព័ន្ធទូលំទូលាយ ច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងការចូលរួមពីអង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិដទៃទៀត បានក្លាយជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។

## ខ. ចំណុចខ្វះខាត និងភាពប្រឈម

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន នៅមិនទាន់មានកិច្ចសហការល្អគ្រប់គ្រាន់ មិនទាន់បើកទូលាយ មិនទាន់បង្កលក្ខណៈ និងផ្តល់ធនធានសម្រាប់ប្រតិបត្តិការ និងមិនទាន់មានលក្ខណៈជាប្រព័ន្ធ ដែលអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាបាន។
- ក្រសួង ស្ថាប័ន ឬអង្គភាពជាសមាជិកខ្លះ មិនបានផ្តល់របាយការណ៍ដែលបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័ន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបាន និងកំពុងប៉ះពាល់ដល់ដំណើរការនៃការអភិវឌ្ឍជាតិ តាមវិស័យទាំងនោះឡើយ។
- មន្ត្រីទទួលបន្ទុកនៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមិនទាន់យល់ច្បាស់ពីការងារ និងតួនាទីភារកិច្ច ជាសមាជិកគណៈកម្មាធិការជាតិ ដែលត្រូវរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗ។
- របាយការណ៍ដែលផ្ញើមកអគ្គលេខាធិការដ្ឋាន តែងតែយឺតយ៉ាវ មិនទាន់ពេលវេលា ។

## គ. សំណូមពរ

- ត្រូវការការជំរុញ និងពង្រឹងបន្ថែមពីប្រធានស្ថាប័នជាសមាជិក គ.ជ.ប.ជ គ្រប់កម្រិត អំពីរបៀបរបបការងារ ដើម្បីពង្រឹងទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងការធ្វើរបាយការណ៍ ស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងអនុក្រឹត្យ និងសេចក្តីសម្រេចពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់ក្រសួងស្ថាប័នជាសមាជិក ។
- ត្រូវការវគ្គបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ និងមន្ត្រីអនុវត្តន៍ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

- ត្រូវការឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ គួបផ្សំនឹងការគាំទ្រធនធានឲ្យបានសមស្រប ដើម្បីសម្រួលដល់ដំណើរការកិច្ចប្រតិបត្តិការ។

## ឃ. សន្និដ្ឋាន

- អាស្រ័យដោយមានការគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានធ្វើឲ្យសភាពការណ៍សន្តិសុខ សុវត្ថិភាព របស់ប្រជាពលរដ្ឋកម្ពុជា កាន់តែត្រូវបានយកចិត្តទុកដាក់ប្រសើរឡើង ។ ប្រជាជនគ្រប់រូប ត្រូវបានទទួលការការពារយ៉ាងហ្មត់ចត់ រួមទាំងការគិតគូពីរបបសន្តិសុខសង្គម សម្រាប់ពលករ ពលការិនី មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ទើបធ្វើឲ្យស្ថានភាពជួញដូរមនុស្ស នៅកម្ពុជាមានការប្រែប្រួលតិចតួច និងអាចគ្រប់គ្រងបាន ។
- រាជរដ្ឋាភិបាលកម្ពុជាមានច្បាប់ គោលនយោបាយគ្រប់គ្រាន់ និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការគោរពសិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋ ការពារសុវត្ថិភាព ពីភាពរងគ្រោះ ជាពិសេស ដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។
- ការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាយន្តការជាតិ គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលទូលំទូលាយ ប្រកបដោយឆន្ទៈមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ មានកិច្ចសហប្រតិបត្តិការល្អ និងមានសមត្ថភាពដោះស្រាយរាល់បញ្ហា ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស ។
- ល្បិចកលក្នុងការប្រព្រឹត្តបទល្មើស មានការប្រែប្រួល បត់បែន កាន់តែស្មុគ្រស្មាញ និងពិបាកកំណត់។ ទោះបីយ៉ាងនេះក្តី ក៏មន្ត្រីអនុវត្ត កាន់តែមានជំនាញ មានបទពិសោធន៍កាន់តែស៊ីជម្រៅ និងកាន់តែមានការចូលរួម និងកិច្ចសហការល្អពីអ្នកពាក់ព័ន្ធ ជាតិ និងអន្តរជាតិ ។
- ប្រជាពលរដ្ឋកាន់តែមានការយល់ដឹងច្រើនពីអំពើជួញដូរមនុស្ស និងមានការប្រុងប្រយ័ត្ន ចំណែកជនរងគ្រោះ ក៏មានបទពិសោធន៍កាន់តែច្រើន។

ទោះបីជាយ៉ាងនេះក្តី ប្រភេទបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សថ្មីៗ បានកើតមានជាបន្តបន្ទាប់ ដែលចាំបាច់ត្រូវតែបន្តការយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់។

# V. ទិសដៅ១០ខែ ឆ្នាំ២០១៩

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ផ្ទៃក្នុងជាតិ ប្រទេសពាក់ព័ន្ធ និងជាមួយអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ការពារ និងបង្ក្រាប ឈានទៅលុបបំបាត់អំពើជួញដូរ មនុស្សគ្រប់រូបភាព។

២. ពង្រឹងការអនុវត្តច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការនាំទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. សម្រេចបញ្ចប់លើសេចក្តីព្រាង និងប្រកាសដាក់ឲ្យប្រើប្រាស់ផែនការយុទ្ធសាស្រ្ត ៥ឆ្នាំ ២០១៩-២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
៤. ចុះពិនិត្យ ស្ថានភាពប្រែប្រួល និងចំណុចសេសសល់ លើការងារលើកកម្ពស់សុវត្ថិភាពពលករនៅក្រៅប្រទេស ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួល។
៥. ជំរុញការកសាង អនុស្សរណៈ ឬកិច្ចព្រមព្រៀង ស្តីពីកិច្ចការពារសុវត្ថិភាពពលករក្នុងវិស័យនេសាទ។
៦. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។
៧. បន្តពង្រឹងការងារបង្ការ ទប់ស្កាត់ តាមរយៈការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។
៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី និងជំរុញការអនុវត្ត គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីអនុវត្តន៍នៅតាមបណ្តាក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងមន្ត្រីស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ។
៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។
១០.ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។
១១.បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" និងការរៀបចំយន្តការទទួលពលករ នៅមណ្ឌលទទួលពលករប៉ោយប៉ែត និងត្រៀមរៀបចំបន្តតាមគោលដៅច្រកទ្វារសំខាន់ៗដទៃទៀត (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** )។
១២.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។
១៣.រៀបចំវេទិកាអន្តរសាសនា ប្រឆាំងអំពើជួញដូរមនុស្ស។
១៤.រៀបចំទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
១៥.បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

១៦.បន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **ប្រមុខរាជរដ្ឋាភិបាល** និង**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ជំរុញការសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានលំហូរពលករឆ្លងកាត់ និងមានការបញ្ជូនត្រឡប់ពីប្រទេសថៃ ដោយរៀបចំយន្តការអន្តរស្ថាប័ន ដែលមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារសម្រន់ សម្រាប់មនុស្សចាស់ កុមារ ទារក ការផ្តល់ប្រឹក្សា ការផ្តល់ព័ត៌មានអំពីការងារ ឬសេវាច្បាប់ ទីកន្លែងសម្រាក ឬស្នាក់នៅបណ្តោះអាសន្ន សម្របសម្រួលរកមធ្យោបាយធ្វើដំណើរ ទទួលបណ្តឹង ឬសាកសួរព័ត៌មានអំពីភាពរងគ្រោះ ស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ចម្លងជូន**

- ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈ ១០ខែ ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រសួងអប់រំ យុវជន និងកីឡា | សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការងបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស | ក្រសួងអប់រំ យុវជន និងកីឡា | 10 លើក | 600 នាក់ | 113 នាក់ |
| | | តាមរយៈការប្រជុំផ្សព្វផ្សាយច្បាប់ ស្ដីពីការជួញដូរមនុស្ស និងច្បាប់ការត្រួតពិនិត្យគ្រឿងញៀន មន្ត្រីបុគ្គលិក លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។ | ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ | 1 លើក | 600 នាក់ | 0 នាក់ |
| 2 | ក្រសួងការងារ និង បណ្ដុះ បណ្ដាលវិជ្ជាជីវៈ | តាមរយៈការផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងច្បាប់ បទបញ្ញត្តិពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងដល់សហគម៍ និងអ្នកដែលមានបំណងស្វែងរកការងារធ្វើនៅបរទេស ដល់ខេត្តចំនួន៥ មាន៖ ខេត្តកំពត កំពង់ចាម កំពង់ធំ បាត់ដំបង និងខេត្តព្រៃវែង | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មជ្ឈមណ្ឌល MRC | 5 លើក | 35,915 នាក់ | 18,300 នាក់ |
| 3 | កាកបាទក្រហមកម្ពុជា | បានលើកកម្ពស់ការយល់ដឹង ដោយបញ្ជ្រាបការងារផ្សព្វផ្សាយក្រោមប្រធានបទ ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅក្នុងក្របខណ្ឌការងារជាអន្តរវិស័យ តាមរយៈគម្រោងសុវត្ថិភាពសហគមន៍ និងគម្រោងស្ដារទំនាក់ទំនងគ្រួសារដែលបាន និងកំពុងអនុវត្តនៅក្នុងខេត្តគោលដៅតាមបណ្ដោយព្រំដែនចំនួន ៤ គឺខេត្ត ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តព្រះវិហារ។ | កាកបាទក្រហមកម្ពុជា | 5 លើក | 165 នាក់ | 132 នាក់ |
| 4 | ក្រុមការងារ អនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើ ធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំ មានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 2,567 លើក | 158,961 នាក់ | 87,535 នាក់ |
| 5 | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ផ្សព្វផ្សាយដល់បណ្ដាញការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានមន្ទីរឧស្សាហកម្ម និងសិប្បកម្មទាំង ១១មន្ទីរ និងអង្គភាពរដ្ឋាករទឹក ៤កន្លែង ស្ដីពីលទ្ធផលដែលនាំឱ្យមានការជួញដូរមនុស្ស។ | ក្រសួង/មន្ទីរឧស្សាហកម្ម និងសិប្បកម្ម និងអង្គភាពរដ្ឋាករទឹក | 4 លើក | 121 នាក់ | 121 នាក់ |
| 4 | ក្រសួងកិច្ចការនារី | វេទិកាផ្សព្វផ្សាយរបស់ក្រុមគ្រូបង្គោលថ្នាក់ខេត្ត ស្រុក ឃុំ ស្ដីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តរតនគិរី បាត់ដំបង កំពត និងខេត្តកំពង់ចាម | ក្រសួង/មន្ទីរកិច្ចការនារីខេត្ត | 8 លើក | 696 នាក់ | 383 នាក់ |
| 5 | ខេតកណាល | វេទិកាសាធារណៈការអនុវត្តគោលនយោបាយទាំង៩ចំណុច ភូមិ-ឃុំ មានសុវត្ថិភាព ស្ដីពីការលើកកម្ពស់សិលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដោយបានបញ្ជ្រាប ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋទូទាំងខេត្ត។ | មន្ទីរកិច្ចការនារី ខេត្ត និងក្រុមការងារថ្នាក់ក្រុង/ស្រុក | 930 លើក | 49,716 នាក់ | 22,814 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| [illegible] | [illegible] | ផ្សព្វផ្សាយច្បាប់ ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការធ្វើអាជីវកម្មផ្លូវភេទ និងអំហឹង្សាលើស្ត្រី និងកុមារ ដល់សាលារៀន គរុកោសល្យ ក្រឹតការ មន្ទីរនានា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅតាមវិទ្យាល័យប្រជាពលរដ្ឋទូទាំងខេត្ត។ | ក្រុមការងារថ្នាក់ក្រុង/ស្រុក មន្ទីរ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មន្ទីរកិច្ចការនារី មន្ទីរអប់រំខេត្ត | 3,372 លើក | 396,780 នាក់ | 197,160 នាក់ |
| 6 | ខេត្តតាកែវ | វេទិកាសាធារណៈស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 121 លើក | 4,565 នាក់ | 1,941 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈសិក្ខាសាលា និងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរកិច្ចការនារីខេត្ត | 624 លើក | 37,273 នាក់ | 16,804 នាក់ |
| 7 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្នុងខេត្តទាំងមូល។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 1,225 លើក | 79,062 នាក់ | 41,524 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាក ស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋទូទាំងខេត្ត ។ | ស្នងការដ្ឋាននគរបាលខេត្ត | 3,880 លើក | 739,705 នាក់ | 419,731 នាក់ |
| 8 | ខេត្តប៉ៃលិន | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីកិច្ចការនារី | 444 លើក | 20,780 នាក់ | 8,643 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុង/ស្រុក។ | | 597 លើក | 27,072 នាក់ | 11,420 នាក់ |
| 9 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ តាមការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 6,130 លើក | 421,815 នាក់ | 215,149 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | | 3,236 លើក | 114,389 នាក់ | 58,368 នាក់ |
| 10 | ខេត្តព្រៃវែង | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងសំណួរចម្លើយតាមរយៈប្រារព្ធទិវាជាតិនារី៨មិនា ដល់ស្រុកចំនួន៦ ។ និងបានផ្សព្វផ្សាយ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈពរពោះជំនួសដល់ប្រជាពលរដ្ឋ នៅក្នុងស្រុកពារាំង និង ស្រុកស៊ីធរកណ្តាល។ | មន្ទីរកិច្ចការនារីខេត្ត | 3 លើក | 4,870 នាក់ | 0 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយស្របច្បាប់ ការរំលោភបំពានផ្លូវភេទ និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងតំណាងឃុំទាំង៥មានឃុំ( ជ្រៃ ព្រៃខ្លា មានបុណ្យ ទឹកថ្លា និងឃុំសំពោង) សរុប៣០ភូមិ និងនៅសាលាស្រុកពោធិ៍រៀង។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អង្គការចាប់ដៃ | 2 លើក | 3,773 នាក់ | 2,500 នាក់ |
| 11 | ខេត្តស្វាយរៀង | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អង្គការចាប់ដៃ | 3 លើក | 1,613 នាក់ | 1,005 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 2,730 លើក | 99,596 នាក់ | 55,431 នាក់ |
| 12 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 4,621 លើក | 175,255 នាក់ | 91,170 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អង្គការដៃគូ | 4,951 លើក | 235,977 នាក់ | 123,045 នាក់ |
| 13 | ខេត្តសៀមរាប | វេទិកាសាធារណៈផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋទូទាំងខេត្ត។ | ស្នងការដ្ឋាននគរបាលខេត្ត លេខាធិការដ្ឋាន គ.ខ.ប.ជ និង មន្ទីរកិច្ចការនារី | 2,706 លើក | 128,614 នាក់ | 77,241 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋទូទាំងខេត្ត។ | មន្ទីរកិច្ចការនារី មន្ទីរអប់ កងរាជអាវុធហត្ថខេត្ត រដ្ឋបាលស្រុក និងអង្គការពាក់ព័ន្ធ | 470 លើក | 40,544 នាក់ | 24,639 នាក់ |
| 14 | ខេត្តកំពង់ធំ | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | គ.ខ.ប.ជ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរអប់រំ និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | 67 លើក | 35,950 នាក់ | 18,647 នាក់ |
| 15 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយតាមរយៈគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 42 លើក | 5,817 នាក់ | 2,382 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 16 | ខេត្តកំពង់ស្ពឺ | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋានខេត្ត ស្នងការដ្ឋាននគរបាលខេត្ត និងអាជ្ញាធរភូមិ/ឃុំ/ក្រុង/ស្រុក | 2,070 លើក | 349,584 នាក់ | 169,030 នាក់ |
| 17 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកត្បូងឃ្មុំ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 15 លើក | 838 នាក់ | 596 នាក់ |
| 18 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 90 លើក | 5,503 នាក់ | 2,635 នាក់ |
| | | ផ្សព្វផ្សាយ និងបញ្ជ្រាបការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចំនួន១៩៨សាលា និងប្រជាពលរដ្ឋនៅស្រុកបុទុមសាគរ និងស្រុកថ្មបាំង។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំ យុវជន និងកីឡា | 200 លើក | 25,818 នាក់ | 11,542 នាក់ |
| 19 | ខេត្តកែប | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារី និងស្នងការដ្ឋាននគរបាលខេត្ត | 225 លើក | 45,447 នាក់ | 20,926 នាក់ |
| 20 | ខេត្តកំពត | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 954 លើក | 33,917 នាក់ | 17,744 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកដងទង់ បន្ទាយមាស ទឹកឈូ អង្គរជ័យ ជុំគិរី និងនៅច្រកតន់ហាន់ | ក្រុមការងារលេខាធិការដ្ឋានស្រុក មន្ទីរកិច្ចការនារីខេត្ត | 89 លើក | 6,371 នាក់ | 3,455 នាក់ |
| 21 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងបញ្ជ្រាបការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋទូទាំងខេត្ត។ | ស្នងការដ្ឋាននគរបាលខេត្ត | 222 លើក | 11,382 នាក់ | 5,298 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈការប្រជុំជាមួយគ្រូបង្រៀន ដើម្បីធ្វើការណែដល់សិស្ស ឲ្យចេះសរសេរបដារ ពាក្យស្លោកដែលមានខ្លឹមសារ ប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មពលកម្មលើកុមារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។ និងផ្សព្វផ្សាយ ទៅដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្ត ឲ្យអនុវត្តន៍តាមច្បាប់ ស្តីពីការងារ។ | មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរការងារ និងបណ្តុះបណ្តាលខេត្ត | 110 លើក | 19,154 នាក់ | 12,401 នាក់ |
| 22 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកស្នួល ចិត្របូរី និងស្រុកព្រែកប្រសព្វ និងសិស្ស និស្សិត ។ | លេខាធិការដ្ឋានគ.ខ.ប.ជ មន្ទីរអប់រំខេត្ត មន្ទីរសង្គមកិច្ច និងមន្ទីរកិច្ចការនារីខេត្ត | 20 លើក | 1,376 នាក់ | 1,026 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | វេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពារបស់រាជរដ្ឋាភិបាល | លេខាធិការដ្ឋាន គ.ខ.ប.ជ | 25 លើក | 2,300 នាក់ | 1,950 នាក់ |
| 23 | ខេត្តស្ទឹងត្រែង | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងជម្រកសុវត្ថិភាពសម្រាប់ស្ត្រី និងក្មេងស្រី លើការរំលោភបំពាន ដល់ប្រជាពលរដ្ឋទូទាំងខេត្ត។ | មន្ទីរកិច្ចការនារីខេត្ត | 6 លើក | 363 នាក់ | 245 នាក់ |
| 24 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៥យ៉ាង អំពីគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 2,752 លើក | 104,551 នាក់ | 78,191 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចការការពារជនរងគ្រោះដោយអំពើជួញដូរ ដល់ប្រប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។ | ស្នងការដ្ឋាននគរបាលខេត្ត | 371 លើក | 21,187 នាក់ | 11,598 នាក់ |
| 25 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈស្តីពីភូមិឃុំមានសុវត្ថិភាព និងការអប់រំចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់ អំពើជួញដូរមនុស្ស | ស្នងការដ្ឋាននគរបាលខេត្ត | 21 លើក | 1,086 នាក់ | 676 នាក់ |
| 26 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋទូទាំងខេត្ត។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរអប់រំ មន្ទីរការងារ និង មន្ទីរទេសចរណ៍ | 82 លើក | 5,650 នាក់ | 2,997 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ | ក្រុមការងារគ.ខ.ប.ជខេត្ត និង អាជ្ញាធរក្រុង/ស្រុក | 56 លើក | 3,813 នាក់ | 1,641 នាក់ |

សកម្មភាពសរុបចំនួន: 46,062 លើក

មនុស្សសរុបចំនួន: 3,458,564 នាក់

ស្រីសរុបចំនួន : 1,838,149 នាក់

# ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៥០៨លើក) មនុស្សចំនួន១៩.១៤៧នាក់ (ស្រី៨.០១៣នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន ១៩២លើក អ្នកចូលរួមសរុបចំនួន ២.៦៦៨នាក់ (ស្រី១.០៤១នាក់)<br>❖ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**<br>- បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំ ចំនួន០៦លើក៖<br>- កិច្ចប្រជុំត្រួតពិនិត្យលើនីតិវិធី ស្តីពីការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងពលរដ្ឋខ្មែរ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំចង្អៀតអន្តរក្រសួងថ្នាក់រដ្ឋមន្ត្រី ពិភាក្សាកំណត់ ទិសដៅរួមគ្នាសម្រាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍សម្រាប់ត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រទេសបញ្ចូន៣ប្រទេស (កម្ពុជា ឡាវ និងភូមា) នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន១៦នាក់ ស្រី០៣នាក់។<br>- បានអញ្ជើញចូលរួមជាអធិបតីភាព ចំនួន០២លើក៖<br>- ក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ លើកទិសដៅឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានសមាសភាពចូលរួមចំនួន ១៩៩នាក់ ស្រី៩៣នាក់។<br>❖ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញចូលរួមកិច្ចប្រជុំ៖<br>- ផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន១១លើក អ្នកចូលរួមចំនួន៧៤នាក់ ស្រី១២នាក់។<br>- ស្តីពីការត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន៣២នាក់ ស្រី០៧នាក់ (ចំនួន០២លើក)។<br>- ស្តីពីការងារគ្រប់គ្រងទេសន្តរប្រវេសន៍ សម្រាប់ត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រទេសបញ្ចូន៣ប្រទេស (កម្ពុជា ឡាវ និងភូមា)។<br>- ស្តីពីការបែងចែកក្រុមដឹកនាំកងកម្លាំងនគរបាលជាតិ និងមន្ត្រីរាជការស៊ីវិលនៃក្រសួងមហាផ្ទៃ ដើម្បីអញ្ជើញចុះសួរសុខទុក្ខកងកម្លាំងនគរបាលជាតិ នៅតាមបណ្តាវរៈនគរបាលការពារព្រំដែន។<br>- ស្តាប់របាយការណ៍ និងពិភាក្សាលើការវាយតម្លៃរាជធានី-ខេត្ត អ្នកចូលរួមចំនួន១៥នាក់ ស្រី០១នាក់ (ចំនួន០២លើក)។<br>- ស្តីពីការស្នើសុំកិច្ចសហការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការការងារជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោះស្រាយបណ្តឹងក្រុមហ៊ុននាំពលករខុសច្បាប់។<br>- ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ០៦៦ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ អ្នកចូលរួមចំនួន១១នាក់ ស្រី០២នាក់។<br>- ស្តីពីផែនការការងារអ្វីជាអាទិភាពរបស់ក្រុមការងារទេសន្តរប្រវេសន៍ ធ្វើចាប់ពីពេលនេះរហូតដល់បំណាច់ឆ្នាំ២០១៨។ |

| | |
|---|---|
| | - ស្តីពីពលករទេសន្តរប្រវេសន៍ មានអ្នកចូលរួមចំនួន១៦នាក់ ស្រី០២នាក់។<br>- ស្តីពីការបិទសន្និបាតឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ដែលនឹងប្រព្រឹត្តទៅនៅខេត្តកំពង់ឆ្នាំង និងខេត្តកែប នៅសាលប្រជុំអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំអន្តរក្រសួងចំនួន១០លើក សមាសភាពចូលរួមចំនួន២២៦នាក់ ស្រី៤៤នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ស្តីពីករណីពពោះជំនួស ក្នុងដំណាក់កាលមិនទាន់មានច្បាប់ មានសមាសភាពចូលរួមចំនួន២៤នាក់ ស្រី០៥នាក់។<br>- លើសេចក្តីព្រាងច្បាប់ ស្តីពី "ការពពោះជំនួស" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ មានសមាសភាពចូលរួមចំនួន១៦នាក់ ស្រី០៤នាក់។<br>- ស្តីពីការងារដោះស្រាយសំណុំរឿងរំលោភសេពសន្ថវៈ តាមរយៈសំណងហិរញ្ញវត្ថុដល់ជនរងគ្រោះ មានសមាសភាពចូលរួមចំនួន០៩នាក់ ស្រី០១នាក់។<br>- ស្តីពីការពិភាក្សាត្រៀមរៀបចំកិច្ចប្រជុំឆ្លាស់វេនជាមួយក្រសួងសន្តិសុខសាធារណៈចិន ដើម្បីពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការបង្ការ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានសមាសភាពចូលរួមចំនួន១៩នាក់ ស្រី០៦នាក់។<br>- លើករណីបណ្តឹងរំលោភលើសេចក្តីទុក្ខចិត្ត និងការប៉ុនប៉ងនាំពលករចេញមិនស្របច្បាប់ទុកសម្រាប់ឆ្លងដែន របស់មជ្ឈមណ្ឌលភាសាជប៉ុន ភ្នំពេញកូត្សូ និងមជ្ឈមណ្ឌលភាសាកូរ៉េ ជប៉ុន ដេជូជូ សមាសភាពចូលរួមក្រុមការងារបង្ការ ទប់ស្កាត់ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស។<br>- ស្តីពីការវាយតម្លៃការផ្តល់ពិន្ទុប្រចាំឆ្នាំ២០១៧ ជូនដល់គណៈកម្មាធិការ គ.រ.ច.ជ/គ.ខ.ប. មានសមាសភាពចូលរួមចំនួន១៨នាក់ ស្រី០៣នាក់។<br>- ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣។<br>- ស្តីពីការពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៥៤នាក់។<br>- ពិភាក្សាចំនួន០២លើក ត្រៀមរៀបចំកិច្ចប្រជុំ ស្តីពីកិច្ចការការពារពលករទេសន្តរប្រវេសន៍៖ តួនាទីប្រទេសបញ្ជូន និងប្រទេសទទួល មានសមាសភាពចូលរួមចំនួន៨៦នាក់ ស្រី២៥នាក់។<br>- ជាមួយអង្គការដៃគូ ចំនួន០៥លើក មានអង្គការចាប់ដៃ ស្តីពីការងារពាក់ព័ន្ធអំពើជួញដូរមនុស្ស និងត្រៀមចុះអនុស្សរណៈយោគយល់គ្នា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន៣២នាក់ ស្រី០៦នាក់ និងអង្គការកោរីតាស ស្តីពីការរៀបចំកសាងមណ្ឌលសំចតសម្រាប់ពលករនៅក្រុងព្រះសីហនុ និងរៀបចំទិវាអន្តរសាសនាលើកទី២ អ្នកចូលរួមចំនួន២០នាក់ ស្រី០៤នាក់។<br>- ស្តីពីការងាររវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង DSI ថៃ។<br>- ពិភាក្សាការផ្តល់យោបល់ លើអនុស្សរណៈនៃការយោគយល់គ្នារវាង ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខនៃសាធារណៈប្រជាមានិតចិន។<br>- ប្រចាំឆ្នាំលើកទី២ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន ស្តីពីភាពរីកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការសកម្មភាព នៅសណ្ឋាគារភ្នំពេញ។ |

| | |
|---|---|
| | - ពិភាក្សាពិគ្រោះយោបល់ក្រុមប្រទេសបញ្ជូន ស្តីពីតួនាទីរបស់ប្រទេសបញ្ជូនដើម្បីពិភាក្សា (កម្ពុជា មីយ៉ាន់ម៉ា ឡាវ) ពីបញ្ហារួម និងដំណោះស្រាយរួម នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប។<br>- ស្តីពីបច្ចេកទេសយេនឌ័រ (TWG-G) នៅទីស្តីការក្រសួងកិច្ចការនារី។<br>- ជាគណអធិបតីភាព ចំនួន០៤លើក អ្នកចូលរួមចំនួន១.១០៩នាក់ ស្រី៨៦១នាក់៖<br>  ○ ក្នុងកម្មវិធីសំណេះសំណាលអបអរសាទរទិវានារីអន្តរជាតិ៨មីនា ខួបលើកទី១០៧ ឆ្នាំ២០១៨ នៅសាលប្រជុំក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៩៥៩នាក់ ស្រី៨៦១នាក់។<br>  ○ ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងការប្រឡងប្រណាំងការងារ ភូមិ-ឃុំ មានសុវត្ថិភាព របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង។<br>  ○ ក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតាមដានត្រួតពិនិត្យ នៃការអនុវត្តក្រមប្រតិបត្តិយេនឌ័រ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅសណ្ឋាគារ កាំបូឌីយ៉ាណា មានសមាសភាពចូលរួមប្រមាណ១៥០នាក់។<br>  ○ ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលក្រិតវិជ្ជាជីវៈនគរបាល និងប្រកាសតាំងស៊ុបក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ប្រព្រឹត្តទៅនៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា។<br>- ជាប្រធានប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចុះបំពេញបេសកកម្មតាមដានលើការអនុវត្ត អនុសញ្ញាស៊ី-ដ(CEDAW) អនុសាសន៍ សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាតិពាក់ព័ន្ធដែលទាក់ទងនឹងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខមាលភាពស្ត្រី នៅខេត្តត្បូងឃ្មុំ។<br>- បានដឹកនាំមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីចុះសួរសុខទុក និងសំណេះសំណាលកងកម្លាំងនគរបាលវរៈសេនាតូចការពារព្រំដែនទឹក និងគោក នៅខេត្តតាកែវ កំពត និងខេត្តកែប (វរៈលេខ៨៣០ ២៤១ និង៦០៣)។<br>- បានចុះទៅការិយាល័យអង្គការ GVC ខេត្តសៀមរាប ដើម្បីពិនិត្យ តាមដានការអនុវត្តការងារ និងផែនការសកម្មភាព។<br>- បានសហការជាមួយមូលនិធិ ឈៀន ឆាយ ដើម្បីមនុស្សធម៌ដែលជាដៃគូចុះពិនិត្យស្ថានភាពពលករខ្មែរ នៅក្រុមហ៊ុនសំណង់ធំមួយដែលប្រើប្រាស់ពលករជាង ២ម៉ឺននាក់ និងមានបណ្តាញជាច្រើន ឈ្មោះថា JWS Construction Co. Ltd. នៅជាប់ខេត្តឈុនបូរី ប្រទេសថៃ។<br>- បានរៀបចំកម្មវិធីការពារគម្រោងនិក្ខេបបទលម្អិត ថ្នាក់បណ្ឌិត ជំនាញវិទ្យាសាស្ត្រនយោបាយ លើប្រធានបទ «ទេសន្តប្រវេសន៍កម្ពុជា១៧ឆ្នាំ នាដើមសតវត្សន៍ទី២១» ប្រព្រឹត្តទៅនៅសាលារាជបណ្ឌិត្យសភាកម្ពុជា ។<br>- បានចូលរួមជំនួបពិភាក្សារវាង ក្រសួងមហាផ្ទៃដឹកនាំដោយ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជាមួយក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ជារដ្ឋមន្ត្រី** ប្រព្រឹត្តទៅនៅទីស្តីការក្រសួងមហាផ្ទៃ ។<br>- បានអញ្ជើញជាគណអធិបតី៖<br>  ○ ក្នុងពិធីសំណេះសំណាលជាមួយសមាជិកាសមាគមនារីខេត្ត ដែលអញ្ជើញមកពីរដ្ឋបាល អាជ្ញាធរមានសមត្ថកិច្ច ក្នុងបណ្តាក្រុង ស្រុក/សង្កាត់ឃុំនៅក្នុង/ខេត្តកំពង់ឆ្នាំង សៀមរាប ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគិរី ខេត្តមណ្ឌលគិរី សរុបអ្នកចូលរួម ចំនួន៧២០នាក់ ។ |

- បានអញ្ជើញជួបសំណេះសំណាលជាមួយ៖
  - ○ បងប្អូនកម្មករ និយោជិត នៅស្រុកសាមគ្គីមានជ័យ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សា៖
  - ○ ក្នុងកិច្ចប្រជុំរៀបចំផែនការយុទ្ធសាស្ត្រជាតិរបស់ គ.ជ.ប.ជ រយៈពេល៥ឆ្នាំ បន្ត(២០១៩-២០២៣) ប្រព្រឹត្តទៅនៅសាលប្រជុំអគារ ៤ ក្រសួងមហាផ្ទៃ។
  - ○ ពិគ្រោះយោបល់ ស្តីពីបទល្មើសរត់ពន្ធជនអន្តោប្រវេសន៍ រៀបចំដោយ អង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន (UNODC) ប្រព្រឹត្តទៅនាទីក្រុងបាងកក ប្រទេសថៃ។ និងជួបពិភាក្សាជាមួយមន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ។
  - ○ លើករណីពពោះជំនួស ដែលត្រូវបានបង្ក្រាបកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ប្រព្រឹត្តទៅនៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ○ ជាមួយតំណាងស្ថានទូតអាមេរិចប្រចាំកម្ពុជា លើរបាយការណ៍ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០១៧ ប្រព្រឹត្តទៅនៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ○ បានអញ្ជើញចុះត្រួតពិនិត្យការដ្ឋានសាងសង់មណ្ឌលសំចតប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ ។
  - ○ បានទទួលជំនួបសំដែងការគួរសម និងពិភាក្សាការងារជាមួយប្រធានអង្គការ GVC Cambodia ប្រព្រឹត្តទៅនៅការិយាល័យលោកជំទាវ ។
  - ○ បានដឹកនាំមន្ត្រីជាន់ខ្ពស់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងប្រធាននាយកដ្ឋាន មន្ត្រី ក្រសួងសង្គមកិច្ច ចូលរួមសហការជាមួយអាជ្ញាធរដែនដី ដើម្បីចុះពិនិត្យលទ្ធភាពទទួលពលករ ក្នុងមណ្ឌលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថានភាពពលករវិលត្រលប់ តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកទ្វារព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង តាមគោលការណ៍ ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ប.ជ.ជ ស្តីពី៖
  - ○ ផែនការយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ ២០១៩-២០២៣
  - ○ ករណីស្ត្រីពពោះជំនួស
  - ○ ក្រុមការងារយេនឌ័រ
  - ○ ការរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រឆាំងអំពើជួញដូរមនុស្សលើកទី២
  - ○ ការងារទទួលពលករ ដែលអាជ្ញាធរថៃបញ្ជូនត្រឡប់ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត
  - ○ អនុក្រឹត្យ ២៧៣ អនក្រ .បក និងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីគន្លឹះបំពេញបន្ថែមនូវចន្លោះខ្វះខាត
  - ○ ការផ្តល់យោបល់អំពីពង្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារប្រចាំការទទួលពលករ ពលការិនីកម្ពុជាខុសច្បាប់ ប្រចាំខេត្តបន្ទាយមានជ័យ
  - ○ សំណួរលក្ខណៈវិនិច្ឆ័យ វាយតម្លៃ គ.រ.ប.ជ/គ.ខ.ប.ជបន្ត ប្រចាំឆ្នាំ២០១៨។

- បានអញ្ជើញជាអធិបតី៖
    - ក្នុងសិក្ខាសាលាបញ្ចប់ របស់ក្រុមការងារបច្ចេកទេសកម្ពុជា នៃកម្មវិធីអូស្ត្រាលី-អាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្ស (AAPTIP) នៅសណ្ឋាគារភ្នំពេញ
    - ក្នុងកិច្ចប្រជុំពិភាក្សា ស្តីពីការពង្រឹងកិច្ចសហការការងាររវាងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូរ ក្នុងការជួយដល់ពលករកម្ពុជា ដែលត្រូវបញ្ជូនត្រឡប់មកពីប្រទេសថៃ នៅខេត្តបន្ទាយមានជ័យ
    - ធ្វើបទឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីការរៀបចំផែនការសកម្មភាពរយៈពេល១ឆ្នាំ និងរយៈពេល៥ឆ្នាំ ដល់សមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ នៅសាលប្រជុំសាលាខេត្តសៀមរាប
    - ថ្លែងមតិបើកអង្គសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅសាលប្រជុំសាលាខេត្តបាត់ដំបង អ្នកចូលរួមចំនួន១២២រូប។

❖ ឯកឧត្តម នាយឧត្តមសេនីយ៍ **ថោង សំអាត** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម ៖

- ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យ កែសម្រួលរបាយការណ៍ ត្រៀមធ្វើសន្និបាតប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ រួមទាំងប្រលងប្រណាំងរបស់រាជធានី-ខេត្ត មានសមាសភាពចូលរួមចំនួន១៦នាក់ ស្រី០១នាក់។
- ដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់មន្ត្រីនគរបាលជាតិ និងមន្ត្រីស៊ីវិល នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀងរាល់សប្តាហ៍ថ្ងៃច័ន្ទ។
- ពិធីបិទសន្និបាតបូកសរុបវឌ្ឍនៈភាពនៃលទ្ធផលការងារអត្តសញ្ញាណកម្មរយៈពេល៣ឆ្នាំ (២០១៤-២០១៧) របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅទីស្តីការក្រសួងមហាផ្ទៃ។
- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅទីស្តីការក្រសួងមហាផ្ទៃ។
- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ ក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ របស់រដ្ឋបាលរាជធានី-ខេត្តចំនួន១១លើក ៖ (រាជធានីភ្នំពេញ កំពង់ធំ បន្ទាយមានជ័យ បាត់ដំបង សៀមរាប ព្រៃវែង ព្រះសីហនុ កណ្តាល កំពង់ចាម ត្បូងឃ្មុំ និងខេត្តតាកែវ)។
- កិច្ចប្រជុំ ស្តីពីការកំណត់ចំនួនមុខតំណែងថ្នាក់អគ្គនាយករង អនុនាយកដ្ឋាន អនុការិយាល័យ និងថ្នាក់ប្រហាក់ប្រហែលនៃក្របខ័ណ្ឌនគរបាលជាតិមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ នៅទីស្តីការក្រសួងមហាផ្ទៃ។
- កិច្ចប្រជុំ ស្តីពីមិទ្ទិញអបអរខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារកម្ពុជា ឆ្នាំ២០១៨ ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅសាលមហោស្រពពិព័រកោះពេជ្រ។
- ប្រជុំអន្តរក្រសួង ឆ្លងខ្លឹមសារឯកសារសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ ។

❖ ក្រុមជំនួយកិច្ចការទាំង០៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**១-ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- ឯកឧត្តម **ស៊ុន រ៉ូ** អគ្គលេខាធិការរង

- បានដឹកនាំមន្ត្រីអគ្គលេខាធិការដ្ឋានមួយចំនួនជួបជាមួយតំណាងអង្គការ USAID ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំប្រទេសថៃ ឡាវ និងតំបន់ ដើម្បីបង្ហាញអំពីយន្តការ និងរចនាសម្ព័ន្ធរបស់ គ.ជ.ប.ជ ដែលមានតាំងពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិរហូតដល់ស្រុក/ក្រុង-ឃុំ/សង្កាត់ ដោយផ្អែកលើផែនការសកម្មភាពជាតិ(២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រជាអទិភាព ។
- តាមដាន និងប្រមូលទិន្នន័យលទ្ធផលបង្ក្រាបបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។
- តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ ពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់ នៅតាមបណ្តា រាជធានី-ខេត្ត និងទំនាក់ទំនងសហការជាមួយក្រុមការងារអនុវត្តន៍ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ។
- ស្រង់ព័ត៌មានតាមរយៈតេឡេក្រាម នូវរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានចុះផ្សព្វផ្សាយពីការបង្ការទប់ស្កាត់នៃភាពងាយរងគ្រោះ និងបទដ្ឋានច្បាប់នានាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅតាមសហគមន៍ សាលារៀន ដើម្បីជាបច្ច័យល្អដល់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ដឹកនាំកិច្ចប្រជុំ ស្តីពីការផ្តល់ធាតុចូលក្នុងផែនការណ៍យុទ្ធសាស្ត្ររយៈពេល០៥ឆ្នាំ របស់ក្រុមយុទ្ធសាស្ត្រទី២ ការលើកកម្ពស់ការបង្ការទប់ស្កាត់ នូវរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងតំណាងក្រសួងពាក់ព័ន្ធ។
- តាមដានព័ត៌មានជាប្រចាំ តាមរយៈបណ្តាញសង្គមនានា ដែលទាក់ទងនឹងរឿងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការងារផ្សព្វផ្សាយស្តីពីការបង្ការ ទប់ស្កាត់ភាពរងគ្រោះដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ និងតាមរយៈ Telegram របស់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- លោកឧត្តមសេនីយ៍ត្រី ***កែវ សុវណ្ណារ៉ា*** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមកិច្ចប្រជុំ ចំនួន០៤លើក៖

- កិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យរបាយការណ៍ឆ្នាំ២០១៧ របស់ក្រុមការងារបង្ការ ទប់ស្កាត់ និងកែសម្រួល ផែនការសកម្មភាពឆ្នាំ២០១៨ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។
- កិច្ចប្រជុំផ្ទៃក្នុង ស្តីពីការពិនិត្យលើអាទិភាពផែនការសកម្មភាពសម្រាប់អនុវត្ត ឆ្នាំ២០១៨ មានសមាសភាពចូលរួមចំនួន០៧នាក់ ស្រី០១នាក់។
- ជួបសម្របសម្រួលជាមួយនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ ស្តីពីការស្នើទិដ្ឋាការជូន លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីចូលរួមកិច្ចប្រជុំ ស្តីពីទេសន្តរប្រវេសន៍ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។
- ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រឆ្នាំ(២០១៨-២០២០)សម្រាប់ក្រុមយុវជនជំទង់ និងយុវជន រៀបចំដោយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ នៅសណ្ឋាគារសាន់វ៉េ។
- បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យផ្តល់យោបល់ និងបំពេញបន្ថែមនូវធាតុចូលលើកចុងក្រោយ លើរបាយការណ៍អំពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ នៅភោជនីយដ្ឋានទន្លេរបាសាក់២។

| | |
|---|---|
| | - បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចពិភាក្សាលើករណីពពោះជំនួស ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ផៃ ស៊ីណារិទ្ធ** អគ្គស្នងការរងនគរបាលជាតិ នៅសាលប្រជុំ អគ្គស្នងការដ្ឋាននគរបាលជាតិ។<br>- លោកអនុប្រធានក្រុម បានអញ្ជើញចូលរួមស្តាប់បឋកថាចែករំលែកពុទ្ធិ និងបទពិសោធន៍ ក្នុងការរៀបចំសុន្ទរកថា និងសេចក្តីថ្លែងការជាសាធារណៈ ដោយមាន ឯកឧត្តម បណ្ឌិត **ច័ន្ទ សំណព្វ** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ជាវាគ្មិនកិត្តិយស នៅសាលប្រជុំ ទ ក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តគោលនយោបាយ និងផែនការណ៍សកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារកុមារនៅសាលារៀន ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិត សភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា។ អ្នកចូលរួមចំនួន ៧៦នាក់ ស្រី១៨នាក់ នៅភោជនីយដ្ឋាន ទន្លេបាសាក់២។<br>- បានដឹកនាំសមាជិកក្រុមទាំងអស់ ប្រជុំពិភាក្សាផ្ទៃក្នុងក្រុម អំពីយុទ្ធសាស្រ្តបង្ការ ទប់ស្កាត់។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាបន្តលើសំណួរ វាយតម្លៃ គ.រ.ប.ជ/គ.ខ.ប.ជ លើសកម្មភាពការងារបង្ការ ទប់ស្កាត់ ឆ្នាំ២០១៧-២០១៨ ដើម្បីត្រៀមដាក់បញ្ចូលជាកម្រងសំណួររួមសម្រាប់ជូនភ្ជាប់ទៅរាជធានី-ខេត្ត។<br>**២-ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ** លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការរង៖<br>- បានតាមដាន និងស្រង់ស្ថិតិជនរងគ្រោះ ដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស សរុបចំនួន ២៨១នាក់ (ស្រី១៦៦នាក់) ក្នុងនោះ បានបញ្ជូនមកពីប្រទេស៖ ម៉ាឡេស៊ីចំនួន១២៩នាក់(ស្រី៧០នាក់) ឥណ្ឌូនេស៊ីចំនួន០៥នាក់ស្រី)០៣នាក់ (ឡាវចំនួន៣១នាក់(ស្រី២០នាក់) វៀតណាមចំនួន៣៩នាក់(ស្រី៣០នាក់) ចិនចំនួន៤០នាក់(ស្រី៣៩នាក់) សឹង្ហបូរី ចំនួន០៨នាក់(ស្រី) ថៃចំនួន២៨នាក់ ស្រី១៣នាក់ និងប្រទេស កូរ៉េត០១នាក់ (ស្រី)។<br>- ដោយផ្អែកលើរបាយការណ៍របស់ក្រសួងស្ថាប័ន អង្គភាព និង NGO ជាដៃគូ ក្នុងខែឧសភា ឆ្នាំ២០១៨ នេះក្រុមជំនួយកិច្ចការការពារជនរងគ្រោះទទួលបានជំនួបជនសង្ស័យ រងគ្រោះដោយអំពើជួញដូរមនុស្សដែលអាជ្ញាធរបរទេសបញ្ជូនត្រលប់កម្ពុជាវិញមានចំនួន ៦២នាក់។ ក្នុងនោះរួមមានប្រទេសចំនួន ០៣ ដូចខាងក្រោម៖<br>• ប្រទេសសិង្ហបូរី ចំនួន០៣នាក់ (ស្ត្រី០៣នាក់)<br>• ប្រទេសម៉ាឡេស៊ីចំនួន៦៥នាក់ (ស្ត្រី៣២នាក់ កុមារ០៥នាក់) ធ្វើការខុសច្បាប់ និងមិនអាចទ្រាំការងារបាន<br>• ប្រទេសអេហ្ស៊ីប ចំនួន០១នាក់ (ស្ត្រី) មិនអាចទ្រាំទ្រនឹងការងារលំបាកបាន<br>• ប្រទេសចិន ចំនួន២១នាក់ (ស្ត្រី២០នាក់) រៀបការខុសច្បាប់ទៅចិន<br>• ប្រទេសវៀតណាម ចំនួន៤០នាក់ លក់ឆ្នោត និងរស់នៅខុសច្បាប់<br>• ប្រទេសថៃ ចំនួន០៩នាក់ (អនីតិជនអាយុចាប់ពី១៣ដល់១៦ឆ្នាំ) រងគ្រោះដោយអំពើជួញដូរមនុស្ស។<br>- នៅគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានធ្វើការសម្ភាសន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅប្រទេសចិនចំនួន០៤នាក់ ដែលទើបបញ្ជូនត្រឡប់មក |

| | |
|---|---|
| | កម្ពុជាវិញ ក្នុងនោះ៖ មានខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តកំពត និងរាជធានីភ្នំពេញ ហើយកំពុងស្នាក់នៅអង្គការចាប់ដៃ។<br>**៣-ក្រុមជំនួយកិច្ចការអនុវត្តន៍ច្បាប់** ឯកឧត្តម ឧត្តមសេនីយ៍ទោ **ជីវ ផល្លី** អគ្គលេខាធិការរង ៖<br>- ដឹកនាំប្រជុំផ្ទៃក្នុងក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ស្តីពីការពិនិត្យលើអាទិភាពផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៨ មានសមាសភាពចូលរួមចំនួន០៧នាក់ ស្រី០១នាក់។<br>- ទំនាក់ទំនង និងជំរុញក្រុមការងារយុត្តិធម៌ ដើម្បីស្រង់យកចំនួនតួលេខជម្រះក្តីពីក្រសួងយុត្តិធម៌។<br>- បានសម្ភាសន៍ជាមួយជនរងគ្រោះ ដែលត្រូវបានបញ្ជូន ពីប្រទេសចិន ចំនួន០១នាក់។<br>- បានស្រាវជ្រាវ និងទំនាក់ទំនង ទៅបណ្តាញសង្គម Facebook ដែលបានបង្ហោះសុំឲ្យជួយសង្គ្រោះចេញពីទូកនេសាទ នៅប្រទេសសូម៉ាលី។<br>- បានស្រាវជ្រាវ និងទំនាក់ទំនង ទៅបណ្តាញសង្គម Facebook ដែលបានបង្ហោះ ស្តីពីយុវតីសិស្សវិទ្យាល័យទួលអំពិលម្នាក់បានរត់គេចពីក្រុមឧក្រិដ្ឋជនចាប់បង្ខាំងទុក ខណៈក្មេងស្រីទាំង១០នាក់ទៀត កំពង់ជាប់ឃុំ។<br>- បានសម្របសម្រួល និងណែនាំនីតិវិធីស្នងការរង ខេត្តកំពង់ធំ ដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវក្រុមហ៊ុន ឬមេខ្យល់ពាក់ព័ន្ធ លើករណីនាំមនុស្សទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី កាលពីឆ្នាំ២០១៥។<br>- បានសម្របសម្រួល និងណែនាំនីតិវិធី បើកការស៊ើបអង្កេតបឋមករណីឪពុករំលោភសេពសន្ថវៈ លើកូនស្រីបង្កើតតាំងពីអាយុ១០ឆ្នាំ រហូតដល់អាយុ១៣ឆ្នាំ រហូតមានផ្ទៃពោះ២ខែ។<br>- បានធ្វើកំណត់ហេតុបណ្តឹង ឲ្យបងប្រុសជនរងគ្រោះ ដែលត្រូវបានបាត់ខ្លួននៅប្រទេសម៉ាឡេស៊ី។<br>**៤-ក្រុមជំនួយកិច្ចការយុត្តិធម៌៖** ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង ៖<br>- បានអញ្ជើញចូលរួមជាវាគ្មិន ចំនួន០២លើក៖<br>- បង្ហាញពីរចនាសម្ព័ន្ធ និងយន្តការជាតិ ថ្នាក់ក្រោមជាតិ ឆ្លើយតបក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងផែនការសកម្មភាព ដល់ក្រុម សិក្សាស្រាវជ្រាវរបស់ USID ប្រចាំតំបន់ ជាមួយអង្គការ WINROCK ប្រចាំកម្ពុជា។<br>- ដល់ក្រុមសិក្សាស្រាវជ្រាវតំបន់អាស៊ី (RAPID ASIA) ចំនួន០២រូប ពិគ្រោះយោបល់ និងធ្វើការសិក្សាស្រាវជ្រាវ ការអនុវត្តក្របខណ្ឌច្បាប់នៅកម្ពុជា ទាក់ទងនឹងសំណងរដ្ឋប្បវេណី និងសំណងបដិទាន ទៅដល់ជនរងគ្រោះ<br>- បានអញ្ជើញចូលរួមសិក្ខាសាលា ចំនួន០៣លើក អ្នកចូលរួមចំនួន៣០នាក់៖<br>- ពិគ្រោះយោបល់ថ្នាក់ជាតិ លើសេចក្តីព្រាងរបាយការណ៍ជាតិ គួបលើកទី៤ ទី៥និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ (២០០៨-២០១៨) គោលបំណងប្រមូលធាតុចូលពាក់ព័ន្ធ រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- ស្តីពីការពិនិត្យចុងក្រោយលើសេចក្តកព្រាង ការវិភាគស្ថាភាពសិទ្ធកុមារឆ្នាំ២០១៧ នៅកម្ពុជា រៀបចំដោយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារនៅភោជនីយ៍ដ្ឋានទន្លេបាសាក់២ គោលបំណងសិក្ខាសាលាគឺបង្កើនការយល់ដឹង រួមចំណែកដល់ការស្រាវជ្រាវជាតិលើបញ្ហាកុមារ និងពង្រឹងគុណភាពក្នុងការ |

តាមដានការអនុវត្តសិទ្ធិកុមារ។

- ស្តីពីកិច្ចពិភាក្សាជ្រើសរើសរឿងជោគជ័យជាលទ្ធផលនៃកម្មវិធី AAPTIP ក្រោមការគាំទ្រ និងសហការរបស់អគ្គស្នងការនគរបាលជាតិ និងក្រសួងយុត្តិធម៌ រៀបចំដោយអង្គការ AAPTIP នៅសណ្ឋាគារកាំបូឌីយ៉ាណា អ្នកចូលរួមចំនួន៣០នាក់។
- បានអញ្ជើញចូលរួមកិច្ចប្រជុំ ចំនួន០២លើក៖
- ពិភាក្សាអំពីតម្រូវការ ការបណ្តុះបណ្តាលធនធានមនុស្សនៅតាមអង្គភាព ដែលមានការចូលរួមគ្រប់អគ្គចំណុះក្រសួងមហាផ្ទៃ រៀបចំដោយអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។
- ពិភាក្សាជាមួយក្រុមការងារប្រេតិភូចិន ដើម្បីសម្របសម្រួលលើកម្មវិធីនៃកិច្ចប្រជុំលើកទី២ រវាងកម្ពុជាចិន ក្នុងការអនុវត្តកិច្ចព្រមព្រៀង និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ។
- ឯកឧត្តមឧត្តមសេនីយ៍ឯក **យឹម វីរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង នៅអគ្គស្នងដ្ឋានការនគរបាលជាតិ ដឹកនាំដោយលោកជំទាវ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ និងជាតំណាងក្រុមអនុវត្តច្បាប់ ពិភាក្សាលើការអនុវត្តបន្ត ក្រោយពីការបង្ក្រាបករណីពពោះជំនួស។
- លោកឧត្តមសេនីយ៍ត្រី **ស៊ុន ប៊ុណ្ណា** អនុប្រធាននាយកដ្ឋានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស គម្រោង AAPTIP កម្ពុជា លើកទី១០ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកនៃអគ្គនាយកដ្ឋានអយ្យការ និងកិច្ចការព្រហ្មទណ្ឌ អ្នកចូលរួមចំនួន៤១នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

## ៥-ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ

- លោកជំទាវ ឧត្តមសេនីយ៍ត្រី **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
    - កិច្ចប្រជុំ Comment on EU Commission Concern
    - កិច្ចប្រជុំជាមួយ ឯកឧត្តម **ងី ច័ន្ទផល** និងក្រុមការងារ EU ប្រចាំក្រសួងមហាផ្ទៃលើការឆ្លើយតប EU
    - កិច្ចប្រជុំជាមួយក្រុមការងារ បេសកកម្មសហគមន៍អឺរ៉ុប ដែលប្រព្រឹត្តទៅសាលប្រជុំ B នៃទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ
    - ប្រជុំជាមួយ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ទាក់ទងនឹងការធ្វើរបាយការណ៍សម្រាប់ឆ្នាំ ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
    - បានដឹកនាំកិច្ចប្រជុំក្រុមទី២ ដែលត្រៀមរៀបចំកម្មវិធីអន្តរសាសនាថ្នាក់ជាតិលើកទី២ អ្នកចូលរួមចំនួន១៣រូប ស្រី០៤រូប នៅបន្ទប់ប្រជុំការិយាល័យលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- លោកវរសេនីយ៍ឯក **អ៊ិន មាន** បានចូលរួមសហការជាមួយក្រុមការងាររ៉ិបសាយបញ្ចូលទិន្នន័យអង្គការ និងកម្មវិធីសម្រាប់ប្រើលើទូរស័ព្ទ )Mobile App) ដើម្បីធ្វើការរៀបចំ Resource Database។
- មន្ត្រីក្រុមការងារបានចូលរួមកិច្ចប្រជុំ ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ គ.ជ.ប.ជ និងក្រុមការងារ ខមមីតកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរ

| | |
|---|---|
| | មនុស្ស នៃក្រុមការងារសហប្រតិបត្តិការអន្តរជាតិ គ.ជ.ប.ជ រយៈពេល៥ឆ្នាំ ២០១៤-២០១៨ និងទិសដៅការងារអនុវត្តបន្ត ក្រោមអធិបតីភាព លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី នៅទីស្ដីការក្រសួងកិច្ចការនារី។<br>- ស្ដីពីការបន្ថែម និងកែប្រែចំណុចមួយចំនួនទៅលើសេចក្ដីព្រាងអនុស្សរណៈរវាង គ.ជ.ប.ជ និងអង្គការចាប់ដៃ ទៅលើការកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ បច្ចុប្បន្នភាពរបស់អង្គការដៃគូអភិវឌ្ឍន៍។<br>- ស្ដីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យអង្គការ និងការផ្ដល់ថវិកាសម្រាប់ផលិតវីដេអូខ្លីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការលើកថវិកាថ្មីសម្រាប់ការធ្វើសិក្ខាសាលាបណ្ដុះបណ្ដាល និងពង្រឹងការងារអនុវត្តច្បាប់ និងការងារយុត្តិធម៌នៅថ្នាក់ខេត្ត ដើម្បីជំរុញការសហការរវាងនគរបាល និងព្រះរាជអាជ្ញា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- ស្ដីពីការបូកសរុបការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខេមមីតកម្ពុជា នៅទីស្ដីការក្រសួងកិច្ចការនារី។<br>- កិច្ចប្រជុំពិភាក្សាការងារ និងផ្ដល់ឯកសារបទអន្តរាគមន៍ជំនាញ ពាក់ព័ន្ធកិច្ចប្រជុំគណៈកម្មាធិការចម្រុះ កម្ពុជា-អឺរ៉ុប លើកទី១០ ដែលគ្រោងនឹងធ្វើនៅទីក្រុងប៊្រុចសែល ប្រទេសបែលហ្ស៊ិក នៅមជ្ឈមណ្ឌល សិក្សាស្រាវជ្រាវអភិបាលកិច្ច ក្រសួងមហាផ្ទៃ។<br>- ពិនិត្យ និងឆ្លងសេចក្ដីព្រាងច្បាប់ ស្ដីពីការពពោះជំនួស នៅសាលប្រជុំក្រសួងយុត្តិធម៌។<br>- ស្ដីពីការឆ្លើយតបនឹង UN លើអនុសញ្ញា CEDAW ពាក់ព័ន្ធនឹងការរំលោភ។ ប្រជុំជាមួយ NCCD ក្រសួងមហាផ្ទៃ។<br>- ស្ដីពីបច្ចុប្បន្នភាពការងារដើម្បីស្ដាប់នូវរបាយការណ៍វិវឌ្ឍន៍ថ្មីៗ និងបញ្ហាប្រឈមក្នុងកំឡុងពេលអនុវត្តការងារពីអ្នកចូលរួម និងអ្នកពិភាក្សាលើការងារជា អាទិភាពត្រូវអនុវត្តបន្ត នៅសាលប្រជុំក្រសួងកិច្ចការនារី។<br>- បានចូលរួមវគ្គបណ្ដុះបណ្ដាល អភិវឌ្ឍន៍ភាពជាអ្នកដឹកនាំនយោបាយ ជំនាន់ទី១៣ នៅក្រសួងបរិស្ថាន។<br>- ក្រុមការងារបានធ្វើការរៀបចំនូវពង្រាងទម្រង់ចុះបញ្ជីអង្គការ ដែលមានសកម្មភាពការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ត្រៀមប្រជុំជាមួយតំណាងអង្គការដៃគូអភិវឌ្ឍន៍ក្នុងការបញ្ចូលទិន្នន័យនៅលើវិបសាយ។<br>- ក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានរៀបចំកិច្ចប្រជុំពិនិត្យសារឡើងវិញលើផែនការសកម្មភាព ២០១៨ ដែលផ្ញើមកពីក្រុមការងារអន្តរក្រសួង។<br>- លោកជំទាវ រ៉ន សិរីលក្ខិណា និងលោក វរសេនីយ៍ឯក អ៊ិន មាន បានអញ្ជើញចូលរួមប្រជុំដើម្បីពិភាក្សាលើផែនការសកម្មភាពដែលក្រសួងស្ថាប័នពាក់ព័ន្ធគ្រោងនឹងអនុវត្តលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ(២០១៩-២០២៣)ដើម្បីបញ្ចូលផែនការសកម្មភាពរបស់ក្រុម ការងារទៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០៥ ឆ្នាំបន្ត(២០១៩-២០២៣)នៃ គ.ជ.ប.ជ ដែលដឹកនាំដោយក្រសួងកិច្ចការនារី។<br>- បានការសហការជាមួយ អង្គការ សម្ព័ន្ធចាប់ដៃ អង្គការ វីនរ៉ុក បានបើកកិច្ចប្រជុំពិភាក្សាលើការរៀបចំទម្រង់ចងក្រងទិន្នន័យអង្គការធ្វើការពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ និងស្ដីពីការត្រួតពិនិត្យ និងកែតម្រូវលើទម្រង់ចុះបញ្ជីអង្គការដៃគូអភិវឌ្ឍន៍ និងកិច្ចពិភាក្សាស្ដីពីការបង្កើតវីដេអូអប់រំខ្លី របស់សហគមន៍ពាក់ព័ន្ធនឹងការជួញដូរមនុស្សជាមួយ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។ |

| | |
|---|---|
| | - ប្រចាំឆមាស ក្រុមការងារបញ្ញាបយេនឌ័រ ក្រសួង ស្ថាប័ន នៅសណ្ឋាគារភ្នំពេញ។<br>- ជាមួយ ក្រុមប្រឹក្សាជាតិ ដើម្បីរៀបចំផែនការ ៥ឆ្នាំ (២០១៩-២០២៣) ដោយបញ្ចូលការងារពាក់ព័ន្ធទេសន្តប្រវេសន៍ និងប្រឆាំងការជួញដូរមនុស្ស។<br>- ជាមួយអគ្គព្រះរាជអជ្ញា តំណាងអគ្គស្នងការនគរបាលជាតិ និងអគ្គស្នងការនគរបាលរាជធានីភ្នំពេញ លើបញ្ហាកំណត់ទោសចំពោះស្ត្រី ៣២នាក់ ដែលបានទទួលការពពោះជំនួស នៅតុលាការដំបូងរាជធានីភ្នំពេញ។<br>- បានធ្វើការដោះស្រាយទៅលើបញ្ហាស្ត្រីខ្មែរម្នាក់ ដែលធ្វើការនៅប្រទេសហុងកុង នឹងចង់ធ្វើមាតុភូមិនិវត្តន៍វិញ ខណៈពេលដែលខ្លួនមិនទាន់ផុតកុងត្រាការងារជាមួយក្រុមហ៊ុន។ ក្នុងនោះដែលក៏មានការសហការ និងសម្របសម្រួលជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ផងដែរ ក្នុងការរៀបចំរបាយ<br>- ការណ៍ដើម្បីធ្វើចំណាត់ការបន្ត។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល អភិវឌ្ឍន៍ភាពជាអ្នកដឹកនាំនយោបាយ ជំនាន់ទី១៣ នៅក្រសួងបរិស្ថាន។<br>- បានធ្វើការរៀបចំនូវពង្រាងទម្រង់ចុះបញ្ជីអង្គការ ដែលមានសកម្មភាពការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ត្រៀមប្រជុំជាមួយតំណាងអង្គការដៃគូអភិវឌ្ឍន៍ក្នុងការបញ្ចូលទិន្នន័យនៅលើវិបសាយ។<br>- ក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានរៀបចំកិច្ចប្រជុំពិនិត្យសារឡើងវិញលើផែនការសកម្មភាពឆ្នាំ២០១៨ ដែលផ្ញើមកពីក្រុមការងារអន្តរក្រសួង។ និងប្រជុំប្រចាំឆមាស ក្រុមការងារបញ្ញាបយេនឌ័រ ក្រសួង ស្ថាប័ន នៅសណ្ឋាគារភ្នំពេញ។<br>- ជាមួយ ក្រុមប្រឹក្សាជាតិ ដើម្បីស្ត្រី ដើម្បីរៀបចំផែនការ៥ឆ្នាំ (២០១៩-២០២៣) ដោយបញ្ចូលការងារពាក់ព័ន្ធទេសន្តប្រវេសន៍ និងប្រឆាំងការជួញដូរមនុស្ស។<br>- ជាមួយអគ្គព្រះរាជអជ្ញា តំណាងអគ្គស្នងការនគរបាលជាតិ និងអគ្គស្នងការនគរបាលរាជធានីភ្នំពេញ លើបញ្ហាកំណត់ទោសចំពោះស្ត្រី ៣២នាក់ ដែលបានទទួលការពពោះជំនួស នៅតុលាការដំបូងរាជធានីភ្នំពេញ។<br>- ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានធ្វើការដោះស្រាយទៅលើបញ្ហាស្ត្រីខ្មែរម្នាក់ដែលធ្វើការនៅប្រទេសហុងកុង និងចង់ធ្វើមាតុភូមិនិវត្តន៍វិញ ខណៈពេលដែលខ្លួនមិនទាន់ផុតកុងត្រាការងារជាមួយក្រុមហ៊ុន។ ក្នុងនោះដែលក៏មានការសហការ និងសម្របសម្រួលជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ផងដែរ ក្នុងការរៀបចំរបាយការណ៍ដើម្បីធ្វើចំណាត់ការបន្ត។<br>• លោកវរៈសេនីយ៍ឯក **អ៊ិន មាន** ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្ដីទី បានធ្វើបទបង្ហាញលើការប្រើប្រាស់វិធី ដើម្បីចង់ក្រងទិន្នន័យ និងការរក្សាទុក ព្រមទាំងធ្វើការណែនាំពន្យល់ពីគម្រោងថ្មី នៃគេហទំព័រវិបសាយគ្រប់គ្រងប្រព័ន្ធទិន្នន័យបច្ចុប្បន្នដៃគូអភិវឌ្ឍន៍ផងដែរ។<br>- បានចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោង ស្តីពីការពិនិត្យ និងរៀបចំផែនការសកម្មភាពបន្តសម្រាប់អនុវត្តគម្រោង ILO-TRIANGLE នៅសណ្ឋាគារភ្នំពេញ ក្រោមការរៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការផ្នែកបច្ចេកទេសដោយអង្គការ ILO។<br>- បានអញ្ជើញជាអធិបតី ក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតាមដានត្រួតពិនិត្យ នៃការអនុវត្តក្រមប្រតិបត្តិយេនឌ័រ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅសណ្ឋាគារ កាំបូឌីយ៉ាណា មានសមាសភាពចូលរួមប្រមាណ ១៥០នាក់។ |

| | |
|---|---|
| | - បានដឹកនាំកិច្ចប្រជុំលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា រវាងអង្គការ GVP (GRUPPO DI VOLONTARIATO CIVILE) និងគ.ជ.ប.ជ ស្តីពីការគាំទ្រ និងការតស៊ូមតិ លើសិទ្ធិពលករទេសន្តប្រវេសន៍កម្ពុជា និងប្រទេសថៃ ក្នុងការបង្ការទប់ ស្កាត់ពីការរំលោភបំពានផ្សេងៗ និងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ត្រៀមរៀបចំកិច្ចប្រជុំ ស្តីពីកិច្ចការពារពលករទេសន្តប្រវេសន៍៖ តួនាទីប្រទេសបញ្ជូន និងប្រទេសទទួល នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៦០នាក់ ស្រី១៩នាក់។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន ស្តាប់របាយការណ៍ និងពិភាក្សាលើការវាយតម្លៃរាជធានី-ខេត្ត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយតំណាងក្រសួង ២០១៧និងសម្រេចលើរបាយការណ៍ឆ្នាំ ស្ថាប័ន និងអង្គការដៃគូពាក់ពន្ធ័ ដើម្បីពិនិត្យ នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៥៤នាក់។<br>- បានអញ្ជើញចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាគមមូលនិធិ ឈាន ឆាយ ដើម្បីមនុស្សធម៌ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសក្នុងចំណោមពលករទេសន្តប្រវេសន៍នៅប្រទេសថៃ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង រៀបចំយុទ្ធសាស្រ្តជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ(២០១៩-២០២៣)នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាត្រៀមរៀបចំប្រជុំ ស្តីពីកិច្ចការពារ ពលករទេសន្តប្រវេសន៍: តួនាទីប្រទេសបញ្ជូន និងប្រទេសទទួល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន២៦នាក់ ស្រី០៦នាក់។<br>- បានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយអង្គការដៃគូក្នុងការរៀបចំគម្រោងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យទិន្នន័យជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់អង្គការ ដែលមានអ្នកចូលរួមចំនួន១៣នាក់ ស្រី០៤នាក់។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការឆ្លើយតបនឹង UN លើអនុសញ្ញា CEDAW ពាក់ព័ន្ធនឹងការរំលោភ ។<br>- បានចាត់តាំងមន្ត្រីចូលរួមកម្មវិធី សុវត្ថិភាពទីក្រុងសម្រាប់ស្ត្រី ដែលមានគោលបំណងកាត់បន្ថយអំពើហឹង្សាលើស្ត្រីនៅទីសាធារណៈ របស់អង្គការ Actionaid Cambodia ។<br>- ស្រាវជ្រាវ និងរក្សាទុកឯកសារទាក់ទងនឹងអនុស្សរណៈយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗ ។<br>- រៀបចំគ្រប់គ្រងបែបបទ និងតារាងព័ត៌មានដូចជា៖ ឈ្មោះអង្គការ ដៃគូអភិវឌ្ឍន៍ ច្រកចេញចូល និងប្រភេទពលករទេសន្តប្រវេសន៍ ។<br>- បានទំនាក់ទំនងការិយាល័យហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រមូលព័ត៌មានចំនួនពលករទេសន្តប្រវេសន៍របស់ប្រទេសបញ្ជូនទាំង៣ (កម្ពុជា ឡាវ និងភូមា) ជាលទ្ធផលមិនផ្លូវការគឺ ប្រទេសភូមាមានលំដាប់លេខរៀងទី១ កម្ពុជាទី២ និងឡាវទី៣ តែមិនមានទិន្នន័យ ឬរបាយការណ៍ជាក់លាក់អះអាងទេ។<br>- បានទំនាក់ទំនងបុគ្គលិកអង្គការ FAR របស់ប្រទេសថៃ និងសហភាពសម្ព័ន្ធសហជីពជាតិកម្ពុជា (NACC) ដើម្បីឲ្យជួយសហការស្រាវជ្រាវរកទីតាំង និងចំនួនពលករដែល មិនទាន់បានទទួលភាពស្របច្បាប់ ។ |

**៦-ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍** ឯកឧត្តម **ខៀវ ចាន់ប៉ា** អគ្គលេខាធិការរង ៖

បានចាត់បញ្ជូនមន្ត្រីដើម្បីចូលរួម៖

- សិក្ខាសិលា ចំនួន០២លើក៖
  - ស្តីពីទេសន្តរប្រវេសន៍កុមារ និងផលប៉ះពាល់លើកុមារទេសន្តរប្រវេសន៍ ដែលគ្រួសារមិនបានទៅជាមួយ រៀបចំដោយអង្គការ IOM។
  - ស្តីពីការឧបត្ថមគាំទ្រជួយជំលៀសប្រជាពលរដ្ឋខ្លួន ដែលរងគ្រោះនៅមហន្តរាយក្នុងប្រទេសដែលមានវិបត្តិក្រោមការរៀបចំដោយអង្គការIOM នៅសណ្ឋាគារភ្នំពេញ។
- កិច្ចប្រជុំ ចំនួន០៣លើក
  - ស្តីពីការពិនិត្យ និងរៀបចំផែនការសកម្មភាពបន្តសំរាប់អនុវត្តគម្រោង ILO-TRIANGLE នៅសណ្ឋាគារភ្នំពេញ ក្រោមការរៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការផ្នែកបច្ចេកទេសដោយអង្គការ ILO។
  - ស្តីពីការលើកកម្ពស់សិទ្ធិនារី ដែលចំណាកស្រុកទៅក្រៅប្រទេស នៅក្នុងតំបន់អាស៊ានតាមកម្មវិធីសុវត្ថិភាព និងយុត្តិធម៌នៅសណ្ឋាគារ Raffle Hotel Le Royal រៀបចំឡើងដោយអង្គការ UN-WOMAN និង ILO។
  - លោកឧត្តមសេនីយ៍ទោ ស្រី សាមឌី ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ និងលោកឧត្តមសេនីយ៍ត្រី កែវ សុវណ្ណប៉ា ប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ បានអញ្ជើញចូលរួមសិក្ខាសិលា ស្តីពីទេសន្តរប្រវេសន៍កុមារ និងផលប៉ះពាល់លើកុមារទេសន្តរប្រវេសន៍ ដែលគ្រួសារមិនបានទៅជាមួយ រៀបចំដោយអង្គការ IOM។
- បានទំនាក់ទំនងការិយាល័យហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រមូលព័ត៌មានចំនួនពលករទេសន្តរប្រវេសន៍របស់ប្រទេសបញ្ជូនទាំង៣ (កម្ពុជា ឡាវ និងភូមា) ជាលទ្ធផលមិនផ្លូវការគឺ ប្រទេសភូមាមានលំដាប់លេខរៀងទី១ កម្ពុជាទី២ និងឡាវទី៣ តែមិនមានទិន្នន័យ ឬរបាយការណ៍ជាក់លាក់អះអាងទេ ។
- បានទំនាក់ទំនងបុគ្គលិកអង្គការ FAR របស់ប្រទេសថៃ និងសហភាពសម្ព័នសហជីពជាតិកម្ពុជា (NACC) ដើម្បីឲ្យជួយសហការស្រាវជ្រាវរកទីតាំង និងចំនួនពលករដែល មិនទាន់បានទទួលភាពស្របច្បាប់ ។
- តាមដានអំពីស្ថានភាពពលករទេសន្តរប្រវេសន៍ និងពលករខ្មែរដែលត្រូវបានចាប់បញ្ជូនត្រឡប់មកពីប្រទេសថៃ ។
- ចូលរួមប្រជុំក្នុងក្រុមពិភាក្សាស្តីពី " ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស " នៅក្នុងយុទ្ធសាស្ត្រទី២ យតំណាងក្រសួងការងារ និងជាមួ ណ្តុះបបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងកិច្ចការនារី ដែលលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ បានធ្វើការបែងចែក កាលពីរសៀលថ្ងៃអង្គារទី១២ ខែមិថុនាឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ ដើម្បីផ្តល់ធាតុចូលជំហានដំបូងទៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ២០១៩-២០២៣ ជាលទ្ធផល នៅពុំទាន់បានបញ្ចប់ធាតុចូលទាំងស្រុងទេ ដោយតំណាងក្រសួងអប់រំដែលជាប្រធានក្រុមការងារបង្ការទប់ស្កាត់ សំណូមពររង់ចាំប្រមូលធាតុចូលមួយចំនួនទៀតពីសមាជិកក្រុម ដែលមកពីក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗសិន។

| | |
|---|---|
| | - បានសហការណ៍ទំនាក់ទំនងស្នើសុំរបាយការណ៍លទ្ធផលសកម្មភាពប្រចាំខែឧសភា និងមិថុនា ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីត្រៀមបញ្ចូលក្នុងរបាយការណ៍ឆមាសទី១ឆ្នាំ២០១៨របស់។ ជាលទ្ធផល បានទទួល និងគ.ជ.ប.ជ ប្រគល់ជូនលោក អ៊ុន សុខជា ប្រធានការិយាល័យសរុបផែនការណ៍រួចហើយ។<br>- បានសហការស្រាវជ្រាវព័ត៌មានតាមរយៈមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធានច្រកទ្វារអន្តរជាតិប៉ោយប៉ែត ប្រធានច្រកទ្វារអន្តរជាតិដូង ប្រធាននគរបាលប៉ុស្តិ៍អន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង និងខាងអង្គការ IOM ដែលមានទីតាំងប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយ ប៉ែត ដើម្បីតាមដានព័ត៌មាន ស្តីពីការពង្រឹងការអនុវត្តច្បាប់របស់អាជ្ញាធរថៃទៅលើពលករបរទេស ពិសេសពលករទេសន្តរប្រវេសន៍កម្ពុជា ដែលមិនបានទទួលភាពស្របច្បាប់ហើយដែលផ្សព្វផ្សាយជាសាធារណៈថានឹងចាប់ផ្តើមចាប់បញ្ជូនមកកម្ពុជាវិញនៅក្រោយថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ក្រែងភាគីថៃផ្តល់ព័ត៌មានឲ្យដឹង ជាលទ្ធផលគឺនៅមានភាពស្ងប់ស្ងាត់ ពួកគាត់ពុំទាន់បានទទួលព័ត៌មានអ្វីពីភាគីថៃឡើយ គ្រាន់តែដឹងតាមព័ត៌មានផ្សព្វផ្សាយថា នឹងចាប់បញ្ជូនពលករបរទេសដែលគ្មានភាពស្របច្បាប់នៅដើមខែកក្កដាឆ្នាំ២០១៨មកវិញតែប៉ុណ្ណោះ។<br>- បានស្រាវជ្រាវតាមប្រព័ន្ធទំនាក់ទំនងសង្គម(Facebook,Telegrame) លទ្ធផលទទួលបានគឺះយោងតាមរបាយការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានឲ្យដឹងថា ចុះថ្ងៃទី២២ ខែមិថុនា ២០១៨ស្ថានឯកអគ្គរាជទូតកម្ពុជាបាន អន្តរាគមន៍ជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ចំនួន ២១នាក់ក្នុងនោះ។<br>- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសសិង្ហបុរី ជួយសង្គ្រោះពលការិនី០២នាក់ ដែលបានទៅបំរើការងារជាជំនួយការមេផ្ទះនៅទីនោះ។<br>- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ជួយសង្គ្រោះពលករ-ពលការិនីចំនួន១២នាក់ ក្នុងនោះពលការិនីចំនួន០៧នាក់ និងកុមារចំនួន ០៣នាក់ (កូនរបស់ពលការិនី)ដែលបានទៅធ្វើការខុសច្បាប់នៅទីនោះ។<br>- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសសៀងហៃ ជួយសង្គ្រោះស្ត្រីខ្មែរចំនួន០៧នាក់ ដែលត្រូវបានមេខ្យល់នាំទៅរៀបការខុសច្បាប់នៅប្រទេសចិន។<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ៖<br>• បានចូលរួមកិច្ចប្រជុំ ជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងតំណាងក្រសួងពាក់ព័ន្ធ មួយចំនួនទៀត ស្តីពីការផ្តល់ធាតុចូល ក្នុងផែនការយុទ្ធសាស្ត្រជាតិរយៈពេល៥ឆ្នាំ របស់ក្រុមយុទ្ធសាស្ត្រទី២ ក្រោមប្រធានបទ "ការលើកកម្ពស់ការបង្ការ ទប់ស្កាត់នូវរាល់ទម្រង់ នៃអំពើជួញដូរមនុស្ស"។<br>• បានចូលរួមប្រជុំពិភាក្សា អំពីការងាររៀបចំក្រុមការងារ និងយន្តការទទួលពលករ ពលការិនីកម្ពុជា ដែលត្រូវបានបញ្ជូនពីប្រទេសថៃ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និង ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានធ្វើរបាយការណ៍ ស្តីពីបេសកកម្មអមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ដើម្បីអង្កេត និងស្វែងយល់ពីស្ថានភាពចាប់បញ្ជូនពលករកម្ពុជា ជាក់ស្តែងតាមច្រកទ្វារព្រំដែនអន្តរជាតិទាំងពីរខាងលើ ដាក់ជូនលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ពិនិត្យ និងជ្រាបជារបាយការណ៍។<br>- លោកឧត្តមសេនីយ៍ត្រី កែវ ផល្លា បានចូលរួមប្រជុំកែតម្រូវផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំបន្ត របស់ក្រុមពិភាក្សាទី២ "យុទ្ធសាស្ត្របង្ការ ទប់ស្កាត់ គ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស" ជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងស្តាប់អនុសាសន៍ណែនាំ ដាក់បញ្ចូលសកម្មភាពតូចៗ បន្ថែមមួយចំនួនទៀត ដែល |

| | |
|---|---|
| | បំបែកចេញពីចង្កោមសកម្មភាពធំៗ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>**៧. <u>លេខាធិការដ្ឋាន គ.ខ.ប.ជ៖</u>**<br>❖ <u>ការងាររដ្ឋបាល ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨នេះ មានដូចខាងក្រោម:</u><br>- បានទទួលលិខិតចូល៥០ច្បាប់ និងបញ្ជូនលិខិតចេញ៤៣ច្បាប់ ពីក្រសួង ស្ថាប័ននានា សរុបចំនួន៩៣ច្បាប់ ក្នុងនោះមាន៖<br>• គ.ជ.ប.ជ លិខិតចូលមក ចំនួន១៥ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន៣១ច្បាប់។<br>• អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លិខិតចូលមក ចំនួន៣៥ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន១២ច្បាប់។<br>- បានចាត់បញ្ជូន៖<br>• មន្ត្រីជាគ្រូឧទ្ទេស ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលចំនួន ០២វគ្គគឺ នៅខេត្តពោធិ៍សាត់ និងបន្ទាយមានជ័យ ដែលមានសិក្ខាកាមចូលរួមចំនួន៤៧នាក់ (ស្រី១៩នាក់) ដែលរៀបចំដោយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា និងអង្គការ IOM។<br>• មន្ត្រី០៤រូប ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាល របស់អង្គការសម្ព័ន្ធចាប់ដៃ (រាជធានីភ្នំពេញ) ស្តីពីការពង្រឹងបណ្តាញការងារ និងកសាសមត្ថភាពដល់អ្នកអនុវត្តការងារសង្គមកិច្ចដោយផ្ទាល់នៅកម្ពុជា។<br>- បានធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានធ្វើកំណត់ហេតុកិច្ចប្រជុំផ្ទៃក្នុង និងអន្តរក្រសួងនានា។<br>- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ប្រចាំខែ និងត្រីមាសទី៣)។<br>- បានរៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- បានបញ្ជូនរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅកាន់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។<br>- បានចងក្រង ព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដាក់ចូលក្នុងបណ្ណាសាររើគី និងគ្រប់គ្រងទំព័រ Facebook របស់លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន ដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ បានស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី និងរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ នៅរៀងរាល់កិច្ចប្រជុំ។ |
| **ស្ថាប័នអន្តរក្រសួងសម្របសម្រួលចំនួន៦១លើក អ្នកចូលរួមសរុបចំនួន៨៨៤នាក់ (ស្រី៤៧០នាក់)** | |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយអង្គការដៃគូក្នុងការរៀបចំគម្រោងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យទិន្នន័យជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់អង្គការ ដែលមានអ្នកចូលរួមចំនួន១៣នាក់ (ស្រី០៤នាក់)។<br>- បានរៀបចំកិច្ចប្រជុំបន្តជាមួយអង្គការដៃគូ លើកិច្ចត្រៀមបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះ (Database) អ្នកចូលរួមចំនួន១៣នាក់ ស្រី០៥នាក់។ |

| | |
|---|---|
| | - បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ ជាមួយអង្គការដៃគូ ស្តីពីវឌ្ឍនភាពការងាររបស់អង្គការដៃគូ អ្នកចូលរួមចំនួន៣២នាក់ ស្រី១៨នាក់ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ ជាមួយក្រុមការងារការពារជនរងគ្រោះ អ្នកចូលរួមចំនួន៣៩នាក់ ស្រី១៩នាក់ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានចាត់បញ្ជូនមន្ត្រីចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលចំនួន ០២វគ្គគឺ នៅខេត្តពោធិ៍សាត់ និងបន្ទាយមានជ័យ ដែលមានសិក្ខាកាមចូលរួមចំនួន៤៧នាក់ (ស្រី១៩នាក់) ដែលរៀបចំដោយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា និងអង្គការ IOM។<br>- បានចាត់បញ្ជូនមន្ត្រី០៤រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរបស់អង្គការសម្ព័ន្ធចាប់ដៃ (រាជធានីភ្នំពេញ) ស្តីពីការពង្រឹងបណ្តាញការងារ និងកសាសមត្ថភាពដល់ អ្នកអនុវត្តការងារសង្គមកិច្ចដោយផ្ទាល់នៅកម្ពុជា។ |
| **ក្រសួងកិច្ចការនារី** | - ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៨ និងលទ្ធផលកិច្ចប្រជុំមន្ត្រីថ្នាក់ខ្ពស់ខមមីតលើកទី១២ នៅប្រទេសមីយ៉ាម៉ា និងអនុម័តលើផែនការសកម្មភាពការងារឆ្នាំ២០១៨ មានអ្នកចូលរួមមកពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធសរុបចំនួន៤០នាក់ ស្រី២២នាក់ ។<br>- បានចូលរួមធ្វើវិទិកា និងគាំទ្រដល់សកម្មភាពជនបង្គោលថ្នាក់ភូមិ/ឃុំ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការកេងប្រវ័ញ្ចនានា បានចំនួន០៦លើក ក្នុងមានខេត្តរតនគិរី(ស្រុកអូរយ៉ាដាវ) ខេត្តបាត់ដំបង(ស្រុកសំឡូត) ខេត្តកំពត(ស្រុកជុំគិរី) និងខេត្តកំពង់ចាម (ស្រុកស្ទឹងត្រង់) ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៦៩៦នាក់ ស្រី៣៨៣នាក់ ។<br>- បានចូលរួមកិច្ចប្រជុំជាមួយអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ ចំនួន០២លើកៈ<br>○ ចូលរួមពិភាក្សាត្រៀមរៀបចំកិច្ចប្រជុំប្តូរវេនរៀងភាគីកម្ពុជា-ចិន<br>○ ចូលរួមកិច្ចប្រជុំការងារវាយតម្លៃលើរបាយការណ៍ និងឯកសារការងារថ្នាក់ក្រោមជាតិរាជធានី-ខេត្ត<br>- បានចូលរួមសិក្ខាសាលាជាមួយក្រសួងសង្គមកិច្ច អតីយុទ្ធជន និងនីតិសម្បទា ចំនួន០២លើកៈ<br>○ ស្តីពីការពិគ្រោះយោបល់ថ្នាក់ជាតិលើគោលការណ៍ណែនាំ និងនីតិវិធីអាស៊ាន ដើម្បីដោះស្រាយតម្រូវការជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>○ កិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន០២លើកៈ<br>○ ស្តីពីសុវត្ថិភាព និងយុត្តិធម៌(ការទទួលស្គាល់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ក្នុងតំបន់អាស៊ាន។<br>○ ត្រីភាគីលើគោលការណ៍ណែនាំ ស្តីពីការដោះស្រាយវិវាទទាក់ទងនឹងពលករទេសន្តរប្រវេសន៍។<br>- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់បច្ចេកទេស ក្នុងចំណោមក្រុមប្រទេសបញ្ជូន(កម្ពុជា-ឡាវ និងមីយ៉ាន់ម៉ា) ស្តីពីតួនាទីប្រទេសបញ្ជូន ដើម្បីពិភាក្សា |

| | |
|---|---|
| | អំពីបញ្ហារួម រកដំណោះស្រាយរួមរបស់ពលករទេសន្តប្រវេសន៍នៅក្នុងប្រទេសគោលដៅ ។<br>- បានរៀបចំកិច្ចប្រជុំពិភាក្សារកជាតចូល ដើម្បីស្នើសុំទៅភាគីម៉ាឡេស៊ីដាក់ចូលទៅក្នុងសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់កិច្ចប្រជុំទ្វេភាគីនៅពេលខាងមុខ។ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | - ប្រជុំពិភាក្សាលើការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ស្តីពីការដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ក្រោមអធិបតីភាពលោកជំទាវ សឿ សុជាតា<br>- ចូលរួមប្រជុំអន្តរក្រសួង ស្តីពីការត្រៀមរៀបចំកិច្ចប្រជុំប្រទេសបញ្ជូន និងប្រទេសទទួលពលករ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង**។<br>- បានចូលរួមប្រជុំឆ្លងរបាយការណ៍ ស្តីពីរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០១៧ ទិសដៅឆ្នាំ២០១៨ នៅក្រសួងមហាផ្ទៃ ។<br>- បានចូលរួមប្រជុំអន្តរក្រសួង ស្តីពីការរៀបចំផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៥ឆ្នាំបន្ត(២០១៩-២០២៣) ក្រោមអធិបតីភាពលោក **ជំទាវ ជូ ប៊ុនអេង** នៅក្រសួងមហាផ្ទៃ។<br>- បានចូលរួមប្រជុំពិភាក្សា ពិនិត្យលទ្ធផល និងការផ្តល់ពិន្ទុនៃការវាយតម្លៃសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជូនរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០១៧។<br>- ចូលរួមប្រជុំអន្តរក្រសួង ស្តីពីការពិភាក្សាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស០៥ឆ្នាំបន្ត២០១៩-២០២៣ ក្រោមអធិបតីភាពលោក **ជំទាវ ជូ ប៊ុនអេង** នៅក្រសួងមហាផ្ទៃ។ |
| **អគ្គនាយកដ្ឋាន អន្តោប្រវេសន៍** | ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **សុខ ផល** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានអញ្ជើញចូលរួមចំនួន**៣៧**លើកៈ<br>- កិច្ចប្រជុំ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ ចំនួន១៦លើកៈ<br>○ កិច្ចប្រជុំពិនិត្យករណីពាក់ព័ន្ធបទល្មើសបរិហារកេរ្តិ៍ និងជេរប្រមាថអង្គព្រះមហាក្សត្រ<br>○ ធ្វើសេចក្តីរាយការណ៍អំពីការងាររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>○ កិច្ចប្រជុំស្តីពីការវិភាគមុខងារ ការកំណត់ក្របខ័ណ្ឌ<br>○ កិច្ចប្រជុំការងារវិសោធនកម្មរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ<br>○ កិច្ចប្រជុំពិភាក្សា និងចុះហត្ថលេខាលើផែនការសហប្រតិបត្តិការ ឆ្នាំ២០១៨<br>○ កិច្ចប្រជុំស្តីពីការធ្វើមាតុភូមនិវត្តន៍ពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក<br>○ កិច្ចប្រជុំស្តីពីបញ្ហាពាក់ព័ន្ធសមាគន និងអង្គការមិនមែនរដ្ឋាភិបាល (NGO)<br>○ កិច្ចប្រជុំស្តីពីអន្តោប្រវេសន៍ជនជាតិចិន ដែលកំពុងស្នាក់នៅ និងធ្វើអាជីវកម្មនៅខេត្តព្រះសីហនុ<br>○ កិច្ចប្រជុំក្រុមការងារអន្តរក្រសួងចុះសិក្សាស្ថានភាពតាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែន |

- កិច្ចប្រជុំក្រុមការងារដើម្បីសិក្សាធ្វើវិសោធនកម្មច្បាប់ ស្តីពីសញ្ជាតិ (ចំនួន០២លើក)
- ប្រជុំពិភាក្សាកំណត់ទិសដៅរួមគ្នាសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការងារគ្រប់គ្រងទេសន្តរប្រវេសន៍ និងត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា)
- កិច្ចប្រជុំការងារវិសោធនកម្មច្បាប់ ស្តីពីអន្តោប្រវេសន៍
- កិច្ចប្រជុំ ស្តីពីការងារចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ
- កិច្ចប្រជុំស្តាប់សេចក្តីរាយការណ៍ អំពីសកម្មភាពអនុវត្តការដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី និងទទួលពាក្យសុំប្រកាសទទួលស្គាល់ និងប័ណ្ណស្នាក់នៅអនៅអចិន្ត្រៃយ៍រយៈពេល០៦ខែ
- កិច្ចប្រជុំចង្អៀតពាក់ព័ន្ធការងារចាំបាច់មួយចំនួនរបស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍(គ.ស.អ) សម្រាប់រៀបចំការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨។

- ក្នុងឱកាស សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតិឲ្យចូលជួបសម្តែងការគួរសម នៅសាលទទួលភ្ញៀវអន្តរជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ ចំនួន០៥លើក៖
  - ឯកឧត្តម **VU QUANG MINH** ឯកអគ្គរដ្ឋទូតវៀតណាម ទើបតែងតាំងថ្មី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម
  - ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ប៊ួយ វ៉ាន់ណាម** អនុរដ្ឋលេខាធិការក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម
  - ឯកឧត្តម **DMITRI TSVETKOV** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី
  - ឯកឧត្តម **CHEN SHIGU** អគ្គនាយករងក្រសួងសន្តិសុខសាធារណរដ្ឋចិន និងជាប្រធានក្រុមការងារខមមីតចិន
  - ឯកឧត្តម **ZHAO KEZHI** សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងជំនួបពិភាក្សាផ្លូវការរវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន។
- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** របស់អគ្គនាយកដ្ឋាន និងរដ្ឋបាលរាជធានី-ខេត្ត ចំនួន០៩លើក (អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋនាអត្តសញ្ញាណកម្ម អគ្គាធិការដ្ឋានក្រសួងមហាផ្ទៃ គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងរដ្ឋបាលរាជធានីភ្នំពេញ កណ្តាល បន្ទាយមានជ័យ បាត់ដំបង)។
- កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ទទួលបន្ទុករៀបចំតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុក គឹមលេខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ (ចំនួន០២លើក)។
- ប្រជុំពិភាក្សាដើម្បីត្រៀមរៀបចំសម្របសម្រួលខ្លឹមសារកំណត់ហេតុ នៃកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជា មានិតឡាវ ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការ

| | |
|---|---|
| | ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំក្រុមពិភាក្សាការងារជំនាញរវាងភាគីទាំងពីរ កម្ពុជា និងចិន ស្តីពីការគ្រប់គ្រងព្រំដែន ការតាមចាប់ជនសង្ស័យ កិច្ចសហប្រតិបត្តិការ ការពារសុវត្ថិភាពវិថីមួយផ្លូវសូត្រមួយ ការប្រយុទ្ធប្រឆាំងបទល្មើស ការប្រយុទ្ធប្រឆាំងជនបរទេសប្រព្រឹត្តបទល្មើស ការជួញដូរមនុស្ស ការឆបោកតាមទូរគមនាគមន៍ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចការនគរបាលនៅតាមមូលដ្ឋាន។<br>- បានទទួលជួបពិភាក្សាការងារជាមួយចំនួន០៤លើកៈ<br>○ គណប្រតិភូនគរបាលជាតិសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក IM BYUNG HO ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសឧក្រិដ្ឋនៃការិយាល័យកិច្ចការបរទេស នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។<br>○ គណប្រតិភូ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសន្តិសុខសាធារណរដ្ឋចិន ដែលដឹកនាំដោយលោក LIAO JINRONG អគ្គនាយកកិច្ចសហប្រតិបត្តិការអន្តរជាតិចិន នៅអគ្គនាយកដ្ឋានអន្តប្រវេសន៍។<br>○ លោកស្រី DOMICA POTTIE ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំនៅទីក្រុងបាងកក និងលោកស្រី ALLISON STWARD ភារធារីស្ថានទូតកាណាដាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។<br>○ លោក រ៉ូប៊ីត ថមមិន អនុព័ន្ធប្រចាំតំបន់ នៃក្រសួងសន្តិសុខមាតុភូមិ ទទួលបន្ទុកកិច្ចការគយ និងព្រំដែនសហរដ្ឋអាមេរិក។<br>ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **សុខ ផល** អគ្គនាយកអន្តោប្រវេសន៍ បានអញ្ជើញចូលរួមៈ<br>- កិច្ចប្រជុំពិភាក្សាការអនុវត្តច្បាប់ ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដឹកនាំប្រជុំដោយ ឯកឧត្តម **ប៊ុន ហុន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ។<br>- ជួបពិភាក្សាការងារជាមួយលោកស្រី សេ ស៊ីលា តំណាងនគរបាលនៃប្រទេស NORDIC ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ និសហការី។<br>- ដឹកនាំកិច្ចប្រជុំបូកសរុបការងារឆមាសទី១ និងលើកទិសដៅអនុវត្តការងារបន្តឆមាសទី២ ឆ្នាំ២០១៨។<br>- បានអញ្ជើញចូលរួមក្នុងឱកាស **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** អនុញ្ញាតឲ្យលោកជំទាវ TINA SUSAN RIDSHAW ឯកអគ្គរដ្ឋទូតចក្រភពអង់គ្លេស ទើបតែងតាំងថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម។<br>- ជំនួបពិភាក្សាការងារជាមួយលោក JOSEPH GALOSKI តំណាងសេនានុព័ន្ធប្រចាំប្រទេសរបស់សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា និងសហការីន។<br>- ដឹកនាំគណៈប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងជាប្រធានកុងស៊ុលអាស៊ានលើកទី២២(22nd DGICM) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រព្រឹត្តទៅថ្ងៃទី០៦ ដល់១០ ខែសីហា ឆ្នាំ២០១៨។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សម្របសម្រួលចំនួន២៥២លើក អ្នកចូលរួមសរុបចំនួន១៥.៥៩៥នាក់ (ស្រី៦.៥០២នាក់)** | |
| **ខេត្តបន្ទាយមានជ័យ** | - បានរៀបកិច្ចប្រជុំប្រចាំខែ និងប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជខេត្ត នៅសាលាប្រជុំ(ខ)ខេត្ត ក្រោមអធិបតីភាព លោកស្រី **ប៉ុក ណាឌី** ប្រធានលេខាធិការ គ.ខ.ប.ជខេត្ត មានសមាសភាពចូលរួមចំនួន៤៨នាក់ ស្រី០៨នាក់។<br>- បានរៀបកិច្ចប្រជុំលើកកម្ពស់ការយល់ដឹង ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅភូមិទំនប់៥ មានអ្នកចូលរួមចំនួន៣៦នាក់ ស្រី០៥នាក់។ |

| | |
|---|---|
| | - បានរៀបកិច្ចប្រជុំរវាងអង្គការដៃគូ 3PC និងអង្គការគ្រួសារថ្មី ស្តីពីការសហការគ្នា នៅកន្លែងការធ្វើចំណាកស្រុករបស់ពលករ មានអ្នកចូលរួមចំនួន០៦នាក់ ស្រី ០២នាក់។<br>- បុគ្គលិកមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ចំនួន០១រូប បានចូលរួមប្រចាំខែ ជាមួយអង្គការម៉ារីតាន់នៅផ្សារមង្គល ស្តីពីការសហការគ្នាទទួលពលករទេសន្តរប្រវេសន៍។<br>- បុគ្គលិកមណ្ឌលស្នាក់នៅបណ្តោះអាសន្ន និង CS DIC ចំនួន០២រូប បានចូលរួមប្រចាំខែនៅអង្គការគ្រួសារថ្មី ស្តីពីការងារការធ្វើចំណាកស្រុក ។<br>- លេខាធិការ គ.ខ.ប.ជខេត្ត បានចូលរួមសហការជាមួយក្រុមការងារថ្នាក់ជាតិ ដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីចុះពិនិត្យ ស្ថានភាពពលករដែលអាជ្ញាធរថៃបញ្ជូនត្រឡប់។ និងពិនិត្យការសាងសង់មណ្ឌលសំចតនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត។<br>- ប្រជុំពិភាក្សា ស្តីពីការពង្រឹងកិច្ចសហការរវាងអាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការទទួលពលករដែលថៃចាប់បញ្ជូនមកវិញ នៅអគារមជ្ឈមណ្ឌលប៉ោយប៉ែត។<br>- ចូលរួមប្រជុំ ស្តីពីការពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ |
| **ខេត្តប៉ៃលិន** | - លោកជំទាវ **ជា លាភ** អនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជខេត្ត បានចូលរួមកិច្ចប្រជុំ៖<br>- ពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ស្តីពីការព្រារបាយការណ៍ប្រចាំត្រីមាសទី១ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត។<br>- ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។<br>- ឯកឧត្តម **ធូ ភា** អភិបាលរងនៃគណៈអភិបាលខេត្ត ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិលើសេចក្តីព្រាងរបាយការណ៍ជាតិគួបផ្សំលើកទី៤ ទី៥ ទី៦ សម្រាប់ផ្ញើជូនគណៈកម្មាធិការសិទ្ធកុមារ នៃអង្គការសហប្រជាជាតិ។<br>- ឯកឧត្តម ផាន់ ចាន់ធុល ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តប៉ៃលិន បានរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាសេចក្តីព្រាង ការកែសម្រួលសមាសភាព និងរបាយការណ៍ឆមាសទី១ ២០១៨ របស់ គ.ខ.ប.ជ ខេត្ត មនុស្សចូលរួម ៣២នាក់ ស្រី០៥នាក់។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងរបាយការណ៍ជាតិ ខួបលើកទី៥ និងទី៦ សម្រាប់ជូនគណៈកម្មាធិការសិទ្ធិកុមារ របស់ អង្គការសហប្រជាជាតិ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង មានអ្នកចូលរួមចំនួន៧០នាក់។<br>- បានចូលរួមប្រជុំជាមួយអង្គការអន្តរជាតិ ខាងការងារ ILO ក្នុងគម្រោងត្រីកោណ ស្តីពីការរៀបចំបច្ចេកទេសការងារ នៅភ្នំពេញសេនជីរ អ្នកចូលរួមមកពីប |

| | |
|---|---|
| | ណ្ដាខេត្តដូចជាខេត្តបាត់ដំបង កំពង់ធំ និងខេត្តកំពង់ចាម សរុបចំនួន១៦នាក់ ស្រី០៦នាក់។<br>- បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ ទិសដៅឆ្នាំ២០១៨ នៃការអនុវត្តផែនការ យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យការងារ ឆ្នាំ២០១៤-២០១៨ នៅទីស្តីការក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានអ្នកចូលរួមចំនួន៤៧០នាក់។<br>- បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដែលរៀបចំឡើងដោយអង្គការទស្សនៈពិភពលោក មានអ្នកចូលរួមមកពីខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្តបាត់ដំបង សរុបចំនួន១២៧នាក់ ស្រី៧៦នាក់ ។<br>- លោកជំទាវ ញ៉ឹក សាគន្ធ អភិបាលរងនៃគណៈអភិបាលខេត្ត បានអញ្ជើញចូលរួមជាគណៈអធិបតី៖<br>+ទិវាជាតិសុខភាពមាត់ធ្មេញ ពិនិត្យ ព្យាបាលឥតគិតថ្លៃដោយទន្តពេទ្យកម្ពុជា និងកម្មវិធីពិនិត្យជម្ងឺនិងផ្តល់វ៉ែនតាដោយឥតគិតថ្លៃ ដោយគ្រូពេទ្យស្ម័គ្រចិត្តមកពីអាមេរិក នឹងបានផ្សព្វផ្សាយអំពីការជួញដូរមនុស្ស និងការចំណាកស្រុកដោយសុវត្ថិភាព ដល់ពលរដ្ឋនៅក្រុងបាត់ដំបង និងស្រុកភ្នំព្រឹក ចំនួន ១,៦៥២នាក់។<br>+ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវការអគារមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន នឹងបានផ្សព្វផ្សាយអំពីការជួញដូរមនុស្ស និងការចំណាកស្រុកដោយសុវត្ថិភាព ដល់ពលរដ្ឋចំនួន ៤៥០នាក់។<br>+វគ្គបណ្តុះបណ្តាលស្តីពីទេសន្តរប្រវេសន៍ និងសមភាពយេនឌ័រដល់អាជ្ញាធរក្រុង ស្រុក ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការដៃគូ មនុស្សចូលរួម ៤១នាក់ ស្រី២៧នាក់។<br>- បានចូលរួមទស្សនៈកច្ចិអន្តរជាតិសម្រាប់ការពិភាក្សារវាងប្រទេសកម្ពុជា និងថៃ ស្តីពីបញ្ហាជួញដូរមនុស្ស និងការធ្វើចំណាកស្រុក នៅទីក្រុងបាងកក។<br>- បានរៀបចំវគ្គពិភាក្សាផ្សព្វផ្សាយ និងពិគ្រោះយោបល់ស្តីពីការចំណាកស្រុកដោយសុវត្ថិភាពចំនួន០២លើក មានមនុស្សចូលរួម១២៧នាក់ ស្រី៦៥នាក់<br>- បានសហការជាមួយអង្គការការីតាសកម្ពុជា រៀបចំវគ្គបណ្តុះបណ្តាលជនបង្គោលនិងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន០៦ស្រុកគោលដៅ៖ សំពៅលូន ភ្នំព្រឹក កំរៀង រុក្ខគិរី សំឡូត គាស់ក្រឡ មានមនុស្សចូលរួម ១៨៤នាក់ ស្រី៦១នាក់។<br>- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់អាជ្ញាធរឃុំ ចំនួន២ ឃុំសំរោងក្នុង ឃុំត្រែង មនុស្សចូលរួម ១០៥នាក់ ស្រី៣៩នាក់។<br>- បានចូលរួមជាវាគ្មិនក្នុងកម្មវិធីលើកកម្ពស់សិទ្ធិមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដែលរៀបចំដោយអង្គការប្រតិបត្តិការកុមារកម្ពុជា(OEC) ដល់គ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក១៣គ្រួសារ និងអាជ្ញាធរភូមិ-ឃុំ នាយកសាលា សរុប ២១នាក់ ស្រី១៦នាក់។ |
| **ខេត្តតាកែវ** | - កិច្ចប្រជុំក្រុមការងារថ្នាក់ស្រុកនៅស្រុកព្រៃកប្បាស អំពីយន្តការពង្រឹងការងារជួញដូរមនុស្ស និងការរំលោភសេន្លវៈ។<br>- លោកស្រី **គា សុភូ** អភិបាលរងខេត្ត បានចូលរួមកិច្ចប្រជុំ៖<br>○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅស្រុកគិរីវង់ មានអ្នកចូលរួមចំនួន២២៧នាក់ ស្រី១៨៧នាក់។ |

| | |
|---|---|
| | ○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅស្រុកកោះអណ្តែត មានអ្នកចូលរួមចំនួន៣៩៤នាក់ ស្រី៣០០នាក់។<br>○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅស្រុកត្រាំកក់ មានអ្នកចូលរួមចំនួន២៨១នាក់ ស្រី១៩៨នាក់។<br>○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅស្រុកទ្រាំង មានអ្នកចូលរួមចំនួន១៧០នាក់ ស្រី១៣៥នាក់។<br>○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅស្រុកបូរីជលសារ មានអ្នកចូលរួមចំនួន៧៤នាក់ ស្រី៤៧នាក់។<br>○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅស្រុកព្រៃកប្បាស មានអ្នកចូលរួមចំនួន៣៣៧នាក់ ស្រី៨០នាក់។<br>○ ផ្សព្វផ្សាយពង្រឹងការងារជួញដូរមនុស្ស និងចំណាកស្រុក នៅក្រុងដូនកែវចំនួន២លើក មានអ្នកចូលរួមចំនួន៧១៤នាក់ ស្រី៥៣នាក់។<br>○ ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>○ ជាមួយក្រុមការងារថ្នាក់ក្រុង ស្រុកទាំង១០ អំពីយន្តការពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងការរំលោភសេពសន្ថវៈ ចំនួន១២លើក មនុស្សចូលរួម ២,៩៣៧នាក់ ស្រី ១,៨០១នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំពិភាក្សាប្រចាំខែ ត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០១៨ ស្តីពីការបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ នៅសាលាខេត្តអ្នកចូលរួមចំនួន៤១៦នាក់ ស្រី១៩៨នាក់។<br>- បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការបូកសរុបឆ្លុះបញ្ចាំងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តម នូ ផល្លា ប្រធានក្រុមប្រឹក្សាខេត្ត អ្នកចូលរួមសរុបចំនួន២៣៦នាក់ ស្រី៩២នាក់។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមប្រជុំ ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។<br>- មន្ត្រីលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចពិភាក្សាពិគ្រោះយោបល់កម្រិតបច្ចេកទេសនៃប្រទេសបញ្ជូនមាន(កម្ពុជា-ឡាវ និងភូមិមា) នៅសណ្ឋាគារសុខាល័យអង្គរ។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ជាអភិបាលរងខេត្តទទួលបន្ទុកការងារអន្តោប្រវេសន៍ បានបើកកិច្ចប្រជុំផ្សព្វផ្សាយ ប្រកាសអន្តរក្រសួងលេខ ៧១៩ ប្រក ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា និង សេចក្តីជូនដំណឹង លេខ១៨៨ សជណ.អអ ស្តីពីកាតព្វកិច្ចធ្វើ ប័ណ្ណសៀវភៅការងារជនបរទេស របស់ម្ចាស់សហគ្រាស គ្រឹះស្ថាន កាស៊ីណូ និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ដល់ម្ចាស់ និងនាយកសហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់ជនបរទេសចំនួន១១៥សហគ្រាសគ្រឹះស្ថាន និងមានការចូលរួមពីសំណាក់ស្ថានអគ្គកុងស៊ុលរបស់ ប្រទេសបារាំង កូរ៉េ ជប៉ុន ចិន និង វៀតណាម ប្រចាំខេត្តសៀមរាបផងដែរ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានដឹកនាំក្រុមការងារបច្ចេកទេសទាំង៦ ចូលរួមពិធីបិទវគ្គបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន តំណាងក្រុមយុវជន និងក្រុមការងារការពារកុមារមកពីខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ នៅ |

| | |
|---|---|
| | សណ្ឋាគារអេប្បរាផាឡែស រៀបចំដោយអង្គការទស្សនៈពិភពលោក មានមនុស្សចូលរួម ៩០នាក់។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន បានចូលរួម៖<br>+ កិច្ចប្រជុំសម្របសម្រួលការងារគ្រប់គ្រងករណី និងសមាហរណកម្មកុមារក្នុងគ្រួសារប្រចាំត្រីមាសទី២ ឆ្នាំ២០១៨<br>+ កិច្ចប្រជុំស្តីពីដំណើរការគ្រប់គ្រងករណីរួមគ្នារវាងប្រទេសកម្ពុជា និងថៃ<br>- បានសម្របសម្រួលកិច្ចប្រជុំតុមូលស្តីពីការការពារសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណេត មានមនុស្សចូលរួម ៧៤នាក់ ស្រី៣១នាក់ |
| **ខេត្តឧត្តរមានជ័យ** | - បានចូលរួមកិច្ចប្រជុំ គ ក ស ក នៅសាលាខេត្ត បាន១០លើក មានអ្នកចូលរួមចំនួន២៥នាក់ ស្រី១១នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ មានអ្នកចូលរួមចំនួន៥០នាក់ ស្រី៤៦នាក់។<br>- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ រយៈ៨ខែ ឆ្នាំ២០១៨ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ មានមនុស្សចូលរួម ៧៦នាក់ ស្រី២៣នាក់។ |
| **ខេត្តព្រះវិហារ** | - កិច្ចប្រជុំអំពីការពិភាក្សា ជាមួយក្រុមការងារទាំង០៦ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ជំរុញឲ្យក្រុមការងារទាំង០៦ ធ្វើផែនការតាមជំនាញរៀងខ្លួន ក្នុងឆ្នាំ២០១៨ ដើម្បីអនុវត្តន៍សកម្មភាព ធ្វើការងារផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបន្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងជោគជ័យ អ្នកចូលរួមចំនួន២២នាក់ ស្រី១១នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ដើម្បីពង្រឹង និងជំរុញឲ្យក្រុមការងារទាំង០៦ យកចិត្តទុកដាក់ ដើម្បីអនុវត្តបន្តផ្សព្វផ្សាយដល់<br>ប្រជាពលរដ្ឋ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ ។ |
| **ខេត្តកំពង់ធំ** | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការត្រួតពិនិត្យ តាមដានការអនុវត្តក្រុមប្រតិបត្តិយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។<br>- បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារក្នុងឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី នៅវិមានសន្តិភាព ទីស្តីការគណៈ រដ្ឋមន្ត្រី។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ ស្តីពីការផ្សព្វផ្សាយការងារទេសន្តរប្រវេសន៍ ការដឹកប្រជុំក្រោមអធិបតីភាពលោក នាយករងរដ្ឋបាលខេត្ត និងអនុប្រធានលេខាធិការ គ.ខ.ប.ជ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយស្តីពី ការបញ្ជ្រាបយេនឌ័រអនុសញ្ញា ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ(ស៊ី-ដ) ការ |

| | |
|---|---|
| | លើក កម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងវិស័យទេសចរណ៍ ក្រោមអធិបតីភាពលោកជំទាវ ហ៊ុន ដានី អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ នៅសាលប្រជុំផ្ទះសំណាក់ពន្លឺថ្មី ។<br>- ប្រធានលេខាធិការ គ.ខ.ប.ជ បានចូលរួមជាអធិបតី ក្នុងវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយយល់ដឹង ស្តីពីយន្តការ និងផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់០៨ក្រុង-ស្រុក ទូទាំងខេត្ត។<br>- លេខាធិការ គ.ខ.ប.ជខេត្ត បានចូលរួមប្រជុំ ស្តីពីការផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។<br>- បានសម្ភាសន៍ជាមួយគម្រោងអូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (AAPTI P) ដើម្បីស្វែងយល់ពីភាពរីកចម្រើន និងបញ្ហាប្រឈមនានា នៃការអនុវត្តសកម្មភាពយេនឌ័រ និងក្រុមប្រតិបត្តិយេនឌ័រ ដែលបានអនុវត្តកន្លងមកនៅការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត។<br>- លេខាធិការ គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០១៨ ដើម្បីពិភាក្សាអំពីសកម្មភាពដែលបានអនុវត្តកន្លងមក និងបញ្ហាប្រឈមនានា។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានរៀបចំប្រជុំត្រីមាសទី៣ និងប្រជុំប្រកាសសមាសភាពគណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត នៅសាលប្រជុំ សាលាខេត្តកំពង់ធំ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជខេត្តបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើកុមារវគ្គទី១៧ (ILEA)នៅប្រទេសថៃ រយៈពេល១៥ថ្ងៃ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានរៀបចំកិច្ចប្រជុំស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីពិភាក្សារកបញ្ហាប្រឈម និងដំណោះស្រាយរួមគ្នា<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាលការពង្រឹងសមត្ថភាពជនបង្គោលស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅគ្រប់រដ្ឋបាលក្រុង ស្រុកទាំង៨ ក្នុងខេត្ត។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រចំណាកស្រុកដោយសុវត្ថិភាព និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អាជ្ញាធរចំនួន២ភូមិ-៨ឃុំ មនុស្សចូលរួមសរុប ៥៣៣នាក់ ស្រី៤១២នាក់។ |
| ខេត្តកណ្តាល | - ក្រុមការងារថ្នាក់ក្រុង-ស្រុកទាំង១១ បានរៀបចំកិច្ចប្រជុំប្រចាំខែ ពង្រឹងសមត្ថភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន៥៦លើក មានអ្នកចូលរួមចំនួន១.១៨៤នាក់ ស្រី៨៤៧នាក់។<br>- គណៈកម្មាធិការខេត្ត និងលេខាធិការដ្ឋានខេត្ត កិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ និងប្រចាំខែ ត្រីមាស ឆ្នាំ២០១៨ បានចំនួន០៦ លើក អ្នកចូលរួមចំនួន៣២៣នាក់ ស្រី១៧៥នាក់។<br>- គណៈកម្មាធិការ គ.ខ.ប.ជ និងលេខាធិការដ្ឋានខេត្ត កិច្ចប្រជុំប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០១៨ ចំនួន០១លើក មានអ្នកចូលរួមក្រុមការងារថ្នាក់ខេត្ត/ក្រុង/ស្រុក ចំនួន៩៤នាក់ ស្រី៥០នាក់។<br>- លោកអភិបាលស្រុក និងជាប្រធានក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកលើកដែក បានរៀបចំកិច្ចប្រជុំ ស្តីពីការលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យនៅ |

| | |
|---|---|
| | ក្នុងផ្ទៃប្រទេស និងការអនុវត្តច្បាប់ផ្សព្វផ្សាយត្រួតពិនិត្យចរាចរណ៍ឆ្លងដែន ដើម្បីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងដែន ។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន០២លើក អ្នកចូលរួមចំនួន២៣នាក់ ស្រី១០នាក់៖<br>○ ស្តីពីការពង្រឹងសមត្ថភាព និងការវាយតម្លៃលទ្ធផលការងាររបស់សមាជិក គ.ខ.ប.ជខេត្ត អ្នកចូលរួមចំនួន១១នាក់ ស្រី០៥នាក់។<br>○ ស្តីពីការរំលឹករបាយការណ៍របស់ក្រុមការងារលេខាធិការដ្ឋាន និងក្រុមទាំង៦ដែលពាក់ព័ន្ធលេខាធិការដ្ឋានគ.ខ.ប.ជ អ្នកចូលរួមចំនួន១២នាក់ ស្រី០៥នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងទប់ស្កាត់អពើហឹង្សាក្នុងគ្រួសារ ដល់ គ.ក.ន.ក យុវជននិងក្រុមគ្រួសារ ឪពុកម្តាយ បានចំនួន១២លើក អ្នកចូលរួមចំនួន៤៧៩នាក់ ស្រី២៤២នាក់។ |
| **ខេត្តពោធិ៍សាត់** | - បានចាត់បញ្ជូនមន្រ្តីនគរបាល០១រូប នៃស្នងការដ្ឋាននគរបាលខេត្ត ទៅចូលរួមវគ្គហ្វឹកហ្វឺនជំនាញស៊ើបអង្កេត បទល្មើសជួញដូរមនុស្ស នៅរាជធានីភ្នំពេញ។<br>- មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបានរៀបចំទិវាប្រឆាំងពលកម្មកុមារអន្តរជាតិ១២មិថុនា នៅអនុវិទ្យាល័យស្រះម្កាក់ មានមនុស្សចូលរួម ៣៣០ នាក់ |
| **ខេត្តកំពង់ស្ពឺ** | - បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន១៩៣នាក់ ស្រី៩៨នាក់។<br>- បានរៀបចំកិច្ចប្រជុំការងារអន្តរមន្ទីរ ស្ថាប័ន ដែលអ្នកចូលរួមចំនួន៤៣នាក់ ស្រី១៩នាក់។ |
| **ខេត្តរតនគិរី** | - លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ជាគណអធិបតី ក្នុងវគ្គសិក្ខាសាលាចំនួន០២លើក ស្តីពីផែនការសកម្មភាព ការបង្ការ ទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ និងស្តីពីការធកិវឌ្ឍន៍កុមារតូច និងការអប់រំក្រុមឪពុក ម្តាយ។<br>- មន្ទីរសង្គមកិច្ចខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការថែទាំមនុស្សចាស់ ការការពារកុមាររងគ្រោះ និងងាយរងគ្រោះ ដែលអ្នកចូលរួមចំនួន១២៥នាក់។ |
| **ខេត្តស្ទឹងត្រែង** | - មន្រ្តីកិច្ចការនារីខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា នៅខេត្តរតនគិរី។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ( ស៊ី-ដ ) នៅខេត្តក្រចេះ។ |
| **ខេត្តក្រចេះ** | - បានប្រជុំគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត និងក្រុមការងារអន្តរមន្ទីរទាំង៦ ស្តីពីការពង្រឹងតួនាទី ភារកិច្ច និងត្រៀមធ្វើរបាយការណ៍ ៩ខែ និងរបាយការណ៍១០ខែ ឆ្នាំ២០១៨ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>- លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំប្រជុំស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែចំនួន០៥លើក មនុស្សចូលរួម៣៥នាក់ ស្រី១៥ នាក់<br>- បានប្រជុំស្តីពីការពង្រឹងការអនុវត្តតួនាទី ភារកិច្ចដល់ក្រុមការងារទាំង៦ របស់ គ.ខ.ប.ជ និងរៀបចំធ្វើផែនការសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៥លើក ដែលអ្នកចូលរួម ៣២៥នាក់ ស្រី២៩៤នាក់។<br>- បានចូលរួមប្រជុំជាមួយគណៈកម្មការចម្រុះស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ មនុស្សចូលរួម ១៤នាក់ ស្រី១០នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ និងការផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ ដែលអ្នកចូលរួម ៧៥នាក់ ស្រី៦៥នាក់។ |

| | |
|---|---|
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមចំកិច្ចប្រជុំប្រចាំខែមីនា ឆ្នាំ២០១៨ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅសាលាខេត្តកំពង់ចាម ដែលមានអ្នកចូលរួមចំនួន១៣នាក់ (ស្រី១០នាក់)។<br>- បានចូលរួមកិច្ចប្រជុំ ស្តីពីនីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។<br>- បានចូលរួមចំកិច្ចប្រជុំប្រចាំខែមីនា ឆ្នាំ២០១៨ របស់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កុមារ នៅសាលាខេត្តកំពង់ចាម ដែលមានអ្នកចូលរួមចំនួន២៥នាក់។<br>- បានចូលកិច្ចប្រជុំ ស្តីពីនីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស ដែលប្រព្រឹត្តទៅនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម។ |
| **ខេត្តត្បូងឃ្មុំ** | - លេខាធិការដ្ឋានខេត្ត សហការជាមួយអង្គការស៊ីកាស្វា និងអង្គការភ្លែនអន្តរជាតិ បានរៀបចំសិក្ខាសាលាស្តីពីការអនុវត្តល្អ និងការពង្រឹងនីតិវិធីនគរបាលយុត្តិធម៌ បែបកុមារមេត្រី និងសេវាសង្គម ព្រមទាំងពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៧ ដែលមានអ្នកចូលរួម ៧៩នាក់ ស្រី ៣៣នាក់។ |
| **ខេត្តកោះកុង** | ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានដឹកនាំកិច្ចប្រជុំ៖<br>- ផ្សព្វផ្សាយសេចក្តីសម្រេចលេខ០២១/១៨ របស់ លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។<br>- ផ្សព្វផ្សាយសេចក្តីសម្រេចលេខ០២២/១៨ របស់រដ្ឋបាលខេត្ត ស្តីពីការបង្កើតក្រុមការការជំនាញ អង្គភាព អន្តរមន្ទីរ សម្រាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ដឹកនាំប្រជុំលេខាធិការដ្ឋាន១លើក មនុស្សចូលរួម ១៨នាក់ ស្រី៨នាក់<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំវគ្គបណ្តុះបណ្តាលថ្នាក់ស្រុក ឃុំ ស្តីពីការពង្រឹងសមត្ថភាពជនបង្គោលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា បាន០៦លើក មនុស្សចូលរួម ២២៤នាក់ ស្រី ៦៣នាក់។<br>- ចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រចាំឆ្នាំ២០១៨ និងទិសដៅបន្តនៅភ្នំពេញ ០១លើក<br>- បើកវគ្គបណ្តុះបណ្តាលស្តីពីចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន ចំនួន០៤វគ្គ មនុស្សចូលរួម ២៣៩នាក់ ស្រី១៦៧នាក់។ |
| **ខេត្តព្រះសីហនុ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែមករា ស្តីពីការពង្រឹងសមត្ថភាព និងជំរុញដល់មន្ទីរ អង្គភាពជុំវិញខេត្ត និងតាមក្រុង/ស្រុក ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យអនុវត្តន៍ទៅតាមតួនាទី និងភារកិច្ច សហការគ្នាផ្តល់របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ មកលេខាធិការដ្ឋានជាប្រចាំ។ |

| | |
|---|---|
| ខេត្តកំពត | - ចូលរួមជាវាគ្មិនកម្មវិធីវិទ្យុ ៩មករា ខេត្តកំពតលើប្រធានបទដំណើរនៃការរាយការណ៍ករណីហឹង្សាលើស្ត្រី និងការជួញដូរមនុស្ស ១លើក។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំស្តីពី គោលកាណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០១៧ មនុស្សចូលរួម ៣៥នាក់ ស្រី ៤នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយអង្គការ ILO បើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន ២វគ្គ មនុស្សចូលរួម ៧០នាក់ ស្រី ២០នាក់។<br>- បានរៀបចំកិច្ចប្រជុំក្រុមលេខាធិការដ្ឋាន ៣លើក ដើម្បីត្រួតពិនិត្យសកម្មភាព ជំរុញការផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>- ទទួលជួបជាមួយលោកស្រី Dr. Anna Miki តំណាងអង្គការ Caram International ដើម្បីវាយតម្លៃដោយឯករាជ្យនូវកម្មវិធីការពារកុមារ។<br>- ទទួលជួបជាមួយប្រធានក្រុមការងារពង្រឹងយុត្តិធម៌ និងបណ្តុះបណ្តាល អង្គការអេស្ប៉ាញ អង្គការ Aple ពាក់ព័ន្ធការបំពារបំពានផ្លូវភេទលើកុមារ និងស្នើសុំសហការទប់ស្កាត់ជនជាតិអាល្លឺម៉ង់ម្នាក់ធ្លាប់ប្រព្រឹត្តល្មើសនៅប្រទេសរបស់គាត់ ប៉ុន្តែបច្ចុប្បន្នកំពង់ស្នាក់នៅខេត្តកំពត។ |
| ខេត្តកែប | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំចំនួន២លើក ដើម្បីឆ្លងសេចក្តីព្រាងរបាយការណ៍ និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **អ៊ុល ភីរុណ** អភិបាលរងខេត្ត និងជាប្រធានលេខាធិការ គ.ខ.ប.ជ ។<br>- លោកជំទាវ **អ៊ុល ភីរុណ** ប្រធានលេខាធិការ គ.ខ.ប.ជ បានចូលរួមក្នុវិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៨៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន**គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។<br>- សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកែប បានចុះកិច្ចសន្យាជាមួយសហព័ន្ធសមាគមនារីខេត្តគៀនយ៉ាង(វៀតណាម) លើវិស័យមួយចំនួនរួម<br>ទាំងការងារបង្ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារផងដែរ ។ |
| ខេត្តព្រៃវែង | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- លោកជំទាវ លៀង ស្រីមុល ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងជាអភិបាលរងខេត្តបានចូលរួម៖<br>○ ជាគណៈអធិបតីក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច នៅសាលាស្រុកពោធិ៍រៀង រៀបចំដោយអង្គការសម្ព័ន្ធចាប់ដៃ ។<br>○ កិច្ចប្រជុំប្រចាំត្រីមាសរបស់ស្ត្រី នៅសាលាខេត្តព្រៃវែង ដែលរៀបចំដោយអង្គការ យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា(GADC) ។<br>- គណៈកម្មធិការពិគ្រោះយោបល់ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីផ្សព្វផ្សាយអប់រំអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រឆាំងអំពើជួញដូរមនុស្សដល់អង្គប្រជុំ ជាពិសេសដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យ ពួកគាត់បានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន តាមរយៈពិធីមង្គលការ ពិធីបុណ្យ និងពិធីកំសាន្តផ្សេងៗ ។ល។ |

| | |
|---|---|
| | - លោកជំទាវ ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួម ក្នុងកិច្ចប្រជុំ៖<br>○ ធ្វើជាអធិបតីប្រជុំត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ និងឆមាសទី១ ឆ្នាំ២០១៨ ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ នៅសាលាខេត្តព្រៃវែង<br>○ ពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៨៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន**គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។<br>○ ធ្វើជាអធិបតីប្រជុំត្រីមាសរបស់ស្ត្រីដឹកនាំនៅថ្នាក់ក្រោមជាតិ នៅសាលាខេត្តព្រៃវែង សម្របសម្រួលពីអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា<br>○ ធ្វើជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងយន្តការដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍ ដល់ក្រុមប្រឹក្សាឃុំ នារីឃុំ និងមេប៉ុស្តិ៍មកពីស្រុកកញ្ច្រៀច ស្រុកកំចាយមារ និងស្រុកស្វាយអន្ទរ នៅសាលប្រជុំផ្ទះសំណាក់រឿងឡឹង សម្របសម្រួលដោអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី។ |
| **ខេត្តមណ្ឌលគិរី** | - លោកស្រីស្នងការរងទទួលបន្ទុកបានដឹកនាំមន្រ្តីជំនាញនៃការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជនចូលរួមកិច្ចប្រជុំត្រួតពិនិត្យ ការអនុវត្តគោលការណ៍របស់អគ្គស្នងការនគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧ ។<br>- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតាមដានត្រួតពិនិត្យការអនុវត្តក្រុមប្រតិបត្តិការងារយេនឌ័រក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅរាជធានីភ្នំពេញ។<br>- ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួម ក្នុងកិច្ចប្រជុំ វិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១៨៧ និងទិសដៅឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិ គ.ជ.ប .ជ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ ។ |